វិទ្យាស្ថានបណ្តុះបណ្តាល និង
ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា

# វិមជ្ឈការហិរញ្ញវត្ថុនៅកម្ពុជា៖ ការងារសម្រេចបាន និងជំហានបន្ទាប់





ប៉ក់ គឹមជឿន

ឯកសារពិភាក្សាលេខ ៥០

ឧសភា ២០១១

ឯកសារបោះពុម្ពផ្សាយរបស់វិទ្យាស្ថាន CDRI

# វិមជ្ឈការហិរញ្ញវត្ថុនៅកម្ពុជា៖ ការងារសម្រេចបាន និងជំហានបន្ទាប់

## ឯកសារពិភាក្សាលេខ ៥០

ប៉ាក់ គីមជឿន

វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា

ខែឧសភា ២០១១ ភ្នំពេញ កម្ពុជា

**បេសកកម្ម វបសអ**

ក្នុងលក្ខណៈជា វិទ្យាស្ថានកម្ពុជាឯករាជ្យផ្នែកស្រាវជ្រាវពីគោលនយោបាយអភិវឌ្ឍន៍ វបសអ មានបេសកកម្មរួមចំណែកដល់ការអភិវឌ្ឍប្រទេសប្រកបដោយចីរភាព និងលើកកំពស់សុខុមាលភាពប្រជាពលរដ្ឋកម្ពុជា តាមរយៈការស្រាវជ្រាវមានគុណភាពខ្ពស់ពីគោលនយោបាយអភិវឌ្ឍន៍ ការផ្សព្វផ្សាយចំណេះដឹង និងការកសាងសមត្ថភាព ។

វបសអ ប្រឹងប្រែងបំពេញបេសកកម្មនេះ ដោយធ្វើការជាដៃគូជាមួយស្ថាប័នសាធារណៈ និងសង្គមស៊ីវិលកម្ពុជា ស្ថាប័នអភិវឌ្ឍន៍ក្នុងតំបន់ និងពិភពលោក និងដោយគោរពដល់សមត្ថភាពរបស់ប្រជាពលរដ្ឋ និងស្ថាប័នកម្ពុជា ចំណេះដឹង និងបទពិសោធន៍ក្នុងស្រុក ព្រមទាំងប្រវត្តិសាស្ត្រ និងវប្បធម៌របស់ប្រទេសកម្ពុជា ។

**© រក្សាសិទ្ធិឆ្នាំ២០១១ វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា** (វបសអ)

រក្សាសិទ្ធិគ្រប់យ៉ាង - គ្មានផ្នែកណាមួយនៃឯកសារនេះ ដែលអាចយកទៅចម្លងទុក ឬផ្សព្វផ្សាយតាមទម្រង់ និងតាមមធ្យោបាយផ្សេងៗ ដូចជា អេឡិចត្រូនិក យន្តកម្ម ថតចម្លង... ។ល។ ដោយគ្មានការអនុញ្ញាតជាលាយលក្ខណ៍អក្សរពីវិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជាឡើយ ។

**វិមជ្ឈការហិរញ្ញវត្ថុនៅកម្ពុជា៖ ការងារសម្រេចបាន និងជំហានបន្ទាប់**

ឯកសារពិភាក្សាលេខ ៥០
ខែឧសភា ឆ្នាំ២០១១

**ប៉ាក់ គឹមជឿន**

*ទស្សនៈទាំងឡាយនៅក្នុងឯកសារនេះ គឺជាគំនិតផ្ទាល់របស់អ្នកនិពន្ធ និងមិនមែនជាទស្សនៈរបស់វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជាទេ ។*

**រូបភាពនៅក្របមុខ**

1. តាមរយៈវិមជ្ឈការហិរញ្ញវត្ថុ ឥឡូវនេះក្រុមប្រឹក្សាឃុំមានមធ្យោបាយមួយចំនួន ដើម្បីធ្វើតាមការសន្យាដល់ប្រជាជនមូលដ្ឋាន៖ ឃុំព្រែកនរិន្ទ ខេត្តបាត់ដំបង
2. ប្រជាជនមានភាពជាម្ចាស់ខ្លាំងជាង លើការងារដែលមូលដ្ឋានផ្តល់ថវិកា៖ ផ្លូវមានការថែទាំល្អ នៅឃុំកំពង់ត្រាច ខេត្តកំពត

**វិទ្យាស្ថាន** CDRI

អគារលេខ ៥៦ ផ្លូវលេខ ៣១៥ ខ័ណ្ឌទួលគោក ប្រអប់សំបុត្រលេខ ៦២២ ភ្នំពេញ កម្ពុជា
ទូរស័ព្ទ៖ (៨៥៥-២៣) ៨៨១-៣៨៤, ៨៨១-៧០១, ៨៨១-៩១៦, ៨៨៣-៦០៣
ទូរសារ៖ (៨៥៥-២៣) ៨៨០-៧៣៤
អ៊ីមែល៖ cdri@cdri.org.kh http://www.cdri.org.kh

កែសម្រួល និងរចនាដោយ៖ អ៊ុំ ចាន់ថា និង យូ សិទ្ធីរិទ្ធ
បោះពុម្ពនៅប្រទេសកម្ពុជាដោយ រោងពុម្ព ស៊ុន ហ៊ាង រាជធានីភ្នំពេញ

# មាតិកា


សេចក្តីថ្លែងអំណរគុណ.......7

សេចក្តីសង្ខេប.......9

១. សេចក្តីផ្តើម.......11

២. ទ្រឹស្តីសាកលស្តីពីវិមជ្ឈការហិរញ្ញវត្ថុ.......11

*២.១. ធាតុសំខាន់ៗនៃវិមជ្ឈការហិរញ្ញវត្ថុ.......12*

*២.២. ការកសាងប្រព័ន្ធគ្រប់គ្រងដំណើរការអនុវត្តវិមជ្ឈការហិរញ្ញវត្ថុ.......14*

៣. កំណែទម្រង់វិមជ្ឈការនៅកម្ពុជា៖ បរិបទ និងការងារសម្រេចបាន.......16

*៣.១. បរិបទ.......16*

*៣.២. ភាពរីកចម្រើននៃកំណែទម្រង់ក្នុងពេលកន្លងមក.......17*

៤. ផែនការសម្រាប់ដំណាក់កាលបន្ទាប់នៃកំណែទម្រង់.......22

*៤.១. ទិសដៅគោលនយោបាយសម្រាប់រយៈពេលវែង.......22*

*៤.២. តួនាទីរំពឹងទុកសម្រាប់បណ្តាថ្នាក់ក្រោមជាតិ.......23*

៥. បញ្ហាប្រឈមក្នុងជំហានខាងមុខ.......25

*៥.១. ការពិនិត្យពីមុខងារ និងការផ្ទេរមុខងារ.......25*

*៥.២. ចំណូលផ្ទាល់ និងមូលធនផ្ទេរពីថវិកាជាតិ.......28*

*៥.៣. តួនាទីរបស់ដៃគូអភិវឌ្ឍន៍ និងការអនុវត្តគម្រោងអភិវឌ្ឍន៍.......32*

៦. សេចក្តីសន្និដ្ឋាន.......33

ឯកសារយោង.......34

បញ្ជីឯកសារពិភាក្សារបស់វិទ្យាស្ថាន CDRI.......37

# តារាង និងប្រអប់

តារាង ១៖ ការបែងចែកថវិកាតាមថ្នាក់រដ្ឋបាល យោងតាមច្បាប់ថវិកាជាតិឆ្នាំ២០០៨ ២០០៩ និង ២០១០ ................. 19
តារាង ២៖ ប្រភេទនៃរដ្ឋបាលក្រោមជាតិ និងសមាសធាតុ.......................................................................................23
តារាង ៣៖ ប្រភេទនៃមុខងារ និងធនធានហិរញ្ញវត្ថុសម្រាប់គ្រប់គ្រង និងចាត់ចែងប្រភេទមុខងារនីមួយៗ.......................28

ប្រអប់ទី ១៖ ជំហានបឋមក្នុងការពិភាក្សាអំពីការផ្ទេរមុខងារក្នុងវិស័យអប់រំ..................................................................27
ប្រអប់ទី ២៖ ការភ្ជាប់ទំនាក់ទំនងរវាងកំណែទម្រង់វិមជ្ឈការ និងការផ្តល់សេវាតាមវិស័យ៖ ករណីវិស័យកសិកម្ម និងធនធានទឹក ........................................................................................................................ 31

# សេចក្តីថ្លែងអំណរគុណ

ខ្ញុំសូមថ្លែងអំណរគុណដល់ស្ថាប័ន និងបុគ្គលមួយចំនួនដែលបានជួយឧបត្ថម្ភគាំទ្រក្នុងការធ្វើឱ្យអត្ថបទនេះលេចចេញជារូបរាងឡើង ។ ជាដំបូង ខ្ញុំសូមអរគុណដល់ការចាត់ចែងរបស់ CDRI ដែលបាន ផ្តល់ជាធនធានហិរញ្ញវត្ថុសម្រាប់ការប្រមូលទិន្នន័យ ការពិនិត្យផ្ទៀងផ្ទាត់ និងការបោះពុម្ព ។ ជាបន្ទាប់ ខ្ញុំសូមអរគុណដល់លោកសាស្ត្រាចារ្យ Paul Smoke មកពី New York University និង លោកសាស្ត្រាចារ្យ Joakim Ojendal មកពី Göteborg University រួមជាមួយនឹងលោក មិន មុនី ជាទីប្រឹក្សាឯករាជ្យ ដែលបានផ្តល់មតិកែសម្រួលទៅលើសេចក្តីព្រាងនៃអត្ថបទនេះ ។ ខ្ញុំក៏សូមអរគុណផងដែរដល់លោក អ៊ូ ស៊ីវហួច ដែលជាអ្នកស្រាវជ្រាវ និងអ្នកសម្របសម្រួលក្នុងកម្មវិធីអភិបាលកិច្ចតាមបែបប្រជាធិបតេយ្យ និងកំណែទម្រង់វិស័យសាធារណៈនៅវិទ្យាស្ថាន CDRI ដែលបានជួយសម្របសម្រួលដល់ដំណើរការស្រាវជ្រាវ និងតាក់តែងអត្ថបទនេះ ក៏ដូចជាអ្នកស្រាវជ្រាវដទៃទៀតដែលបានចូលរួមជាគំនិត ធ្វើឱ្យអត្ថបទនេះមានគុណភាពកាន់តែប្រសើរឡើង ។

# សេចក្តីសង្ខេប

ដើម្បីសម្រេចបានការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ វិមជ្ឈការហិរញ្ញវត្ថុនៅជំហានខាងមុខរបស់កម្ពុជា នឹងផ្តោតទៅលើថ្នាក់ក្រុង ស្រុក/ខណ្ឌ ទាំងលើកំណែទម្រង់ស្ថាប័ន ការពង្រឹងសមត្ថភាព និងការផ្សារភ្ជាប់ជាមួយការផ្តល់សេវាតាមវិស័យឱ្យបានកាន់តែប្រសើរ ។ ដើម្បីជម្រុញឱ្យដំណើរការលូតលាស់ទៅមុខ ការធ្វើកំណែទម្រង់ត្រូវមានលក្ខណៈគ្រប់ជ្រុងជ្រោយ និងមានការសម្របសម្រួលល្អ ទាំងនៅកម្រិតគោលនយោបាយ កម្រិតការអនុវត្ត និងកម្រិតនៃកម្មវិធីកំណែទម្រង់ ។ ភាពគ្រប់ជ្រុងជ្រោយ មិនមែនមានន័យថា រដ្ឋាភិបាលត្រូវតែចាត់ចែងលើគ្រប់ទិដ្ឋភាពនៃកំណែទម្រង់ក្នុងពេលតែមួយនោះទេ ពីព្រោះការធ្វើបែបនេះ អាចច្រើនហួសលទ្ធភាពនាពេលបច្ចុប្បន្ន និងផ្ទុយពីគោលការណ៍ រៀនបណ្តើរធ្វើបណ្តើររបស់រដ្ឋាភិបាល ។ ផ្ទុយទៅវិញ ភាពគ្រប់ជ្រុងជ្រោយ មានន័យថា ត្រូវមានចក្ខុវិស័យច្បាស់លាស់សម្រាប់រយៈពេលវែង និងមធ្យម និងមានការរំពឹងទុកឱ្យបានត្រឹមត្រូវពីបញ្ហាប្រឈមដែលអាចកើតឡើង និងការដោះស្រាយបញ្ហាប្រឈមទាំងនោះជាជំហានៗប្រកបដោយយុទ្ធសាស្ត្រ ។

ការផ្សារភ្ជាប់កំណែទម្រង់វិមជ្ឈការហិរញ្ញវត្ថុ ជាមួយនឹង ការងារផ្តល់សេវាតាមវិស័យ គឺជាបញ្ហាប្រឈមធំមួយ ដោយសារក្រសួងតាមវិស័យនីមួយៗ ភាគច្រើនមិនទាន់គិតគូរឱ្យបានដិតដល់អំពីការងារវិមជ្ឈការទេ ដែលនាំឱ្យមានកង្វះខាតការសម្របសម្រួល ទាំងក្នុងកម្រិតគោលនយោបាយ និងកម្រិតអនុវត្តន៍ការងារផ្តល់សេវា និងមួយទៀតដោយសារកង្វះការសម្របសម្រួលរវាងគម្រោងអភិវឌ្ឍន៍ដែលគាំទ្រដល់ការងារវិមជ្ឈការ ជាមួយនឹងគម្រោងដែលដំណើរការតាមវិស័យ ។ ដើម្បីដោះស្រាយបញ្ហានេះ ក្រសួងមហាផ្ទៃ និង ក្រសួងជំនាញ តាមរយៈ គ.ជ.អ.ប ត្រូវសហការជាមួយគ្នាឱ្យបានច្រើន និងជៀសវាងការភាន់ច្រឡំថា កំណែទម្រង់វិមជ្ឈការ ជាដែនសមត្ថកិច្ចរបស់ក្រសួងមហាផ្ទៃតែមួយក្រសួង ព្រោះតាមពិតគឺជាកម្មវិធីកំណែទម្រង់របស់រដ្ឋទាំងមូល ។ ដៃគូអភិវឌ្ឍន៍នានា ក៏ត្រូវចូលរួមសហការផងដែរ ។

យើងឃើញមានហេតុផល ទាំងសុទិដ្ឋិនិយមផង និងទុទិដ្ឋិនិយមផង ចំពោះអនាគតនៃកំណែទម្រង់វិមជ្ឈការហិរញ្ញវត្ថុនៅកម្ពុជា ដូចមានចែងក្នុងច្បាប់រៀបចំអង្គការ ។ ម្យ៉ាង យើងមើលឃើញថា បទពិសោធន៍មានជោគជ័យនៃការអនុវត្តកំណែទម្រង់កន្លងមក នៅថ្នាក់ឃុំ/សង្កាត់ តាំងពីឆ្នាំ២០០២ បានផ្តល់ការសង្ឃឹមយ៉ាងរឹងមាំថារាជរដ្ឋាភិបាលនឹងធ្វើការសម្របសម្រួល និងពង្រឹងសមត្ថភាពរបស់ខ្លួន ដើម្បីអនុវត្តដំណើរការកំណែទម្រង់ឲ្យបានសម្រេច ។ ម្យ៉ាងវិញទៀត កំណែទម្រង់នៅថ្នាក់ ឃុំ/សង្កាត់ បានអនុវត្តលើការងារតិចមុខណាស់ បើធៀបនឹងការងារដែលគេរំពឹងថាត្រូវសម្រេចឱ្យបាននាជំហានបន្ទាប់ ។ យើងឃើញថា កំណែទម្រង់នៅថ្នាក់ឃុំ/សង្កាត់ មិនទាន់បានឆ្លងកាត់សូម្បីតែការងារជាមូលដ្ឋានមួយចំនួន ដូចជា ការផ្ទេរមុខងារ និងការផ្ទេរធនធាន នោះទេ ។ នៅពេលចាប់ផ្តើមធ្វើការងារទាំងនេះ កំណែទម្រង់វិមជ្ឈការនឹងជៀសមិនផុតពីការជំទាស់ និងរារែកពីសំណាក់ស្ថាប័នថ្នាក់ជាតិមួយចំនួនឡើយ ។ បញ្ហាប្រឈមទាំងនេះនឹងក្លាយជាការសាកល្បងមួយ ទៅលើឆន្ទៈនយោបាយរបស់រាជរដ្ឋាភិបាលនៅក្នុងការងារវិមជ្ឈការហិរញ្ញវត្ថុ ។

## ១. សេចក្តីផ្តើម

វិមជ្ឈការជាកំណែទម្រង់ដ៏សំខាន់នៅកម្ពុជា ។ បន្ទាប់ពីការធ្វើកំណែទម្រង់នៅថ្នាក់ឃុំ/សង្កាត់ ដែលចាប់ផ្តើមតាំងពីឆ្នាំ២០០២ មក រាជរដ្ឋាភិបាលកម្ពុជាបានផ្តើម និងបន្តការងារវិមជ្ឈការនៅថ្នាក់រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ដោយរៀបចំឱ្យមានការបោះឆ្នោតអសាកលនៅខែឧសភា ឆ្នាំ២០០៩ ។ ដើម្បីបន្តការងារនេះ ទាំងនៅថ្នាក់រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងនៅថ្នាក់ឃុំ/សង្កាត់ មានការងារសំខាន់មួយដែលបាននិងកំពុងពិភាក្សា គឺការធ្វើវិមជ្ឈការហិរញ្ញវត្ថុ ។ ក្នុងអំឡុងពេលនៃការតាក់តែងកម្មវិធីជាតិ សម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិសម្រាប់រយៈពេល ១០ឆ្នាំ (ឆ្នាំ ២០១០ ដល់ ២០១៩) (ហៅកាត់ថា កម្មវិធីជាតិ) នៅឆ្នាំ២០០៨ និង ២០០៩ មន្ត្រីពីគ្រប់បណ្តាក្រសួង ស្ថាប័ននៅថ្នាក់ជាតិ នៅថ្នាក់ក្រោមជាតិ និងតំណាងដៃគូអភិវឌ្ឍន៍នានា បានចូលរួម ហើយយល់ស្របថា ដំណើរការវិមជ្ឈការនៅកម្ពុជា នឹងមិនមានន័យឡើយ ប្រសិនបើគ្មានការផ្ទេរមុខងារ សិទ្ធិអំណាច និងធនធានទៅឱ្យថ្នាក់ក្រោមជាតិ (RGC 2010) ។

ទាំងមុន ក្នុងពេល និងក្រោយពេលការតាក់តែងកម្មវិធីជាតិ ដោយមានការគាំទ្រពីសំណាក់ដៃគូអភិវឌ្ឍន៍នានា រាជរដ្ឋាភិបាល បានខិតខំតាក់តែងឯកសារក្របខ័ណ្ឌគតិយុត្តិ និងគោលនយោបាយសម្រាប់ការងារវិមជ្ឈការហិរញ្ញវត្ថុ ។ ក្រសួងមហាផ្ទៃ និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បានសហការគ្នារៀបចំសេចក្តីព្រាងច្បាប់ស្តីពីរបបហិរញ្ញវត្ថុ និងការគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ។ ចំណែកឯរតនាគារជាតិ ក៏បានចាប់ផ្តើមគិតគូរអំពីការគាំទ្រដែលត្រូវផ្តល់ដល់រដ្ឋបាលថ្នាក់ក្រោមជាតិ ពិសេសថ្នាក់ក្រុង ស្រុក ។ ក្រសួងជំនាញមួយចំនួន ក៏បានផ្តើមពិភាក្សាអំពីមុខងារដែលអាចត្រូវផ្ទេរឱ្យថ្នាក់ក្រោមជាតិ ក្នុងរយៈពេល ៥ ឬ ១០ឆ្នាំខាងមុខ ។

ដោយឆ្លុះបញ្ចាំងពីការខិតខំប្រឹងប្រែងទាំងអស់ខាងលើ អត្ថបទសិក្សាស្រាវជ្រាវនេះ ត្រូវបានតាក់តែងឡើងដើម្បីចែករំលែកព័ត៌មាន អំពីការងារវិមជ្ឈការហិរញ្ញវត្ថុដែលសម្រេចបានកន្លងមក ជំហានបន្ទាប់ដែលត្រូវធ្វើ និងបញ្ហាដែលអាចកើតមាននៅកម្ពុជា ។ ផ្នែកដំបូងនៃឯកសារនេះ នឹងបង្ហាញពីទ្រឹស្តីជាសាកលមួយចំនួនទាក់ទងនឹងវិមជ្ឈការហិរញ្ញវត្ថុ ហើយផ្នែកបន្តបន្ទាប់មក មានពិភាក្សាអំពីករណីនៃវិមជ្ឈការហិរញ្ញវត្ថុនៅកម្ពុជា ដោយផ្អែកតាមគោលនយោបាយ ឯកសារគតិយុត្តិ និងទិន្នន័យសំខាន់ៗរបស់រាជរដ្ឋាភិបាល និងការសិក្សាស្រាវជ្រាវនានាដែលបានធ្វើកន្លងមក ។

## ២. ទ្រឹស្តីសាកលស្តីពីវិមជ្ឈការហិរញ្ញវត្ថុ

សំណួរដំបូងដែលគួរចោទសួរគឺ ហេតុអ្វីបានជាប្រទេសមួយត្រូវធ្វើវិមជ្ឈការហិរញ្ញវត្ថុ? ឆ្លើយតបនឹងសំណួរនេះ ជាទ្រឹស្តី គេអះអាងថា ប្រទេសដែលធ្វើវិមជ្ឈការហិរញ្ញវត្ថុ នឹងអាចលើកកម្ពស់ប្រសិទ្ធភាពក្នុងការផ្តល់សេវាសាធារណៈ តាមរយៈការផ្តល់សិទ្ធិ និងធនធានសមស្របឱ្យទៅរដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិទាំងនេះ អាចឆ្លើយតបនឹងតម្រូវការរបស់ប្រជាពលរដ្ឋនៅមូលដ្ឋានបានល្អប្រសើរ (Bahl 2009) ។ ប្រសិទ្ធភាពក្នុងការផ្តល់សេវា គឺជាកត្តាសំខាន់ ប៉ុន្តែជាញឹកញាប់ ជំនាញការខាងវិមជ្ឈការ ច្រើនតែមិនបានពិភាក្សាដល់ចំណុចនេះទេ ដោយជំនាញការទាំងនោះច្រើនតែសង្កត់ធ្ងន់ទៅលើការធ្វើវិមជ្ឈការដើម្បីពង្រឹងលទ្ធិប្រជាធិបតេយ្យនៅមូលដ្ឋានទៅវិញ (Blunt and Turner 2007) ។ ដូច្នេះហើយទើបជំនាញការ និងម្ចាស់ជំនួយមួយចំនួន ច្រើនតែឱ្យតម្លៃទៅលើវិមជ្ឈការនយោបាយ ដែលតម្រូវឱ្យមានការបោះឆ្នោតនៅមូលដ្ឋាន និងមិនសូវគិតដល់វិមជ្ឈការផ្នែករដ្ឋបាល (ឬហៅថា វិសហមជ្ឈការ) ។

វិមជ្ឈការហិរញ្ញវត្ថុជាការងារសំខាន់មួយ ទាំងក្នុងវិមជ្ឈការនយោបាយ និងក្នុងវិសហមជ្ឈការ ។ តាមទ្រឹស្តី វិមជ្ឈការហិរញ្ញវត្ថុផ្តោតជាទូទៅលើទិដ្ឋភាពពីរគឺ ទី១ ទៅលើ ធាតុសំខាន់ៗនៃកំណែទម្រង់ និងទី២ ទៅលើ ដំណើរការដ៏ចាំបាច់ ដើម្បីជម្រុញឱ្យការងារនេះបោះជំហានទៅមុខ ។ ទិដ្ឋភាពទី១ មានលក្ខណៈបច្ចេកទេសច្រើន ចំណែកឯទិដ្ឋភាពទី២ មានលក្ខណៈជាការងារគ្រប់គ្រង និងនយោបាយច្រើន ។

## ២.១. ធាតុសំខាន់ៗនៃវិមជ្ឈការហិរញ្ញវត្ថុ

ធាតុសំខាន់ៗនៃវិមជ្ឈការហិរញ្ញវត្ថុ រួមមាន (១) ការផ្ទេរមុខងារ (២) ការផ្ទេរចំណូលមូលដ្ឋាន (៣)ការផ្ទេរមូលនិធិពីថ្នាក់ជាតិ និង (៤) ការអនុញ្ញាតឱ្យថ្នាក់ក្រោមជាតិមានសិទ្ធិខ្ចីបុល ។ ធាតុទី (៤) មិនមានចែងនៅក្នុងបរិបទរបស់កម្ពុជាទេ[1] ដូច្នេះក៏មិនបានលើកយកមកបកស្រាយដែរ ។ នៅផ្នែក ២.១.១ ខាងក្រោម មានពិភាក្សាអំពីការផ្ទេរមុខងារ ឯផ្នែក ២.១.២ មានពិភាក្សារួមគ្នាអំពី ការផ្ទេរចំណូលមូលដ្ឋាន និងការផ្ទេរមូលនិធិពីថ្នាក់ជាតិ ។

*២.១.១. ការផ្ទេរមុខងារ*

នៅក្នុងវិស័យសាធារណៈ គេឱ្យនិយមន័យ មុខងារ ថាជាបណ្តុំសកម្មភាពនៃប្រព័ន្ធការងារមួយរបស់រដ្ឋាភិបាល ហើយមុខងារនីមួយៗបានអនុវត្តឡើង ដើម្បីចូលរួមសម្រេចគោលបំណង និងលទ្ធផលរួមរបស់ប្រព័ន្ធការងារនោះ (GTZ 2009) ។ មុខងារ អាចសំដៅដល់ (១) សេវាសាធារណៈមួយ ឬវិស័យមួយ ដូចជាការអប់រំបឋម ការជួសជុល និងថែទាំផ្លូវលំជនបទ ឬសំដៅដល់ (២) ការងារជាក់លាក់ណាមួយក្នុងដំណើរការផលិតសេវា ដូចជា ការងារធ្វើផែនការ ថវិកា លទ្ធកម្ម អនុវត្តគម្រោង និងត្រួតពិនិត្យ និងវាយតម្លៃជាដើម (GTZ 2009) ។ ការយកមុខងារមួយមកបំបែកជាមុខងារតូចៗ ឬទៅជាការងារដែលត្រូវអនុវត្តផ្សេងៗពីគ្នា គេហៅថា ការបំបែកបណ្តុំមុខងារ (Flam 2008) ។

ការផ្ទេរមុខងារ អាចមានន័យថាជា (១) ដំណើរការផ្ទេរមុខងារឱ្យទៅថ្នាក់ក្រោមជាតិ ឬ (២) លទ្ធផលទទួលបានពីដំណើរការផ្ទេរនោះ ។ តាមលក្ខណៈបច្ចេកទេស មានគោលការណ៍មួយចំនួនដែលគេអាចប្រើ ដើម្បីសម្រេចថាតើមុខងារមួយណា គួរផ្ទេរទៅឱ្យថ្នាក់រដ្ឋបាលកម្រិតណា ។ គោលការណ៍ទី១ គឺការបង្វិតអ្នកផ្តល់សេវា ឱ្យទៅជិតអ្នកប្រើប្រាស់ ។ តាមគោលការណ៍នេះ មុខងារមួយ គួរតែផ្ទេរឱ្យទៅថ្នាក់រដ្ឋបាលដែលទាបជាងគេបំផុត ឱ្យតែថ្នាក់នោះមានលទ្ធភាពអាចអនុវត្ត ឬធានាការផ្តល់សេវាទាក់ទងនឹងមុខងារនោះប្រកបដោយប្រសិទ្ធភាព និងបានល្អប្រសើរ ។ គោលការណ៍ទី២ គឺវិមាត្រសេដ្ឋកិច្ច ។ គោលការណ៍នេះ ទាមទារឱ្យជ្រើសយកថ្នាក់រដ្ឋបាលណាដែលអាចអនុវត្តមុខងារ ដោយអស់ថ្លៃដើមក្នុងមួយឯកតាទាបបំផុត (GTZ 2009; Flam 2008) ។

មុខងារមួយអាចផ្ទេរបានតាមការធ្វើវិមជ្ឈការ វិសហមជ្ឈការ ឬប្រតិភូកម្ម ។ វិមជ្ឈការ មានន័យថា មុខងារត្រូវប្រគល់ទៅឱ្យថ្នាក់ក្រោមជាតិ ហើយរដ្ឋបាលថ្នាក់នោះត្រូវមានគណនេយ្យភាពលើការបំពេញមុខងារនោះ ។ វិសហមជ្ឈការ មានន័យថា ក្រសួង ឬស្ថាប័នថ្នាក់ជាតិ ធ្វើការផ្ទេរមុខងារទៅឱ្យមន្ទីរ ឬការិយាល័យខ្សែបណ្តោយរបស់ខ្លួន ។ ការធ្វើប្រតិភូកម្ម សំដៅដល់ករណីដែលរដ្ឋបាលថ្នាក់ក្រោមជាតិ ឬស្ថាប័នផ្សេងទៀត ដូចជាវិស័យឯកជន ឬអង្គការមិនមែនរដ្ឋាភិបាល ទទួលបំពេញមុខងារមួយក្នុងនាមជាភ្នាក់ងារតំណាងឱ្យក្រសួង ឬស្ថាប័នថ្នាក់ជាតិ ។ នៅពេលមុខងារមួយត្រូវបានធ្វើវិសហមជ្ឈការ ឬប្រតិភូកម្ម វាមិននាំឱ្យមានការផ្លាស់ប្តូរខ្សែបន្ទាត់គណនេយ្យភាពពីថ្នាក់ជាតិទៅថ្នាក់ក្រោមជាតិឡើយ (GTZ 2009) ។

គួរសំគាល់ដែរថា ពេលថ្នាក់ក្រោមជាតិត្រូវបានផ្ទេរមុខងារឱ្យ ថ្នាក់រដ្ឋបាលនោះមិនមែនដាច់ខាតត្រូវតែធ្វើការងារដោយផ្ទាល់ ដើម្បីបង្កើតជាសេវាដែលពាក់ព័ន្ធនឹងមុខងារនោះឡើយ ។ ផ្ទុយទៅវិញ ពួកគេអាចធ្វើប្រតិភូកម្មមុខងារនោះទៅឱ្យរដ្ឋបាលថ្នាក់ណាមួយផ្សេងទៀត ឬក៏ជួលឱ្យក្រុមហ៊ុន ឬអង្គការណាមួយជាអ្នកអនុវត្ត ។ ចំណុចសំខាន់ដែលគួរចងចាំគឺ ទោះជាមុខងារនោះត្រូវបានធ្វើប្រតិភូកម្ម ឬជួលឱ្យទៅភាគីមួយទៀតក៏ដោយ ក៏ថ្នាក់រដ្ឋបាលដែលបានទទួលមុខងារ នៅតែមានគណនេយ្យភាពដដែលក្នុងការធានាថា មុខងារនោះត្រូវបានអនុវត្តដោយត្រឹមត្រូវ (GTZ 2009) ។

ដំណើរការផ្ទេរមុខងារត្រូវការពេលវេលា និងមានលក្ខណៈស្មុគស្មាញ ។ ដំបូង គេត្រូវមានការគាំទ្រពីមន្ត្រីថ្នាក់នយោបាយ ទៅលើចក្ខុវិស័យមួយទាក់ទងនឹងតួនាទីចំបងៗដែលថ្នាក់រដ្ឋបាលនីមួយៗ គួរទទួលធ្វើក្នុងរយៈពេលមធ្យម និងរយៈពេលវែង ។ ទាំងមុខងារ និងទាំងដំណើរការផ្ទេរ ត្រូវតែមានការគាំទ្រ និងចងដោយច្បាប់ (ដូចជា ច្បាប់រៀបចំអង្គការច្បាប់តាមវិស័យ ឬច្បាប់ក្នុងការកសាងផែនការ និងថវិកាជាដើម) ។ បន្ទាប់ពីមានមូលដ្ឋានគ្រឹះផ្លូវច្បាប់ គេត្រូវចាប់ផ្តើមធ្វើការ

1 មាត្រា ២៥២ នៃច្បាប់អង្គការ

ពិភាក្សាដោយមានការចូលរួមពីក្រសួងជំនាញ ដៃគូអភិវឌ្ឍន៍ និងរដ្ឋបាលថ្នាក់ក្រោមជាតិ ។ នៅតាមក្រសួងជំនាញ ជាទូទៅត្រូវមានបង្កើតក្រុមការងារវិមជ្ឈការមួយ សម្រាប់ដឹកនាំ និងសម្របសម្រួលការពិភាក្សាផ្ទៃក្នុង និងសម្រាប់ត្រួតពិនិត្យលើការកំណត់ និងផ្ទេរមុខងារតាមវិស័យរៀងៗខ្លួន (GTZ 2009) ។

*២.១.២. ការផ្ទេរសិទ្ធិក្នុងការប្រមូលចំណូលមូលដ្ឋាន និងមូលនិធិផ្ទេរពីថ្នាក់ជាតិ*

គោលការណ៍ចំបងមួយនៅក្នុងវិមជ្ឈការហិរញ្ញវត្ថុគឺ ធនធានដើរតាមមុខងារ ។ ចំណុចនេះមានន័យថា បន្ទាប់ពីមុខងារមួយត្រូវបានផ្ទេរ គេត្រូវគិតពីប្រភេទ និងចំនួនធនធានដែលត្រូវផ្ទេរទៅជាមួយ ដើម្បីធានាឱ្យបានថា មុខងារនោះត្រូវបានបំពេញតាមការរំពឹងទុក ។ ធនធានរួមមាន ធនធានហិរញ្ញវត្ថុ បុគ្គលិក និងទ្រព្យសម្បត្តិ ។ អត្ថបទនេះ ផ្តោតលើធនធានហិរញ្ញវត្ថុដែលរដ្ឋបាលថ្នាក់ក្រោមជាតិ ទទួលបានពីចំណូលមូលដ្ឋាន (ទាំងពន្ធ និងមិនមែនពន្ធ) និងពីមូលនិធិផ្ទេរពីថ្នាក់ជាតិ (Smoke 2007; Bahl 1999) ។

ការអនុញ្ញាតឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិប្រមូលចំណូលផ្ទាល់ខ្លួន គឺជាធាតុមួយសំខាន់នៅក្នុងវិមជ្ឈការហិរញ្ញវត្ថុ ដោយសារមូលហេតុពីរ ។ ទី១ នៅពេលប្រជាជននៅមូលដ្ឋានបង់ពន្ធទៅឱ្យថ្នាក់ក្រោមជាតិ ពួកគេចាប់ផ្តើមយល់ពីបន្ទុកពន្ធដែលធ្លាក់មកលើខ្លួនគេ ដូច្នេះពួកគេនឹងចាប់ផ្តើមខ្វល់ខ្វាយទាមទារឱ្យរដ្ឋបាលទាំងនោះ ត្រូវមានគណនេយ្យភាពក្នុងការបម្រើខ្លួនវិញ ។ ទី២ នៅពេលខិតខំប្រឹងប្រែងដោយខ្លួនឯងដើម្បីប្រមូលចំណូល រដ្ឋបាលក្រោមជាតិក៏ចាប់ផ្តើមយល់ និងមានការប្រុងប្រយ័ត្ននៅពេលចំណាយ (Bahl 1999) ។

ប៉ុន្តែនៅក្នុងប្រទេសដែលទើបឆ្លងផុតពីសង្គ្រាម (ដូចជាប្រទេសកម្ពុជា) ដោយសារការគ្រប់គ្រងការប្រមូលពន្ធនៅទន់ខ្សោយ ថ្នាក់ក្រោមជាតិមានសិទ្ធិត្រឹមតែប្រមូលចំណូលពន្ធ និងមិនមែនពន្ធណា ដែលមិនតម្រូវឱ្យមានការគ្រប់គ្រងស្មុគស្មាញ ដូចជា ពន្ធលើមធ្យោបាយដឹកជញ្ជូន ពន្ធលើអចលនទ្រព្យ និងកម្រៃសេវា ។ នៅពេលប្រព័ន្ធគ្រប់គ្រងការប្រមូលពន្ធកាន់តែប្រសើរឡើង គេអាចអនុញ្ញាតឱ្យថ្នាក់ក្រោមជាតិមានសិទ្ធិច្រើនជាងមុន ដូចជា សិទ្ធិក្នុងការកំណត់អត្រាពន្ធក្នុងចន្លោះកំណត់មួយ (IMF 2004; Bahl 1999) ។

ជាទូទៅ នៅប្រទេសកំពុងអភិវឌ្ឍ និងទើបឆ្លងផុតពីសង្គ្រាម រដ្ឋបាលថ្នាក់ក្រោមជាតិនៅពឹងពាក់ខ្លាំងលើមូលនិធិផ្ទេរពីថ្នាក់ជាតិ ។ ក្នុងការផ្ទេរមូលនិធិនេះ ថ្នាក់ជាតិនៅតែជាអ្នកគ្រប់គ្រងការងារហិរញ្ញវត្ថុសាធារណៈ ប៉ុន្តែគេអនុញ្ញាតឱ្យថ្នាក់ក្រោមជាតិទទួលបានធនធានមួយចំណែកពីថវិកាជាតិ ។ មូលនិធិផ្ទេរមានច្រើនរូបភាព ដូចជា មូលនិធិដែលផ្ទេរផ្ទាល់ពីចំណូលជាតិតែម្តង ធនធានដែលចែករំលែកពីចំណូលពន្ធប្រភេទណាមួយ ឬជាចំណូលបង្គ្រប់ដែលថ្នាក់ជាតិបំពេញឱ្យទៅថ្នាក់ក្រោមជាតិ ។ មូលនិធិផ្ទេរត្រូវបានយកមកប្រើក្នុងគោលបំណងផ្សេងៗដូចជា ការធានាឱ្យមានសមភាពហិរញ្ញវត្ថុពីតំបន់មួយទៅតំបន់មួយ ការបង្កើនផលិតភាពក្នុងការប្រមូលពន្ធ (ឧទាហរណ៍ ថ្នាក់ជាតិអាចមានប្រសិទ្ធភាពជាងក្នុងការប្រមូលពន្ធណាមួយ បន្ទាប់មកទើបចែកចំណូលពន្ធនោះទៅឱ្យមូលដ្ឋានវិញ) (Bahl 2000) ។ល ។

គេមានការលំបាកក្នុងការកំណត់ថា តើថ្នាក់ជាតិគួរផ្តល់មូលនិធិផ្ទេរចំនួនប៉ុន្មានទៅឱ្យថ្នាក់ក្រោមជាតិ ។ ចម្លើយយ៉ាងសាមញ្ញគឺ ចំនួនមូលនិធិផ្ទេរ គួរតែស្មើនឹងបន្ទុកចំណាយរបស់ថ្នាក់ក្រោមជាតិ ដកនឹងចំណូលផ្ទាល់ដែលគេប្រមូលបាន ។ បន្ទុកចំណាយសរុបរបស់ថ្នាក់ក្រោមជាតិមួយអាចគណនាបាន ដោយដំបូងត្រូវកំណត់ថា តើមូលដ្ឋានរបស់គេត្រូវការសេវាជាអប្បបរមាអ្វីខ្លះ? ហើយដើម្បីបំពេញតម្រូវការទាំងនោះ គេនឹងត្រូវការធនធានប៉ុន្មាន? ការគណនាបែបនេះជាការលំបាក ព្រោះវាអាស្រ័យលើទំហំមុខងារដែលបានផ្ទេរទៅឱ្យរដ្ឋបាលនីមួយៗ ។

ដោយមានការលំបាកបែបនេះ ក្នុងការអនុវត្តជាក់ស្តែង គេច្រើនមើលលើចំណូលសរុបរបស់ថ្នាក់ជាតិ ហើយកំណត់ជាភាគរយដែលត្រូវចែកទៅថ្នាក់ក្រោមជាតិតែម្តង (Bahl 2000) ។ ការកំណត់ទំហំមូលនិធិផ្ទេរ ត្រូវគិតផងដែរពីការធ្វើឱ្យមានសមភាពរវាងតំបន់ ។ ជាទូទៅ តំបន់ដែលមានកម្រិតសេដ្ឋកិច្ចរីកចម្រើន អាចមានលទ្ធភាពប្រមូលចំណូលមូលដ្ឋានបានច្រើនជាងតំបន់ក្រីក្រ ។ រដ្ឋបាលថ្នាក់ជាតិ អាចប្រើមូលនិធិផ្ទេរ ដើម្បីធ្វើយ៉ាងណាឱ្យតំបន់នីមួយៗអាចមានលទ្ធភាពបំពេញតម្រូវការមូលដ្ឋានរបស់ខ្លួនបានប្រហាក់ប្រហែលគ្នា ។

មូលនិធិផ្ទេរពីថ្នាក់ជាតិត្រូវតែមានតម្លាភាព ទៀងទាត់ និងអាចរំពឹងបាន ដើម្បីអនុញ្ញាតឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ អាចធ្វើផែនការថវិការយៈពេលមធ្យមបាន ។វិធីមួយគឺ ប្រើរូបមន្តដើម្បីកំណត់មូលនិធិផ្ទេរ ដោយយកចំនួនប្រជាជន កម្រិតភាពក្រីក្រ និងកត្តាសមស្របផ្សេងទៀតជាមូលដ្ឋាន ។ មូលនិធិផ្ទេរ អាចមានភ្ជាប់លក្ខខណ្ឌ (មានន័យថា ត្រូវតែចំណាយលើសេវាជាក់លាក់ណាមួយ) និងគ្មានភ្ជាប់លក្ខខណ្ឌ (មានន័យថា ថ្នាក់ក្រោមជាតិអាចប្រើឆន្ទានុសិទ្ធិក្នុងការបែងចែក និងចំណាយ) (Smoke 2007) ។

រដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវប្រើប្រាស់ប្រកបដោយគណនេយ្យភាពនូវមូលនិធិដែលបានផ្ទេរ ។ ដើម្បីសម្រេចបានចំណុចនេះ គេត្រូវមានប្រព័ន្ធគ្រប់គ្រងចំណាយសាធារណៈមួយនៅថ្នាក់ក្រោមជាតិ ហើយប្រព័ន្ធនោះត្រូវតាក់តែងឡើងក្នុងក្របខណ្ឌនៃប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុទូទៅរបស់ជាតិ ។ ប្រព័ន្ធនេះតម្រូវឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ គោរពតាមរាល់វិធាននៃការគ្រប់គ្រងចំណាយសាធារណៈ និងត្រូវមានគណនេយ្យភាពចំពោះថ្នាក់ជាតិ លើការចំណាយមូលនិធិដែលផ្ទេរឱ្យ ។ ក្នុងពេលជាមួយគ្នា គេក៏ត្រូវអនុញ្ញាតឱ្យថ្នាក់ក្រោមជាតិ មានស្វ័យភាពក្នុងការគ្រប់គ្រង និងចាត់ចែងធនធានទាំងនោះ សំដៅបំពេញតម្រូវការ និងបង្ហាញពីគណនេយ្យភាពដល់ប្រជាពលរដ្ឋនៅក្នុងមូលដ្ឋានរបស់គេ (UNCDF 2005) ។

ហិរញ្ញប្បទានពីដៃគូអភិវឌ្ឍន៍ គឺជាប្រភពមួយយ៉ាងសំខាន់សម្រាប់មូលនិធិផ្ទេរ ។ ដៃគូអភិវឌ្ឍន៍ដែលធ្វើការគាំទ្រដល់វិមជ្ឈការក្នុងប្រទេសកំពុងអភិវឌ្ឍ បានបង្កើតឱ្យមានជាមូលនិធិសង្គម ឬមូលនិធិអភិវឌ្ឍន៍ (ឬឈ្មោះផ្សេងៗទៀត) ហើយមូលនិធិទាំងនោះត្រូវបានផ្ទេរឱ្យទៅថ្នាក់ក្រោមជាតិ សម្រាប់ចំណាយលើការអភិវឌ្ឍមូលដ្ឋាន ។ មូលនិធិទាំងនេះច្រើនផ្ទេរតាមប្រព័ន្ធដាច់ដោយឡែក និងខុសពីប្រព័ន្ធចំណាយសាធារណៈរបស់រដ្ឋាភិបាល ។ មូលហេតុនៃការប្រើប្រព័ន្ធថវិកាដាច់ដោយឡែកបែបនេះ គឺក្នុងបំណងការពារមិនឱ្យមានហានិភ័យលើទុនជំនួយ និងជៀសវាងការយឺតយ៉ាវក្នុងការបង្វែរសាច់ប្រាក់ទៅឱ្យថ្នាក់ក្រោមជាតិ ។ ប៉ុន្តែជាចំណុចអវិជ្ជមាន ការអនុវត្តបែបនេះនាំឱ្យមានកង្វះសមាហរណកម្ម និងការតម្រឹមរវាងសកម្មភាព និងអាទិភាពរបស់ដៃគូអភិវឌ្ឍន៍ ជាមួយនឹងរដ្ឋាភិបាល និងបន្ថយល្បឿននៃការកសាងសមត្ថភាពនៅថ្នាក់ក្រោមជាតិ ។

ទោះយ៉ាងនេះក្តី ថ្មីៗនេះ ដៃគូអភិវឌ្ឍន៍បានខិតខំធ្វើការតម្រឹម និងសមាហរណកម្មក្នុងការផ្តល់ជំនួយរបស់ខ្លួន ដោយបានផ្តល់ជាមូលនិធិសម្រាប់ទ្រទ្រង់ថវិកា (មានន័យថា គេផ្តល់ជំនួយទៅក្នុងថវិកាផ្ទាល់របស់រដ្ឋ) និងព្យាយាមកាត់បន្ថយការប្រើប្រាស់អង្គភាពគ្រប់គ្រងគម្រោងក្រៅប្រព័ន្ធរបស់រដ្ឋ ។ ការខិតខំទាំងនេះ នៅមានកម្រិត និងត្រូវការការតម្រឹម និងសមាហរណកម្មបន្ថែមទៀត ទៅក្នុងប្រព័ន្ធរបស់រដ្ឋ ។

## ២.២. ដំណើរការនៃការអនុវត្តវិមជ្ឈការហិរញ្ញវត្ថុ

ដើម្បីទទួលបានជោគជ័យ ការអនុវត្តវិមជ្ឈការហិរញ្ញវត្ថុតម្រូវឱ្យមានជាប្រព័ន្ធ និងដំណើរការច្បាស់លាស់ និងត្រូវឆ្លុះបញ្ចាំងពីកត្តានយោបាយផងដែរ មិនមែនត្រឹមតែកត្តាបច្ចេកទេសប៉ុណ្ណោះទេ ។ កង្វះខាតកត្តាទាំងនេះ ជាមូលហេតុធ្វើឱ្យវិមជ្ឈការនៅប្រទេសជាច្រើនត្រូវបរាជ័យ (Rondinelli 2007; Smoke 2007; Bahl 2009) ។ ជាចំបង វិមជ្ឈការហិរញ្ញវត្ថុត្រូវរៀបចំជាប្រព័ន្ធគ្រប់ជ្រុងជ្រោយមួយ ពោលគឺមានការផ្ទេរមុខងារ ការផ្ទេរសិទ្ធិអំណាច ការផ្ទេរធនធាន ការបង្កើតប្រព័ន្ធគ្រប់គ្រងចំណូល/ចំណាយនៅមូលដ្ឋាន ដែលជាយន្តការដើម្បីធានាឱ្យមានគណនេយ្យភាពទាំងទៅលើ (ថ្នាក់ជាតិ) និងទៅក្រោម (ប្រជាជន) (Bahl 1999) ។ តាមគំនិតនេះ ពាក្យថា គ្រប់ជ្រុងជ្រោយ សំដៅដល់ ការមានរាល់ធាតុ និងប្រព័ន្ធរងទាំងឡាយនៅក្នុងប្រព័ន្ធរួមមួយនៃការធ្វើវិមជ្ឈការហិរញ្ញវត្ថុ ។

ជាមួយគ្នានេះដែរ ភាពគ្រប់ជ្រុងជ្រោយ ក៏សំដៅដល់ការធានាឱ្យមានការចូលរួមពីសំណាក់ភាគីពាក់ព័ន្ធនានា និងការពិចារណាលើកត្តាទាំងឡាយដែលអាចប៉ះពាល់ដល់ដំណើរការកំណែទម្រង់ ។ កត្តាទាំងនោះរួមមាន កត្តានយោបាយ និងការសម្របសម្រួលរវាងក្រសួង/ស្ថាប័ននានាដែលពាក់ព័ន្ធនៅក្នុងដំណើរការកំណែទម្រង់ ។ ជាបទពិសោធន៍ មានក្រសួង/ស្ថាប័នជាច្រើនដែលត្រូវពាក់ព័ន្ធនឹងការងារវិមជ្ឈការហិរញ្ញវត្ថុ ។ ពួកគេអាចមានគំនិតផ្សេងៗគ្នា អំពីខ្លឹមសារ និង

ដំណើរការនៃកំណែទម្រង់ ហើយអាចជំទាស់នឹងការងារនេះទៀតផង ។ បើទោះជាគ្មានការជំទាស់ក៏ដោយ កំណែទម្រង់នៅតែអាចជួបការលំបាក ដោយសារសមត្ថភាពរបស់រដ្ឋបាល ទាំងនៅថ្នាក់ជាតិ និងក្រោមជាតិ នៅមានកម្រិត និងត្រូវមានការកសាងសមត្ថភាពនេះដោយសន្សឹមៗ (Smoke 2007) ។

ការសម្របសម្រួលមិនបានល្អរវាងដៃគូអភិវឌ្ឍន៍ (ដូចជាការបង្កើតឱ្យមានអង្គភាពគ្រប់គ្រងគម្រោងច្រើនក្នុងពេលតែមួយជាដើម) បានធ្វើឱ្យការសម្របសម្រួលការអនុវត្តកំណែទម្រង់វិមជ្ឈការហិរញ្ញវត្ថុ កាន់តែជួបឧបសគ្គ ។ ជាទូទៅដៃគូអភិវឌ្ឍន៍បានគាំទ្រកម្មវិធីកំណែទម្រង់ផ្សេងៗគ្នា (ដូចជាកំណែទម្រង់រដ្ឋបាល កំណែទម្រង់ប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ កំណែទម្រង់តាមវិស័យ) តែមិនបានគិតគូរពីការខិតខំធ្វើឱ្យកម្មវិធីទាំងនោះ មានភាពស៊ីសង្វាក់គ្នាឡើយ ។ កង្វះខាតនេះ នាំឱ្យយឺតយ៉ាវដល់វិមជ្ឈការហិរញ្ញវត្ថុ ដែលជាកំណែទម្រង់អន្តរវិស័យ ប្រទាក់ក្រឡាជាមួយនឹងកំណែទម្រង់ផ្សេងទៀត (Rondinelli 2007) ។

កត្តានយោបាយក៏មានសារៈសំខាន់ដែរ ក្នុងនោះរួមមាន ឆន្ទៈនយោបាយរបស់ថ្នាក់ដឹកនាំ ទំនាក់ទំនងរវាងមន្ត្រីនយោបាយ និងមន្ត្រីបច្ចេកទេស និងកិច្ចសហការ (ឬការប្រកួតប្រជែង) រវាងក្រសួងមហាផ្ទៃ ក្រសួងហិរញ្ញវត្ថុ ក្រសួងជំនាញ និងរដ្ឋបាលក្រោមជាតិ ។ល។ បញ្ហានយោបាយ ក៏កើតមានផងដែរនៅថ្នាក់ក្រោមជាតិ រវាងក្រុមប្រឹក្សា និងមន្ត្រីក្នុងនីតិប្រតិបត្តិ (Smoke 2007; Bahl 1999) ។ កត្តានយោបាយមួយទៀតដែលគេច្រើនតែមើលរំលង គឺតួនាទីរបស់គណបក្សនយោបាយ ។ ទាំងគណបក្សកាន់អំណាច និងគណបក្សប្រឆាំង សុទ្ធតែមានឱកាសទាញយកប្រយោជន៍អំពី វិមជ្ឈការ អាស្រ័យទៅតាមសមត្ថភាពនិងភាពប៉ិនប្រសព្វរបស់ពួកគេ។ហេតុដូច្នេះពួកគេ(ពិសេសគណបក្សកាន់អំណាច)នឹងព្យាយាមប្រើឥទ្ធិពលរបស់ខ្លួនទៅក្នុងការតាក់តែង និងអនុវត្តកំណែទម្រង់ ក្នុងរូបភាពមួយដែលអាចចំណេញប្រយោជន៍របស់ខ្លួន (Manor 1999) ។

វិមជ្ឈការហិរញ្ញវត្ថុជាដំណើរការយូរអង្វែង ហេតុនេះត្រូវមានចក្ខុវិស័យរយៈពេលវែង និងមធ្យម និងត្រូវកំណត់នូវជំហានយុទ្ធសាស្ត្រដែលត្រូវបោះជាបន្តបន្ទាប់ ។ សំណួរអំពីការជ្រើសរើសជំហានក្នុងការធ្វើកំណែទម្រង់នេះ អាចចោទសួរបានច្រើនយ៉ាង និងលើច្រើនទិដ្ឋភាព ។ ឧទាហរណ៍ ជំនាញការខ្លះផ្តោតលើដំណើរការដែលត្រូវធ្វើ ដូចជាថា ត្រូវចាប់ផ្តើមពីការបង្កើតគោលច្បាប់ បន្ទាប់មកការអនុវត្ត បន្ទាប់មកទៀតត្រូវមានការត្រួតពិនិត្យ និងវាយតម្លៃ ។ល។ ខ្លះទៀតផ្តោតលើទិដ្ឋភាពបច្ចេកទេស ដោយលើកឡើងថា ក្នុងដំណាក់កាលដំបូង គួរឱ្យថ្នាក់ក្រោមជាតិពឹងផ្អែកលើមូលនិធិផ្ទេរពីថ្នាក់ជាតិសិនទម្រាំសមត្ថភាពប្រមូលចំណូលនៅមូលដ្ឋានបានរឹងមាំ ។ ខ្លះទៀតផ្តោតលើការជម្រុញឱ្យមានទាំងវិមជ្ឈការ និងវិសហមជ្ឈការកើតឡើងក្នុងពេលព្រមគ្នា (Smoke 2007) ។ ខ្លះទៀតផ្តោតលើថា តើថ្នាក់ណាគួរចាប់ផ្តើមមុន តើចាប់ផ្តើមនៅថ្នាក់ឃុំមុន បន្ទាប់មកនៅថ្នាក់ខេត្ត ស្រុក ឬយ៉ាងណា ។ល។ សំណួរទាំងនេះ អាស្រ័យតាមស្ថានភាពប្រទេសនីមួយៗ ។ ឧទាហរណ៍ នៅប្រទេសវៀតណាម វិសហមជ្ឈការនៅថ្នាក់ខេត្ត បានបោះជំហានយ៉ាងសម្បើមសំដៅជម្រុញការផ្តល់សេវានៅថ្នាក់តំបន់របស់គេ (Martinez-Vazquez 2004) ឯប្រទេសយូហ្គិនដាវិញ បានចាប់ផ្តើមពីវិមជ្ឈការ និងការបោះឆ្នោតនៅថ្នាក់មូលដ្ឋាន (Ndegwa and Levy 2003) ។

ជាសង្ខេប តាមទ្រឹស្តី និងបទពិសោធន៍ជាសាកល យើងទទួលបានគំនិតថា វិមជ្ឈការហិរញ្ញវត្ថុតម្រូវឱ្យមានធាតុសំខាន់ៗមួយចំនួន រួមមាន៖ ការផ្ទេរមុខងារ ការផ្ទេរសិទ្ធិក្នុងការប្រមូលចំណូល និងការផ្ទេរមូលនិធិពីថ្នាក់ជាតិ ។ លើសពីនេះទៀត កំណែទម្រង់ ក៏តម្រូវឱ្យមានការគិតគូរពីដំណើរការអនុវត្តផងដែរ ជាពិសេសទៅលើភាពគ្រប់ជ្រុងជ្រោយ ការសម្របសម្រួល ការបោះជំហានជាយុទ្ធសាស្ត្រ និងកត្តានយោបាយមួយចំនួន ។ តាមបទពិសោធន៍ ការឈានពីការធ្វើការងារដែលបែកខ្ញែកពីគ្នា មកជាការធ្វើការងារប្រកបដោយកិច្ចសហការ និងស៊ីសង្វាក់ ជាការលំបាក ។ កម្ពុជាគួរយកចិត្តទុកដាក់ត្រៀមខ្លួនជម្នះបញ្ហានេះ ។

## ៣. កំណែទម្រង់វិមជ្ឈការនៅកម្ពុជា៖ បរិបទ និងការខាសម្រេចបាន

### *៣.១. បរិបទ*

កំណែទម្រង់វិមជ្ឈការនៅកម្ពុជា បាននិងកំពុងប្រព្រឹត្តទៅក្នុងបរិបទនៃប្រទេសមួយដែលទើបងើបពីសង្គ្រាម ។ ទី១ ក្នុងការតាក់តែងកំណែទម្រង់នេះ រាជរដ្ឋាភិបាលបានគិតគូរជាចំបងនូវការធានាឱ្យបានស្ថិរភាពនយោបាយ (RGC 2008c) ។ ទី២ ដោយសារសង្គ្រាមរ៉ាំរ៉ៃតាំងពីឆ្នាំ១៩៧៩ មក កម្ពុជាមិនមានឱកាសសមរម្យក្នុងការកសាង និងពង្រឹងប្រព័ន្ធរដ្ឋបាលរបស់រដ្ឋទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ។ ការបែងចែក និងផ្ទេរមុខងារ ក៏មិនទាន់បានធ្វើពេញលេញ និងត្រឹមត្រូវ សូម្បីតែនៅថ្នាក់ជាតិ កុំថាឡើយដល់ទៅថ្នាក់ក្រោមជាតិ ។

ចំណូលជាតិ និងការបែងចែកថវិកាជាតិ នៅមានកម្រិត ទោះបីមានការកើនឡើងនៅក្នុងវិស័យសង្គមកិច្ច និងសេដ្ឋកិច្ចក្តី (RGC 2008c) ។ ក្នុងពេលជាមួយគ្នា កម្ពុជានៅពឹងពាក់ខ្លាំងលើជំនួយបរទេស ដែលត្រូវបានផ្តល់ឱ្យជាមូលនិធិសម្រាប់ការផ្តល់សេវាចាំបាច់នៅមូលដ្ឋាន និងសម្រាប់គាំទ្រការរៀនបណ្តើរ ធ្វើបណ្តើរ តាមរយៈអតីតកម្មវិធីសិលា មុននឹងឈានដល់ការអនុវត្តវិមជ្ឈការជាដំបូងនៅឆ្នាំ២០០២ (Rudengren and Ojendal 2002) ។ ប៉ុន្តែការបញ្ចៀសមិនប្រើប្រព័ន្ធរដ្ឋក្នុងការផ្តល់ជំនួយ បានរួមចំណែកដល់ភាពយឺតយ៉ាវក្នុងការធ្វើកំណែទម្រង់រដ្ឋដែលកំពុងតែទន់ខ្សោយ (Taliercio 2008) ។

សង្គ្រាម ក៏បានធ្វើឱ្យប្រជាជនកម្ពុជា មានការបាក់ស្បាត ខ្លាចរអារ និងបាត់បង់ទំនុកចិត្តលើរដ្ឋអំណាចផងដែរ (Oosterom 2009) ។ ភាពខ្លាចរអារ និងការមិនសូវអើពើទាំងនេះ មួយផ្នែកក៏ជាលទ្ធផលនៃវប្បធម៌អ្នកតូចខ្លាចអ្នកធំនៅកម្ពុជាដែលមានជាយូរយារមកហើយ (Blunt and Turner 2005; Chandler 2008) ។ នេះមានន័យថា នៅពេលធ្វើវិមជ្ឈការ មិនមែនមានតែរដ្ឋទេដែលត្រូវផ្លាស់ប្តូរបែបបទធ្វើការងារ ។ ប្រជាជនខ្លួនឯងក៏ត្រូវចាប់ផ្តើមផ្លាស់ប្តូរផ្នត់គំនិតមួយចំនួន ជាពិសេសទាក់ទងនឹងទំនាក់ទំនងជាមួយរដ្ឋអំណាច និងកិច្ចការសាធារណៈក្នុងមូលដ្ឋានរបស់ខ្លួន ។

ភាពក្រីក្រជាកត្តាមួយទៀតដែលមិនអាចមើលរំលងបាននៅទីជនបទកម្ពុជា ។ ទោះកំណើនសេដ្ឋកិច្ចកន្លងមក បានជួយកាត់បន្ថយអត្រាភាពក្រីក្រជារួម គម្លាតនៃការកាត់បន្ថយនោះនៅមានច្រើន ពីតំបន់មួយទៅតំបន់មួយ ។ នៅតំបន់ខ្លះ ឱកាសក្នុងការរកចំណូល ការទទួលបានសេវាអប់រំ និងសុខាភិបាលមានច្រើន តែនៅតំបន់ខ្លះទៀត លទ្ធភាពទាំងនេះនៅមានតិចតួច ។ គម្លាតគ្នានេះ កាន់តែធំទៅទៀត បើប្រៀបធៀបរវាងតំបន់ទីប្រជុំជន និងជនបទ ដែលជាមូលហេតុមួយនាំឱ្យមានការធ្វើចំណាកស្រុកយ៉ាងគំហុក (UNCDF 2010) ។ ដើម្បីដោះស្រាយគម្លាតតាមតំបន់បែបនេះ គេត្រូវរៀបចំឱ្យមានទាំងយុទ្ធសាស្ត្រអភិវឌ្ឍន៍រួមមួយរបស់ជាតិផង និងយុទ្ធសាស្ត្រដែលតម្រូវតាមមូលដ្ឋាននិងតំបន់នីមួយៗផង ។

បន្ថែមពីលើនេះទៀត នៅពេលស្ថានភាពនយោបាយ និងសន្តិសុខ បានរីកចម្រើនឡើង ការងារអភិបាលកិច្ចនៅជួបឧបសគ្គច្រើន រីឯការងារកំណែទម្រង់មួយចំនួន ដូចជា កំណែទម្រង់ប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ កំណែទម្រង់រដ្ឋបាលសាធារណៈ និងកំណែទម្រង់តាមវិស័យមួយចំនួនទៀត នៅមានភាពយឺតយ៉ាវ (RGC 2008c) ។ ដៃគូអភិវឌ្ឍន៍ជាច្រើនបានជួយគាំទ្រដល់ការងារទាំងនេះ ទាំងលើថវិកា និងបច្ចេកទេស ។ ប៉ុន្តែការជួយជ្រោមជ្រែងទាំងនេះនៅខ្វះភាពស៊ីសង្វាក់ ហើយនៅមិនទាន់បានបន្សុីជាមួយនឹងកំណែទម្រង់វិមជ្ឈការនៅឡើយ ។

បើពិនិត្យលើស្ថានភាពនយោបាយទូទៅវិញ យើងសម្គាល់ឃើញថា វិមជ្ឈការនៅកម្ពុជា បានប្រព្រឹត្តទៅក្នុងរយៈពេលមួយ ដែលគណបក្សកាន់អំណាចបច្ចុប្បន្ន កាន់តែមានភាពគ្របដណ្តប់ខ្លាំងឡើងៗ ពីមួយអាណត្តិទៅមួយអាណត្តិ ។ ការលើកយកចំណុចនេះមកបង្ហាញ មិនមានចេតនាធ្វើការវែកញែកថា តើភាពគ្រប់ដណ្តប់នេះល្អឬមិនល្អ សម្រាប់កំណែទម្រង់នោះទេ ប៉ុន្តែមានចេតនាចង្អុលបង្ហាញថា នេះជាបរិបទនយោបាយសំខាន់មួយ ដែលគួរធ្វើការពិចារណា ។ បន្ថែមពីលើនេះទៀត គណបក្សកាន់អំណាចបានឧបត្ថម្ភជាច្រើន ទៅលើការសាងសង់ហេដ្ឋារចនាសម្ព័ន្ធនៅជនបទ ដែលមានភាពស្រដៀងគ្នានឹងការខិតខំរបស់រដ្ឋបាលមូលដ្ឋានកន្លងមកដែរ ។

### ៣.២. ភាពរីកចម្រើននៃកំណែទម្រង់ក្នុងពេលកន្លងមក

ផ្នែកនេះនឹងបង្ហាញពីភាពរីកចម្រើនទៅមុខ នៅក្នុងការងារកំណែទម្រង់កន្លងមក ទាំងលើការខិតខំបង្កើតឱ្យមានធាតុសំខាន់ៗនៃវិមជ្ឈការហិរញ្ញវត្ថុ និងទាំងលើដំណើរការនៃការអនុវត្តកំណែទម្រង់ ។ យើងនឹងមើលទាំងលើថ្នាក់ឃុំ/សង្កាត់ និងថ្នាក់ខេត្ត ក្រុង ស្រុក ។

*៣.២.១. នៅថ្នាក់ឃុំ/សង្កាត់*

ការបោះឆ្នោតឃុំ/សង្កាត់តាំងពីឆ្នាំ២០០២ បាននាំមកនូវសមិទ្ធផលធំៗចំនួនពីរ ។ ទី១ ដំណើរការនេះបានជួយឱ្យមានស្ថិរភាពនយោបាយនៅថ្នាក់មូលដ្ឋាន ដោយនាំឱ្យអតីតភាគីជម្លោះបានចូលរួមក្នុងការបោះឆ្នោត ហើយរៀនសូត្រធ្វើការជាមួយគ្នានៅក្នុងក្រុមប្រឹក្សា សំដៅបម្រើផលប្រយោជន៍របស់ប្រជាជនក្នុងមូលដ្ឋានរបស់ខ្លួន (Rusten, Kim et al. 2004; Meerkerk, Hean et al. 2008) ។ កំណែទម្រង់នេះក៏បានលើកកម្ពស់ការយល់ដឹង និងទំនុកចិត្តរវាងប្រជាជន និងក្រុមប្រឹក្សា បើទោះជាមានកង្វល់ខ្លះៗទាក់ទងនឹងការបង់ថ្លៃសេវាក្រៅផ្លូវការនៅតាមតំបន់មួយចំនួនក្តី[2] ។

ទី២ ក្រុមប្រឹក្សាមានសមាជិកពី ៥ ទៅ ១១នាក់ និងមានស្មៀនម្នាក់ ។ ក្រុមប្រឹក្សានេះបានទទួលភារកិច្ចធ្វើជាតំណាងរដ្ឋ និងត្រូវឆ្លើយតបនឹងតម្រូវការមូលដ្ឋាន រាប់តាំងពីការងារសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ ការអភិវឌ្ឍសង្គម និងសេដ្ឋកិច្ច ការការពារបរិស្ថាន (RGC 2001) ។ល។ ម្យ៉ាងទៀត មានការផ្តួចផ្តើម និងលើកកម្ពស់ការអភិវឌ្ឍដោយមានការចូលរួមពីប្រជាជន និងការបង្កើតមូលនិធិឃុំ/សង្កាត់ ។ នៅឆ្នាំ២០០៣ មូលនិធិឃុំ/សង្កាត់នេះ ត្រូវបានកំណត់ស្មើនឹង ២% នៃចំណូលចរន្តរបស់ជាតិ និងកើនដល់ ២,៥% នៅឆ្នាំ២០០៤ ២,៧% នៅឆ្នាំ២០០៨ ២,៧៥% នៅឆ្នាំ២០០៩ និង ២,៨% នៅឆ្នាំ២០១០ (STF 2008; RGC 2010c) ។

ទោះជាយ៉ាងនេះក្តី យើងសង្កេតឃើញថាភារកិច្ចដែលមានចែងបច្ចុប្បន្នសម្រាប់ថ្នាក់ឃុំ/សង្កាត់ នៅមានភាពទូលំទូលាយ និងខ្វះភាពជាក់លាក់ ។ ក្រុមប្រឹក្សាឃុំ/ សង្កាត់ភាគច្រើនបានលើកឡើងថា រាជរដ្ឋាភិបាលសព្វថ្ងៃហាក់ស្នើសុំឱ្យពួកគេទទួលរ៉ាប់រងលើភារកិច្ចគ្រប់យ៉ាងនៅមូលដ្ឋាន ប៉ុន្តែផ្តល់សិទ្ធិអំណាច និងធនធានតិចតួចដល់ពួកគេ (Pak 2010) ។ ការលើកឡើងបែបនេះ ដោយសារមូលនិធិឃុំ/សង្កាត់បច្ចុប្បន្ន ទោះបីជាមានភាគរយកើនឡើងជាលំដាប់ក្តី តែបើគិតជាចំនួនជាក់ស្តែង គឺនៅមានកម្រិតស្តួចស្តើង ។ នៅឆ្នាំ២០០៣ មូលនិធិនេះមានចំនួន ៤៣,៨ពាន់លានរៀល (ប្រហែល 0,២៤% នៃ ផសស) និងប្រមាណ ៨៩,៦៣ពាន់លានរៀលនៅឆ្នាំ២០០៧ (ប្រហែល 0,២៦% នៃ ផសស) ។ ជារៀងរាល់ឆ្នាំ គ្រប់ឃុំ/សង្កាត់ត្រូវរៀបចំកសាងផែនការអភិវឌ្ឍន៍ដោយមានការចូលរួមពីប្រជាជន ប៉ុន្តែដោយសារធនធាន និងការគាំទ្រមានកម្រិត ក្នុងគម្រោងអាទិភាព ៣ គឺជាមធ្យមមានតែ ១ ប៉ុណ្ណោះ ដែលទទួលបានការគាំទ្រ (NCDD 2010b) ។

ទាក់ទងនឹងខ្ទង់ចំណាយរបស់មូលនិធិឃុំ/សង្កាត់ស្ថិតិកន្លងមកបង្ហាញថាក្រៅពីចំណាយរដ្ឋបាលមួយភាគធំនៃចំណាយអភិវឌ្ឍន៍បានផ្តោតលើហេដ្ឋារចនាសម្ព័ន្ធ ក្នុងនោះប្រហែល ៦៥% ចំណាយទៅលើបណ្តាញគមនាគមន៍ជនបទ ១៧% លើធារាសាស្ត្រ និង ៦% លើការផ្គត់ផ្គង់ទឹកស្អាតនៅជនបទ ។ ស្ថិតិនេះបង្ហាញថា មានមូលនិធិឃុំ/សង្កាត់មួយចំណែកតូចបំផុតដែលយកទៅចំណាយលើសេវាវិស័យសង្គមកិច្ច ដូចជាអប់រំ សុខាភិបាល និងយេនឌ័រ ។ គួរកត់សម្គាល់ថា សេវាវិស័យសង្គមកិច្ចទាំងនេះ ភាគច្រើនផ្តល់ឡើងដោយមន្ទីរ ការិយាល័យជំនាញ និងអង្គការមិនមែនរដ្ឋាភិបាល ដែលបានចូលរួមក្នុងសមាហរណកម្មថ្នាក់ស្រុក (NCDD 2010b) ។

បើទោះជាមានមុខងារមិនច្បាស់លាស់ និងមានធនធានតិចតួច ក្រុមប្រឹក្សាឃុំ/សង្កាត់ភាគច្រើនបានខិតខំបំពេញការងារអភិវឌ្ឍន៍ជាច្រើន រាប់ទាំងការងារសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ ការការពារធនធានធម្មជាតិ ការដោះស្រាយជម្លោះ

---

2 ទោះបីជាយ៉ាងនេះក្តី ការបង់សេវាក្រៅផ្លូវការមានចំនួនតិចតួច ។ តាមការប៉ាន់ស្មាន ការបង់សេវាក្រៅផ្លូវការទៅកាន់ថ្នាក់ឃុំ មានចំនួនប្រហែល ៥ ទៅ ៦លានដុល្លារដែលស្មើនឹង ១០% នៃចំនួនប្រាក់ប្រចាំឆ្នាំក្រៅផ្លូវការបង់ដោយប្រជាជននៅគ្រប់កម្រិត ដែលគេប៉ាន់ស្មានថា មានចំនួនរហូតដល់ ៦៦លានដុល្លារនៅឆ្នាំ២០០៥ (EIC 2006) ។

ការគ្រប់គ្រងទីផ្សារជនបទ ការគ្រប់គ្រងកាកសំណល់ និងសម្រាម ការចូលរួមក្នុងការងាររបស់សាលារៀន និងមណ្ឌលសុខភាព (តាមរយៈគណៈកម្មាធិការស្ត្រី និងកុមារ) និងការងារកសិកម្ម (Pak 2010) ។

ប៉ុន្តែប្រសិទ្ធភាព និងភាពសស្រាក់សស្រាំក្នុងការអនុវត្តការងារទាំងនេះ មានកម្រិតខុសៗគ្នាតាមឃុំ/សង្កាត់នីមួយៗ អាស្រ័យទៅតាមកត្តាមួយចំនួន ដូចជា ភាពឧស្សាហ៍ព្យាយាម និងភាពជាមេដឹកនាំរបស់មេឃុំ ឬចៅសង្កាត់ ការជួយគាំទ្រពីសំណាក់អង្គការមិនមែនរដ្ឋាភិបាល សប្បុរសជន និងគណបក្សនយោបាយ និងភាពរលូននៅក្នុងទំនាក់ទំនងរវាងក្រុមប្រឹក្សា និងស្ថាប័នជំនាញ ដែលចុះទៅធ្វើការងារនៅតាមមូលដ្ឋាននីមួយៗ ។ ទោះជាមានភាពខុសគ្នាតាមតំបន់បែបនេះក៏ដោយ យើងសង្កេតឃើញថា ក្រុមប្រឹក្សាភាគច្រើនបានខិតខំទាំងលំបាកដើម្បីបម្រើដល់មូលដ្ឋានរបស់ខ្លួន ។ ដោយសារហេតុផលនេះ ឃុំ/សង្កាត់ភាគច្រើនបានសំណូមពរឱ្យមានការកំណត់ជាក់លាក់អំពីមុខងាររបស់ពួកគេ និងស្នើឱ្យមានការផ្ទេរសិទ្ធិ និងអំណាចសមស្របនឹងមុខងារទាំងនោះ (Pak 2010) ។

*៣.២.២. នៅថ្នាក់ខេត្ត និងស្រុក*

មុនការបោះឆ្នោតអសាកលនាខែឧសភា ឆ្នាំ២០០៩ កំណែទម្រង់នៅថ្នាក់ខេត្ត និងស្រុក បានកើតឡើងក្នុងរូបភាពតូច ។ នៅមុនពេលមានក្រុមប្រឹក្សា ថ្នាក់ខេត្តត្រូវបានចាត់ទុកជាខ្សែបណ្តោយរដ្ឋបាលរបស់ថ្នាក់ជាតិ ឯពាក្យថា អាជ្ញាធរខេត្ត គឺសំដៅលើសាលាខេត្តដឹកនាំដោយអភិបាលខេត្តដែលត្រូវបានតែងតាំងដោយថ្នាក់ជាតិ។អំណាចរបស់សាលាខេត្តពេលនោះនៅមានកម្រិត ហើយពេលខ្លះត្រូវបានចាត់ទុកគ្រាន់តែជាមន្ទីរមួយរបស់ក្រសួងមហាផ្ទៃ ។ នៅថ្នាក់ស្រុកឯណោះវិញ សាលាស្រុកមិនត្រូវបានគេចាត់ជាថ្នាក់ថវិកាមួយឡើយ ពោលគឺគ្មានថវិកាផ្ទាល់ខ្លួន ដោយត្រូវពឹងផ្អែកលើថវិការបស់សាលាខេត្ត (RGC 1998; Ojendal and Kim 2008) ។

យោងតាមច្បាប់ឆ្នាំ១៩៩៨ ស្តីពីរបបហិរញ្ញវត្ថុ និងការគ្រប់គ្រងទ្រព្យសម្បត្តិរាជធានី ខេត្ត ក្រុង សាលាខេត្តមានការទទួលខុសត្រូវលើមុខចំណាយមួយចំនួន ដូចជា ចំណាយលើការជួសជុលអាគារ និងសម្ភារៈបរិក្ខារ ប្រាក់បៀវត្សរ៍បុគ្គលិក ការបំភ្លឺទីសាធារណៈ ការប្រមូលសម្រាម អនាម័យសាធារណៈ សួនច្បារសាធារណៈ ។ល។ សាលាខេត្តពេលនោះមានសិទ្ធិប្រមូលចំណូលពន្ធ និងមិនមែនពន្ធ និងទទួលបានការឧបត្ថម្ភធនបន្ថែមពីថ្នាក់ជាតិ (RGC 1998) ។ ចំណូលពន្ធ មានដូចជា ពន្ធលើដីមិនប្រើប្រាស់ សត្តឃាត មធ្យោបាយធ្វើដំណើរ ពន្ធប្រថាប់ត្រា ពន្ធបំភ្លឺសាធារណៈ (ដែលប្រមូលបានលើផលិតផលបារី និងស្រា) (RGC 1998) ។ល។ ចំណូលមិនមែនពន្ធដែលគេអាចទទួលបានរួមមានពីការផ្គត់ផ្គង់អគ្គិសនី ទឹកប្រើប្រាស់ និងគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ ។ល។ ចំណូលផ្ទាល់របស់ខេត្ត (ទាំងពន្ធ និងមិនមែនពន្ធ) ធៀបនឹងចំណូលពន្ធ និងមិនមែនពន្ធសរុបថ្នាក់ជាតិ មានទំហំស្មើនឹង ២,៨% នៅឆ្នាំ២០០២ និងកើនដល់ ៦,៩% នៅឆ្នាំ២០០៨[3] ។

បន្ថែមពីលើថវិកាខាងលើ មានសកម្មភាពកំណែទម្រង់ និងខ្ទង់ថវិកាផ្សេងទៀតដែលគេបានបង្កើតឡើង ដើម្បីគាំទ្រដល់ថ្នាក់ខេត្ត និងស្រុក ជាពិសេសធ្វើឱ្យថ្នាក់ទាំងពីរនេះ អាចជួយគាំទ្រដល់ថ្នាក់មូលដ្ឋានបានក្នុងកម្រិតណាមួយ ។ ខ្ទង់ថវិកាសំខាន់ៗមានពីរគឺ មូលនិធិវិនិយោគខេត្ត (ហៅកាត់ PIF) និងមូលនិធិផ្តួចផ្តើមថ្នាក់ស្រុក (ហៅកាត់ DIF) ។នៅឆ្នាំ២០០៩ PIF មានចំនួន ២,២៤លានដុល្លារ ភាគច្រើនយកទៅចំណាយលើគម្រោងដែលមន្ទីរជំនាញស្នើឡើង ហើយដែលឆ្លើយតបនឹងតម្រូវការរបស់ឃុំ/សង្កាត់ ។ នៅឆ្នាំដដែល DIF មានចំនួន ០,៧៨លានដុល្លារ គ្របដណ្តប់លើស្រុក និងខណ្ឌ ចំនួន ១០៦ ដោយនីមួយៗទទួលបានប្រមាណ ៣ម៉ឺនដុល្លារ សម្រាប់ចំណាយជាពិសេសលើគម្រោងអន្តរឃុំ ។ តំណាងមកពីក្រុមប្រឹក្សាក៏មានសម្លេងនៅក្នុងការសម្រេចលើចំណាយ DIF ផងដែរ (PSDD 2009) ។

---

3 ច្បាប់ថវិកាឆ្នាំ២០០២ និង ២០០៨ លេខ IV

នៅថ្នាក់ខេត្ត ស្ថាប័នដែលទទួលខុសត្រូវលើការគ្រប់គ្រងមូលនិធិទាំងនេះ (រួមទាំង មូលនិធិឃុំ/សង្កាត់ផង) គឺគណៈកម្មាធិការអភិវឌ្ឍន៍ជនបទ និងគណៈកម្មាធិការប្រតិបត្តិខេត្ត/ក្រុង ដែលត្រូវបង្កើតឡើងតាំងពីឆ្នាំ២០០២ ក្រោមរចនាសម្ព័ន្ធរបស់កម្មវិធីសិលា[4] ។ នៅចុងឆ្នាំ២០០៨ គណៈកម្មាធិការនេះ ត្រូវបានផ្ទេរមកក្រោមការដឹកនាំរបស់ គ.ជ.អ.ប វិញ[5] ។

បន្ទាប់ពីការបោះឆ្នោតនៅខែឧសភា ឆ្នាំ២០០៩ ច្បាប់រៀបចំអង្គការបានចែងថា ក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ នឹងមានថវិកាផ្ទាល់ខ្លួន ។ ប៉ុន្តែដោយសារច្បាប់ថ្មីស្តីពីរបបហិរញ្ញវត្ថុ និងការគ្រប់គ្រងទ្រព្យសម្បត្តិ រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ មិនទាន់ត្រូវបានអនុម័ត ច្បាប់ឆ្នាំ១៩៩៨ នឹងបន្តមានសុពលភាពលើការគ្រប់គ្រងថវិការបស់ក្រុមប្រឹក្សាថ្មីនេះ ។ ក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ នឹងបន្តទទួលថវិការបស់ខ្លួន តាមរយៈក្រុមប្រឹក្សាខេត្ត ខុសតែម៉្យាងត្រង់ថា នៅក្នុងប្រព័ន្ធថ្មី ថវិការបស់ក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ នីមួយៗ នឹងត្រូវចែងច្បាស់នៅក្នុងថវិការបស់រាជធានី និងខេត្តនីមួយៗ[6] ។

ក្រៅពីសាលាខេត្ត និងសាលាស្រុក ក៏មានមន្ទីរ និងការិយាល័យជំនាញជាច្រើន ដែលដំណើរការនៅតាមថ្នាក់ខេត្ត និងស្រុកដែរ ។ មន្ទីរជំនាញទទួលបានថវិកាសម្រាប់បន្ទុកចំណាយចរន្ត ឯការចំណាយមូលធន មន្ទីរត្រូវធ្វើការស្នើសុំដោយលើកជាគម្រោងអភិវឌ្ឍន៍ប្រចាំឆ្នាំ ឱ្យទៅក្រសួងសាមីរបស់ខ្លួន (Pak and Craig 2008) ។ មន្ទីរទាំងនេះ ខ្លះមានសិទ្ធិច្រើន (ពោលគឺមានវិសហមជ្ឈការច្រើន) ខ្លះទៀតមានសិទ្ធិតិចតួច ទាក់ទងនឹងកិច្ចការថវិកា ។ វិស័យអប់រំ និងសុខាភិបាល ជាវិស័យដែលមានវិសហមជ្ឈការខ្លាំងជាងគេ បន្ទាប់មកគឺ វិស័យកសិកម្ម និងអភិវឌ្ឍន៍ជនបទ ។ ចំណែកឯវិស័យមួយចំនួនទៀត ដូចជាសាធារណការ និងធនធានទឹក វិសហមជ្ឈការថវិកាមានតិចតួចជាងគេ (Pak and Craig 2008) ។

ជាសង្ខេប វិមជ្ឈការតាំងពីឆ្នាំ២០០២ កន្លងមក បាននាំមកនូវភាពរីកចម្រើនគួរឱ្យកត់សម្គាល់ ប៉ុន្តែមានភាពខ្វះខាតលើទិដ្ឋភាពជាច្រើនដែរ ជាពិសេសលើការងារថវិកា ។ ជាក់ស្តែង ប្រសិនបើយើងសង្កេតមើលចំណែកនៃថវិកា ដែលត្រូវបានបែងចែកទៅឱ្យថ្នាក់ក្រោមជាតិក្នុងឆ្នាំ២០០៨ ២០០៩ និង ២០១០ យើងឃើញថា ក្នុងឆ្នាំទាំងបីនេះ ទាំងថវិការបស់ឃុំ/សង្កាត់ ថវិកាខេត្ត ក្រុង និងថវិកាមន្ទីរជំនាញ សរុបទាំងអស់មានចំនួនប្រមាណ ២០% ប៉ុណ្ណោះ បើធៀបនឹងថវិកាសរុបរបស់ជាតិទាំងមូល (សូមមើលតារាង ១) ។

តារាង ១៖ ការបែងចែកថវិកាតាមថ្នាក់រដ្ឋបាល យោងតាមច្បាប់ថវិកាជាតិឆ្នាំ២០០៨ ២០០៩ និង ២០១០
(គិតជាលានរៀល)

| *ខ្ទង់ចំណាយ* | *២០០៨* | *២០០៩* | *២០១០* |
|---|---|---|---|
| (១) ចំណាយជាតិសរុប | ៥.៥៧៣.៣៨៣ | ៧.២៥៩.៥៦៦ | ៨.២៩៩.៧៧៣ |
| (២) ចំណាយរបស់ខេត្ត | ២០៦.៧៧៦ | ៣៥៦.៩៥០ | ៣២៦.៣៧០ |
| (៣) មូលនិធិឃុំ/សង្កាត់ដែលផ្ទេរពីថ្នាក់ជាតិ | ៩១.០០០ | ១០៧.០០០ | ១៤២.៤២៤ |
| (២+៣)/១ | *៥,៣៤%* | *៦,៣៩%* | *៥,៦៥%* |
| (៤)ថវិការបស់មន្ទីរជំនាញ | ៨៥៧.៦៤៥ | ១.០៥៩.១២២ | ១.២០៩.៤៣១ |
| (២+៣+៤)/១ | *២០,៧៣%* | *២០,៩៨%* | *២០,២២%* |

---

4 ប្រកាសរបស់សិលា (Seila) លេខ ២៩២ ខ.ជ.ន.ស ថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០២

5 ប្រកាសរបស់ គ.ជ.ប លេខ ៦៨ ថ្ងៃទី០៨ ខែកញ្ញា ឆ្នាំ២០០៨

6 សុន្ទរកថារបស់ឯកឧត្តម គាត ឈន់ នៅក្នុងសិក្ខាសាលាជាតិឆ្នាំ២០១០ ស្តីពីការរៀបចំផែនការសកម្មភាព និងថវិការបស់គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ - គ.ជ.អ.ប (NCDD) ភ្នំពេញ ថ្ងៃទី៦-៧ តុលា ២០០៩ ។

*៣.២.៣. វិមជ្ឈការ និងការផ្តល់សេវានៅមូលដ្ឋាន៖ បញ្ហាប្រឈមក្នុងការសម្របសម្រួល*

នៅកម្ពុជា វិមជ្ឈការគឺជាកំណែទម្រង់ស្នូលសម្រាប់លើកកម្ពស់ការផ្តល់សេវានៅមូលដ្ឋាន ។ ប៉ុន្តែដោយសារកន្លងមក ការធ្វើវិមជ្ឈការហិរញ្ញវត្ថុនៅមានកម្រិត ថវិកាមួយភាគធំដែលចាំបាច់សម្រាប់ការផ្តល់សេវាសាធារណៈ នៅបន្តគ្រប់គ្រងដោយស្ថាប័នថ្នាក់ជាតិ ។ ចំណុចគួរសម្គាល់គឺថា មានតួអង្គច្រើនទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ធ្វើការងារផ្តល់សេវា និងអភិវឌ្ឍន៍មូលដ្ឋាន ប៉ុន្តែតួអង្គទាំងនេះខ្វះកិច្ចសហការ និងការសម្របសម្រួលជាមួយគ្នា ។ កង្វះខាតនេះកើតឡើងនៅលើកម្រិតបីផ្សេងគ្នា គឺកម្រិតគោលនយោបាយ កម្រិតនៃការអនុវត្តគោលនយោបាយ និងកម្រិតនៃការអនុវត្តកម្មវិធីកំណែទម្រង់ ។

នៅកម្រិតគោលនយោបាយ យើងសង្កេតឃើញថា នៅកម្ពុជាសព្វថ្ងៃ មិនទាន់មានជាគោលនយោបាយរួម និងស៊ីសង្វាក់មួយទាក់ទងនឹងការអភិវឌ្ឍជនបទនៅឡើយទេ (UNCDF 2010) ។ ពេលខ្លះ វិមជ្ឈការត្រូវបានចាត់ទុកថាជាគោលនយោបាយសម្រាប់ការអភិវឌ្ឍជនបទ ហើយក្នុងនោះរដ្ឋបាលថ្នាក់ក្រោមជាតិមានតួនាទីយ៉ាងសំខាន់ (RGC 2005) ។ ប៉ុន្តែវិស័យជំនាញនានាក៏មានគោលនយោបាយរបស់ខ្លួនដែលចូលរួមចំណែកទាំងផ្ទាល់ និងប្រយោលដល់ការអភិវឌ្ឍជនបទដែរ ។ ឧទាហរណ៍ យើងមានគោលនយោបាយ សម្រាប់វិស័យអប់រំ សុខាភិបាល កសិកម្ម និងអភិវឌ្ឍន៍ជនបទ (MOEYS 2005a; TWG on Agriculture and Water 2007; MoH 2008) ។ល។ អ្វីដែលគួរយកត់សម្គាល់គឺ គោលនយោបាយទាំងនេះខ្វះភាពស៊ីសង្វាក់ជាមួយគ្នា ដោយសារគោលនយោបាយនីមួយៗ ច្រើនមើលការងារអភិវឌ្ឍន៍ក្នុងក្របខ័ណ្ឌវិស័យរៀងៗខ្លួន ហើយមិនបានគិតដល់ទំនាក់ទំនងអន្តរវិស័យ ។

ចំណុចមួយទៀត គឺគោលនយោបាយទាំងនេះមិនបានបែងចែករវាងទីប្រជុំជន និងជនបទ ដែលមានកម្រិតអភិវឌ្ឍន៍ និងតម្រូវការសេវាសាធារណៈខុសគ្នា ។ ការសិក្សាកន្លងមកបានបង្ហាញថា នៅជនបទ តម្រូវការសំខាន់របស់ឃុំគឺ ប្រព័ន្ធធារាសាស្ត្រ ផ្លូវថ្នល់ សេវាអប់រំបឋមសិក្សា និងសេវាសុខភាពបឋម ។ ឯសង្កាត់នៅតាមទីប្រជុំជន ទោះមានតម្រូវការស្រដៀងនឹងឃុំនៅជនបទខ្លះក្តី តែភាគច្រើនមានបញ្ហាចោទ ទឹកលិចតាមផ្លូវ ប្រព័ន្ធលូបាក់បែក កង្វះខាតប្រព័ន្ធទឹកស្អាត កង្វះខាតប្រព័ន្ធអគ្គិសនី និងការគ្រប់គ្រងសម្រាម និងកាកសំណល់តាមទីសាធារណៈមិនបានល្អ (Pak 2010) ។

ការសិក្សាផ្សេងទៀត បានបង្ហាញថា ការធ្វើចំណាត់ថ្នាក់ចំនួនប្រជាជនតាមជនបទ និងទីប្រជុំជននៅកម្ពុជា អាចមិនឆ្លុះបញ្ចាំងពីតថភាពជាក់ស្តែង (UNCDF 2010) ។ ការធ្វើចំណាត់ថ្នាក់បែបនេះ គឺធ្វើតាមរយៈការធ្វើជំរឿនដែលមានគុណភាពកាន់តែប្រសើរឡើងពីមួយលើកទៅមួយលើក ។ ប៉ុន្តែការធ្វើចំណាត់ថ្នាក់នេះកន្លងមក ត្រូវបានធ្វើឡើងដោយឈរលើទិន្នន័យដែលរៀបចំមិនទាន់បានស្រួលបួល និងមិនទាន់មានសង្គតិភាពពេញលេញ (UNCDF 2010) ។ មួយវិញទៀត និយមន័យដែលកម្ពុជាកំពុងប្រើសម្រាប់ធ្វើចំណាត់ថ្នាក់ជនបទ ឬទីប្រជុំជន មានភាពខុសគ្នាពីនិយមន័យដែលគេប្រើជាអន្តរជាតិ ។

ការសិក្សាបានបង្ហាញថា បើគេប្រើនិយមន័យដូចមាននៅប្រទេសជឿនលឿន សម្រាប់ប្រទេសកម្ពុជា គេឃើញថាប្រជាជនកម្ពុជាប្រមាណ ៤៨% អាចចាត់ថា កំពុងរស់នៅក្នុងទីប្រជុំជន (UNCDF 2010) ។ តួលេខនេះខុសគ្នាច្រើនពីទិន្នន័យរបស់ជាតិដែលកំណត់ថា ប្រជាជនកម្ពុជាប្រមាណតែ ១០% ប៉ុណ្ណោះ ដែលកំពុងរស់នៅក្នុងទីប្រជុំជន ។ អត្ថបទនេះសូមមិនធ្វើការវាយតម្លៃថា និយមន័យមួយណាសុក្រិតជាងនិយមន័យមួយណាឡើយ ប៉ុន្តែគម្លាតយ៉ាងច្រើនដូចបានបង្ហាញខាងលើ អាចជាហេតុផលមួយដែលជម្រុញឱ្យយើងគួរពិនិត្យពិចារណាឡើងវិញលើនិយមន័យ និងវិធីសាស្ត្រដែលកំពុងប្រើបច្ចុប្បន្ន ។

នៅកម្រិតនៃការអនុវត្ត គោលនយោបាយនីមួយៗត្រូវបានបម្លែងទៅជាសកម្មភាព និងលទ្ធផល តាមរយៈប្រព័ន្ធនៃការគ្រប់គ្រងផ្សេងៗគ្នា ។ មូលនិធិឃុំ/សង្កាត់ PIF និង DIF ព្រមទាំងគម្រោងអភិវឌ្ឍន៍នានា ដែលទទួលបានការសម្របសម្រួលតាមរយៈ គ.ជ.អ.ប ត្រូវបានអនុវត្តតាមប្រព័ន្ធគ្រប់គ្រងចំណាយដោយឡែកមួយ ដែលក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បានបង្កើតឡើង និងទទួលស្គាល់ (STF 2008) ។ គួរសម្គាល់ថា ប្រព័ន្ធនេះមានលក្ខណៈខុសពីប្រព័ន្ធគ្រប់គ្រងថវិកាទូទៅរបស់ជាតិ ។ ឧទាហរណ៍ មូលនិធិរបស់ខេត្ត និងស្រុក កន្លងមកត្រូវបានបង្វិលនៅក្រៅប្រព័ន្ធរតនាគារ (PSDD 2009) ។ ឯមូលនិធិឃុំ/សង្កាត់ ទោះជាបង្វិលតាមរតនាគារ ប៉ុន្តែបែបបទផ្សេងៗក្នុងការកសាងផែនការបែងចែកចំណាយ ការដេញថ្លៃ និងការវាយតម្លៃគម្រោងជាដើម មានលក្ខណៈខុសពីប្រព័ន្ធដែលប្រើសម្រាប់ការគ្រប់គ្រងចំណាយសាធារណៈទូទៅរបស់រដ្ឋ ។

ចំណែកក្រសួង និងមន្ទីរជំនាញវិញ ពួកគេប្រើប្រាស់ចំណាយចរន្តដែលខ្លួនទទួលបាន ដោយប្រើប្រព័ន្ធគ្រប់គ្រងចំណាយទូទៅរបស់ជាតិ ។ ប្រព័ន្ធនេះអនុលោមតាមច្បាប់គ្រប់គ្រងហិរញ្ញវត្ថុច្បាប់ឆ្នាំ២០០៨ និងបទបញ្ញត្តិនានាដែលចេញដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។ ប្រព័ន្ធនេះផ្តល់សិទ្ធិអំណាចច្រើនដល់ក្រសួង និងមន្ទីរ សេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងរតនាគារជាតិ និងខេត្ត ហើយមានលក្ខណៈរឹងត្អឹងនៅក្នុងការអនុវត្តថវិកា ។ នៅថ្នាក់ខេត្ត ទោះជាអភិបាលខេត្តមានសិទ្ធិដើរតួជាអាណាប័កផ្ទេរសិទ្ធិ តែជាក់ស្តែងគាត់មានអំណាចតិចតួចលើការអនុវត្តថវិការបស់មន្ទីរ (Pak and Craig 2008; RGC 2008f) ។

ប្រព័ន្ធថវិការបស់កម្ពុជា ចែកដាច់គ្នារវាងចំណាយចរន្ត និងចំណាយមូលធន ។ ចំណាយចរន្តត្រូវបានបែងចែកតាមចំណាត់ថ្នាក់សេដ្ឋកិច្ច ដូចជាប្រាក់បៀវត្សរ៍ ការចំណាយរដ្ឋបាល អន្តរាគមន៍សង្គមកិច្ច និងសេដ្ឋកិច្ច ។ល។ ឯចំណាយមូលធនវិញ ត្រូវបានបែងចែក និងបង្ហាញក្នុងរូបភាពជាគម្រោងនៅក្នុងកម្មវិធីវិនិយោគសាធារណៈបីឆ្នាំរំកិល ។ កម្មវិធីនេះរៀបចំដោយក្រសួងជំនាញ និងយកមកចងក្រងដោយក្រសួងផែនការ ។ កម្មវិធីវិនិយោគសាធារណៈសម្រាប់ឆ្នាំ២០១០-២០១២ មាន ៥៣៦គម្រោង (RGC 2009) ភាគច្រើនទទួលបានហិរញ្ញប្បទានពីដៃគូអភិវឌ្ឍន៍ ។ នៅក្នុងឆ្នាំ២០១០ ក្នុងចំណាយមូលធនចំនួន ៣.១២១ពាន់លានដុល្លារ ប្រមាណ ៦៥% បានមកពីដៃគូអភិវឌ្ឍន៍ ។

ដោយសារជំនួយដៃគូអភិវឌ្ឍន៍មានទំហំធំធេងបែបនេះ កាលណាគេពិភាក្សាអំពីការងារអភិវឌ្ឍន៍មូលដ្ឋាន គេមិនអាចមិននិយាយពីការងារគ្រប់គ្រងជំនួយបរទេសបានឡើយ ។ ត្រង់នេះ គួរកត់សម្គាល់ថា ដៃគូអភិវឌ្ឍន៍នៅកម្ពុជាបានផ្តល់ជំនួយទាំងលើការងារវិមជ្ឈការ និងទាំងលើការងារតាមវិស័យជំនាញ ។ ក្នុងការងារវិមជ្ឈការ មានគម្រោងខ្លះជួយលើការលើកកម្ពស់ការផ្តល់សេវា ខ្លះទៀតជួយលើការពង្រឹងសិទ្ធិ និងការចូលរួមរបស់ប្រជាជន ។ ពិតណាស់ គម្រោងទាំងនេះមានគុណសម្បត្តិបំពេញឱ្យគ្នាទៅវិញទៅមក ប៉ុន្តែការអនុវត្តគម្រោងទាំងនេះនៅខ្វះការសម្របសម្រួលរវាងគ្នា ដោយសារថ្នាក់ដឹកនាំគម្រោងនីមួយៗច្រើនផ្តោតលើតែការងាររបស់ខ្លួន ដោយមិនបានខិតខំធ្វើការបន្សីជាមួយនឹងគម្រោងផ្សេងទៀត ។

ក្នុងការងារអភិវឌ្ឍន៍តាមវិស័យ គម្រោងភាគច្រើននៅប្រើទស្សនៈជាអ្នកបច្ចេកទេសតាមជំនាញ ហើយមើលការផ្តល់សេវាតែក្នុងក្របខ័ណ្ឌវិស័យរបស់ខ្លួន ។ ក្នុងវិស័យខ្លះ ពួកគេបានផ្តោតលើ វិសហមជ្ឈការតាមខ្សែបណ្តោយរបស់ខ្លួន ប៉ុន្តែនៅមិនទាន់បានគិតពីវិមជ្ឈការ និងតួនាទីនាពេលអនាគតរបស់ក្រុមប្រឹក្សា (Pak and Craig 2008) ។ បញ្ហានេះមួយផ្នែកបណ្តាលមកពីកង្វះខាតការសម្របសម្រួលរវាងគម្រោងដែលជួយលើវិមជ្ឈការ និងគម្រោងដែលជួយតាមវិស័យ ។ ពេលខ្លះទៀត សូម្បីតែរវាងគម្រោងនៅក្រោមដៃគូអភិវឌ្ឍន៍តែមួយ ក៏នៅមានភាពខ្វះខាតការសម្របសម្រួលដែរ ។

កង្វះខាតការសម្របសម្រួលរវាងគម្រោងអភិវឌ្ឍន៍ បណ្តាលជាចំបងមកពីគម្រោងទាំងនោះ ត្រូវបានបង្កើតឡើង និងអនុវត្តតាមអង្គភាពជាច្រើនរាប់រយដាច់ដោយឡែកពីគ្នា ហើយដំណើរការនៅក្រៅប្រព័ន្ធរដ្ឋបាលទូទៅរបស់ជាតិ ។ ឧទាហរណ៍ នៅឆ្នាំ២០០៧ មានអង្គភាពអនុវត្តគម្រោងជំនួយរហូតដល់ ១២១ ហើយចំនួននេះគេមិនរំពឹងថា បានថយចុះទេក្នុងរយៈពេល ២ឆ្នាំកន្លងទៅនេះ ។ ក្នុងឆ្នាំដដែល មានជំនួយប្រមាណតែ ១២% ដែលត្រូវបានផ្តល់ឱ្យតាមប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុទូទៅរបស់រាជរដ្ឋាភិបាល (ធៀបនឹងឆ្នាំ២០០៥ ដែលមានប្រមាណ ១០%) និងជំនួយប្រមាណ ១៦% ដែលបានប្រើប្រព័ន្ធលទ្ធកម្មរបស់ជាតិ (ធៀបនឹងឆ្នាំ២០០៥ ដែលមានប្រមាណ ៦%) (RGC 2008b; VBNK and RBMG 2010; RGC 2010a) ។

ជាចុងក្រោយ នៅក្នុងកម្រិតកម្មវិធីកំណែទម្រង់ ការងារវិមជ្ឈការ (ដែលជាទូទៅគេមើលឃើញថា ជាកំណែទម្រង់ដឹកនាំដោយក្រសួងមហាផ្ទៃ) នៅខ្វះសង្គតិភាពជាមួយនឹងកំណែទម្រង់ប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (ដែលគេមើលឃើញថា ដឹកនាំដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ) ។ កំណែទម្រង់ប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈកន្លងមកបានធ្វើការគិតគូរតិចតួច ទាក់ទងនឹងការបញ្ចូលកម្មវិធីវិមជ្ឈការហិរញ្ញវត្ថុ ទៅក្នុងក្របខ័ណ្ឌរបស់ខ្លួន ។ គិតត្រឹមចុងឆ្នាំ២០០៩ កំណែទម្រង់ប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ មានបញ្ចូលសកម្មភាពទី២៧ ដែលស្តីពីវិមជ្ឈការហិរញ្ញវត្ថុ ប៉ុន្តែសកម្មភាពនេះ នៅមិនទាន់មានភាពលម្អិត និងជាក់លាក់សម្រាប់យកទៅអនុវត្តនៅឡើយ (RGC 2008d) ។ ឧទាហរណ៍ សកម្មភាពនោះនៅតែកំណត់ថា ការងារវិមជ្ឈការហិរញ្ញវត្ថុប៉ះពាល់តែលើការងាររបស់នាយកដ្ឋានហិរញ្ញវត្ថុមូលដ្ឋានប៉ុណ្ណោះ ហើយមិន

បានប្រមើលមើលពីផលប៉ះពាល់របស់វាទៅលើការងាររបស់នាយកដ្ឋានផ្សេងទៀត ដូចជាខាងពន្ធដារ ចំណូលមិនមែនពន្ធ ថវិកា លទ្ធកម្ម និងរតនាគារ ។ល។ តាមពិតទៅ ការងារទាំងអស់នេះនឹងត្រូវប៉ះពាល់ នៅពេលមានការផ្ទេរមុខងារ និងធនធាន បន្ថែមឱ្យទៅថ្នាក់ក្រោមជាតិ[7] ។

## ៤. ផែនការសម្រាប់ដំណាក់កាលបន្ទាប់នៃកំណែទម្រង់

### *៤.១. ទិសដៅគោលនយោបាយសម្រាប់រយៈពេលវែង*

ទោះការងារវិមជ្ឈការកន្លងមក ផ្តោតជាសំខាន់លើថ្នាក់ឃុំ/សង្កាត់ក៏ដោយ ក៏រាជរដ្ឋាភិបាលបានទទួលស្គាល់តាំងពីឆ្នាំ២០០៥ មកថា កំណែទម្រង់នេះក៏ត្រូវអនុវត្តផងដែរ នៅថ្នាក់ស្រុក និងខេត្ត ។ ក្របខ័ណ្ឌយុទ្ធសាស្ត្រីពីវិមជ្ឈការ និងវិសហមជ្ឈការឆ្នាំ២០០៥ បានប្រមើលថា នឹងត្រូវបង្កើតឱ្យមានរដ្ឋបាលឯកភាពនៅថ្នាក់ទាំងពីរនេះ (RGC 2005) ។ នៅឆ្នាំ២០០៨ ច្បាប់រៀបចំអង្គការត្រូវបានអនុម័ត និងផ្តល់ជាមូលដ្ឋានគ្រឹះផ្លូវច្បាប់សម្រាប់ការបោះឆ្នោតជាអសាកល ដើម្បីជ្រើសរើសក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខ័ណ្ឌ កាលពីខែឧសភា ឆ្នាំ២០០៩ ។

យោងតាមច្បាប់រៀបចំអង្គការ ក្រុមប្រឹក្សាទាំងនេះមានសិទ្ធិអំណាចធ្វើសេចក្តីសម្រេចខាងបញ្ញត្តិ និងសេចក្តីសម្រេចខាងប្រតិបត្តិ[8] ។ ពួកគេត្រូវមានភារកិច្ចចាត់ចែងការងារទាក់ទងនឹងការរៀបចំទទួលមុខងារ និងធនធានថ្មីៗ[9] ។ ច្បាប់រៀបចំអង្គការ ក៏បានចែងពីការតែងតាំងនូវគណៈអភិបាលដែលដឹកនាំដោយអភិបាល និងមានភារកិច្ចត្រូវអនុវត្តរាល់ការសម្រេច និងថវិកាដែលអនុម័តដោយក្រុមប្រឹក្សា[10] ។

នៅខែឧសភា ឆ្នាំ២០១០ រាជរដ្ឋាភិបាលបានអនុម័តកម្មវិធីជាតិរយៈពេល ១០ឆ្នាំ បន្ទាប់ពីមានការពិភាក្សា និងពិគ្រោះយោបល់ជាច្រើនលើកច្រើនសារ ។ កម្មវិធីជាតិនេះមានសមាសធាតុកម្មវិធីចំនួន ៥៖ (១) ការរៀបចំស្ថាប័នថ្នាក់ក្រោមជាតិ (២) ប្រព័ន្ធគ្រប់គ្រង និងអភិវឌ្ឍន៍ធនធានមនុស្ស (៣) ការផ្ទេរមុខងារ (៤) ប្រព័ន្ធគ្រប់គ្រងថវិកា ហិរញ្ញវត្ថុ និងទ្រព្យសម្បត្តិរបស់រដ្ឋបាលក្រោមជាតិ និង (៥) ស្ថាប័នគាំទ្រកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ (RGC 2010) ។ សមាសធាតុកម្មវិធីទី(៣) និង ទី(៤) មើលទៅហាក់ទាក់ទងខ្លាំងជាងគេជាមួយនឹងវិមជ្ឈការហិរញ្ញវត្ថុ ។ ប៉ុន្តែតាមពិត សមាសធាតុទាំង ៥នេះ មានការពាក់ព័ន្ធគ្នា ហើយសុទ្ធតែមានសារៈសំខាន់សម្រាប់ការបោះជំហានទៅមុខនៃវិមជ្ឈការហិរញ្ញវត្ថុ (RC 2010) ។

ទាំងក្របខ័ណ្ឌយុទ្ធសាស្ត្រ ទាំងច្បាប់រៀបចំអង្គការ និងកម្មវិធីជាតិ បានផ្តល់ជាទិសដៅជាក់លាក់សម្រាប់កំណែទម្រង់ក្នុងរយៈពេលវែងនៅកម្ពុជា ។ ទី១ ឯកសារទាំងនេះបញ្ជាក់ច្បាស់ថា កំណែទម្រង់នាពេលអនាគត នឹងមិនគ្រាន់តែជាការបង្កើតជាមូលនិធិតូចមួយសម្រាប់ផ្តល់ដល់ថ្នាក់ក្រោមជាតិប៉ុណ្ណោះទេ ប៉ុន្តែនឹងពាក់ព័ន្ធផងដែរដល់ការផ្ទេរមុខងារ និងការផ្ទេរធនធានតាមលក្ខណៈជាប្រព័ន្ធ និងជាជំហានៗពីក្រសួងទៅឱ្យបណ្តារដ្ឋបាលនៅថ្នាក់ក្រោមជាតិ[11] ។ ទី២ កំណែទម្រង់នឹងសង្កត់ធ្ងន់លើសារៈសំខាន់នៃគណនេយ្យភាពទៅថ្នាក់ក្រោម និងការគោរពដល់សិទ្ធិអំណាចរបស់ក្រុមប្រឹក្សាឃុំ/សង្កាត់ ក្នុងនាមពួកគេជាស្ថាប័នទទួលបានការបោះឆ្នោតដោយផ្ទាល់ពីប្រជាជន[12] ។ ទី៣ នៅក្នុងក្របខ័ណ្ឌនៃរដ្ឋឯកភាពមួយ បណ្តារដ្ឋបាលថ្នាក់ក្រោមជាតិ នឹងមានស្វ័យភាពច្រើនឡើងក្នុងការគ្រប់គ្រង ចាត់ចែងមុខងារ និងការទទួលបានធនធានផ្ទាល់របស់ខ្លួន[13] ។ ទាំងអស់នេះគឺជាទស្សនវិស័យមួយប្រកបដោយភាពក្លាហាន បើធៀបនឹងស្ថានភាពបច្ចុប្បន្នដែលមានលក្ខណៈមជ្ឈការខ្លាំងនៅឡើយ ។

---

7 កិច្ចប្រជុំក្រុមការងារ MEF D&D ថ្ងៃទី០៩ និងថ្ងៃទី១៣ ខែមករា ឆ្នាំ២០០៩

8 មាត្រា ៣០ នៃច្បាប់រៀបចំអង្គការ

9 មាត្រា ៤២ និង ៤៣ នៃច្បាប់រៀបចំអង្គការ

10 ជំពូកទី៣ ផ្នែកទី៥ នៃច្បាប់រៀបចំអង្គការ

11 ជំពូកទី៥ ផ្នែកទី២ នៃច្បាប់រៀបចំអង្គការ

12 មាត្រា ៩៨ នៃច្បាប់រៀបចំអង្គការ

13 ជំពូកទី៥ ផ្នែកទី៦ នៃច្បាប់រៀបចំអង្គការ

ទោះមានទស្សនវិស័យប្រកបដោយមហិច្ឆតាយ៉ាងនេះក្តី រាជរដ្ឋាភិបាលក៏បានធ្វើការប្រយ័ត្នប្រយែង និងទទួលស្គាល់រាល់បញ្ហាប្រឈមដែលនឹងកើតមានឡើងនៅពេលអនុវត្តកំណែទម្រង់ ។ ឧទាហរណ៍ នៅពេលលើកឡើងអំពីរដ្ឋបាលឯកភាព គោលនយោបាយបច្ចុប្បន្នបានសង្កត់ធ្ងន់លើ កង្វះខាតការសម្របសម្រួលនាពេលសព្វថ្ងៃ និងជម្រុញឱ្យបង្កើត និងពង្រឹងតួនាទីរបស់គណៈកម្មាធិការសម្របសម្រួលបច្ចេកទេស ដែលមានតួនាទីសម្របសម្រួលរវាងក្រុមប្រឹក្សា និងមន្ទីរជំនាញ ។ រាជរដ្ឋាភិបាលក៏បានរំពឹងគិតថា កំណែទម្រង់ត្រូវតែធ្វើជាជំហានៗប្រកបដោយយុទ្ធសាស្ត្រ (RGC 2010) ។

ដើម្បីជម្រុញសកម្មភាពកំណែទម្រង់ និងជម្នះរាល់បញ្ហាប្រឈម រដ្ឋាភិបាលបានបង្កើត គ.ជ.អ.ប នៅចុងឆ្នាំ២០០៨ ដើម្បីសម្របសម្រួល និងដឹកនាំដំណើរការនេះ ។ គ.ជ.អ.ប មានសមាជិក ១៦ រូប ។ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ គឺជាប្រធាន គ.ជ.អ.ប ហើយរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ជាអនុប្រធាន ។ សមាជិកផ្សេងទៀត រួមមាន រដ្ឋមន្ត្រី ឬរដ្ឋលេខាធិការដែលមកពីក្រសួងជំនាញផ្សេងទៀត ។ គ.ជ.អ.ប មានអនុគណៈកម្មាធិការ ៣ គឺ (១) អនុគណៈកម្មាធិការមុខងារ និងធនធាន (២) អនុគណៈកម្មាធិការកិច្ចការសារពើពន្ធ និងហិរញ្ញវត្ថុ និង (៣) អនុគណៈកម្មាធិការបុគ្គលិករបស់រដ្ឋបាលថ្នាក់ក្រោមជាតិ (RGC 2008c) ។

នៅតាមបណ្តាក្រសួងពាក់ព័ន្ធ ក្រុមការងារបច្ចេកទេសវិមជ្ឈការ និងវិសហមជ្ឈការ នឹងត្រូវបានបង្កើត ឬធ្វើឱ្យមានសកម្មភាពឡើងវិញ ។ ឧទាហរណ៍ នៅក្នុងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្រុមការងារវិមជ្ឈការ និងវិសហមជ្ឈការត្រូវបានបង្កើតឡើងដោយមានតំណាងមកពីនាយកដ្ឋាននានារបស់ក្រសួង បន្ថែមលើតំណាងមកពីនាយកដ្ឋានហិរញ្ញវត្ថុមូលដ្ឋាន ។ តួនាទីសំខាន់មួយរបស់ក្រុមកាងារនេះ គឺធ្វើការរៀបចំ និងត្រួតពិនិត្យលើសេចក្តីព្រាងច្បាប់ស្តីពីរបបហិរញ្ញវត្ថុ និងការគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ និងបន្តការពិភាក្សាលម្អិតលើសកម្មភាពទី២៧ របស់កម្មវិធីកំណែទម្រង់ប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ធ្វើយ៉ាងណាឱ្យមានសង្គតិភាពជាមួយនឹងកំណែទម្រង់វិមជ្ឈការ ។ ក្រសួងជំនាញផ្សេងទៀតក៏នឹងត្រូវបង្កើតក្រុមការងារ ដើម្បីសម្របសម្រួលផ្ទៃក្នុងរបស់ខ្លួន ទាក់ទងនឹងការពិនិត្យមើល និងផ្ទេរមុខងារ[14] ។

## ៤.២. តួនាទីរំពឹងទុកសម្រាប់បណ្តាថ្នាក់ក្រោមជាតិ

ដើម្បីដាក់អនុវត្តកម្មវិធីជាតិសម្រាប់រយៈពេល ១០ឆ្នាំ រាជរដ្ឋាភិបាលនៅដើមឆ្នាំ២០១០ បានចេញជាក្របខ័ណ្ឌ (Outlines) សម្រាប់ផែនការអនុវត្តរយៈពេល ៣ឆ្នាំទៅមុខ (២០១១-២០១៣) ក្នុងនោះមានចែងជាចំណុចគោលមួយចំនួន ។ ចំណុចគោលទី១ គឺការបែងចែកបណ្តាថ្នាក់ក្រោមជាតិបច្ចុប្បន្នទៅជា ២ថ្នាក់គឺ ថ្នាក់តំបន់ និងថ្នាក់មូលដ្ឋាន ។

តារាង ២៖ ប្រភេទនៃរដ្ឋបាលក្រោមជាតិ និងសមាសធាតុ

| *ថ្នាក់* | *សមាសធាតុ* | *ចំនួន* |
|---|---|---|
| ថ្នាក់តំបន់ | ខេត្ត | ២៣ |
| ថ្នាក់មូលដ្ឋាន | រាជធានី ខ័ណ្ឌ និងសង្កាត់របស់រាជធានី | ១ |
| | ក្រុង និងសង្កាត់របស់ក្រុង | ២៦ |
| | ស្រុក ឃុំ និងសង្កាត់របស់ស្រុក | ១៥៩ |

ប្រភព៖ NCDD (2010a, p.4)

ក្របខ័ណ្ឌផែនការ ៣ឆ្នាំ បានចែងច្បាស់អំពីតួនាទីរំពឹងទុករបស់រដ្ឋបាលក្រោមជាតិតាមបណ្តាថ្នាក់ ។ ឯកសារនេះក៏មានបង្ហាញពីផែនការផ្ទេរទៅឱ្យរដ្ឋបាលថ្នាក់មូលដ្ឋាន នូវមុខងារក្នុងការផ្តល់សេវា និងក្នុងការពង្រឹងសមត្ថភាពថ្នាក់តំបន់សម្រាប់ការកសាងផែនការ ការរៀបចំកម្មវិធីវិនិយោគជាយុទ្ធសាស្ត្រ និងការផ្តល់ការគាំទ្រដល់រដ្ឋបាលថ្នាក់មូលដ្ឋាន ។

14 កិច្ចសន្ទនាស្តីពីថវិកា និងហិរញ្ញវត្ថុថ្នាក់ក្រោមជាតិ ក្នុងការគាំទ្រ NP-SNDD នាថ្ងៃទី១៣ ខែមករា ឆ្នាំ២០០៩

ឯកសារនេះផ្តល់គំនិតថា ថ្នាក់ស្រុកនឹងក្លាយជាចំណុចចាប់ផ្តើមសំខាន់សម្រាប់ការពិភាក្សា និងអនុវត្តការផ្ទេរមុខងារ (NCDD 2010a) ។

អត្ថបទនេះសូមធ្វើការបកស្រាយលើចំនុចគោលៗដែលចែងនៅក្នុងក្របខ័ណ្ឌផែនការ ៣ឆ្នាំខាងលើ ។ ទី១ ថ្នាក់ស្រុកបានទទួលការយកចិត្តទុកដាក់ ដោយសារជាថ្នាក់មួយមានវិមាត្រសេដ្ឋកិច្ច សម្រាប់ការផ្តល់សេវាសាធារណៈ ។ ជាទូទៅ ក្នុងប្រទេសកំពុងអភិវឌ្ឍ ថ្នាក់រដ្ឋបាលដែលគួរមានការទទួលខុសត្រូវច្រើនក្នុងការផ្តល់សេវា គួរមានទំហំប្រជាជនចាប់ពី ១០០.០០០ ទៅដល់ ២០០.០០០នាក់ (Boex 2009) ។ នៅកម្ពុជា ទំហំប្រជាជននៅថ្នាក់ឃុំមានជាមធ្យមប្រមាណ ៨.០០០នាក់ និងនៅថ្នាក់ស្រុកមានប្រហែល ៧១.០០០នាក់ ។ តាមចំនួននេះ ស្រុកគឺថ្នាក់រដ្ឋបាលដែលសមរម្យជាង សម្រាប់ការទទួលបានមុខងារច្រើនក្នុងការផ្តល់សេវា ។

ទី២ នៅថ្នាក់ស្រុកបច្ចុប្បន្ន ការិយាល័យជំនាញមានវត្តមាន និងសកម្មភាពតិចតួច ។ ស្ថានភាពបែបនេះអនុញ្ញាតឱ្យការធ្វើកំណែទម្រង់នៅថ្នាក់ស្រុកអាចចាប់ផ្តើមបានពីចំណុចថ្មីមួយ ដូច្នេះអាចកាត់បន្ថយការជំពាក់ជំពិនជាមួយប្រព័ន្ធ និងឥទ្ធិពលដែលមានស្រាប់ (NCDD 2010a) ។ ចំណុចនេះអាចជួយពន្លឿនការផ្ទេរមុខងារ និងកសាងប្រព័ន្ធរដ្ឋបាលថ្មីមួយនៅថ្នាក់ស្រុក ។ ប៉ុន្តែមតិខ្លះទៀតយល់ថា ស្ថានភាពនេះគឺជាបញ្ហាប្រឈម ដោយហេតុថាគេនឹងមានការងារច្រើនដែលត្រូវធ្វើ ទម្រាំប្រព័ន្ធរដ្ឋបាលថ្នាក់ស្រុកថ្មីអាចដំណើរការបាន ។ ឧទាហរណ៍ គេត្រូវកសាង និងដាក់ឱ្យប្រើប្រាស់នូវប្រព័ន្ធសម្រាប់ការកសាងថវិកា លទ្ធកម្ម និងរតនាគារ ដែលសព្វថ្ងៃសឹងតែគ្មាននៅថ្នាក់ស្រុក ។ ម៉្យាងទៀត ការកសាងប្រព័ន្ធទាំងនេះត្រូវប្រឈមទាំងបញ្ហាបច្ចេកទេសផង និងបញ្ហានយោបាយផង ដែលនាំឱ្យដំណើរការនេះកាន់តែត្រូវមានការសម្របសម្រួល និងពិគ្រោះយោបល់ច្រើនទៀត ជាពិសេសរវាងកំណែទម្រង់វិមជ្ឈការ និងកំណែទម្រង់ប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ។

មួយវិញទៀត បើទោះជាថ្នាក់ស្រុកមានគុណសម្បត្តិខាងវិមាត្រសេដ្ឋកិច្ច គេក៏មិនត្រូវភ្លេចពីគណនេយ្យភាពរវាងថ្នាក់ស្រុក និងថ្នាក់ឃុំ/សង្កាត់នោះដែរ ។ ត្រង់ចំណុចនេះ ច្បាប់រៀបចំអង្គការបានធ្វើការបែងចែកគ្នារវាងប្រព័ន្ធរដ្ឋបាលនៅជនបទ និងនៅទីប្រជុំជន ។ នៅទីប្រជុំជន សង្កាត់ត្រូវស្ថិតក្រោមបង្គាប់ និងការគ្រប់គ្រងរបស់ក្រុង[15] ។ ថ្នាក់ក្រុងគឺជាអ្នកធ្វើប្រតិភូកម្មមុខងារ និងការទទួលខុសត្រូវទៅឱ្យថ្នាក់សង្កាត់ ។ ថ្នាក់សង្កាត់នឹងមិនមានថវិកាផ្ទាល់ខ្លួនទេ ដូច្នេះត្រូវពឹងលើថវិការបស់ក្រុង[16] ។ ការរៀបចំបែបនេះ ផ្អែកលើហេតុផលថា ការអភិវឌ្ឍនៅទីប្រជុំជន ច្រើនប៉ះពាល់ដល់សង្កាត់លើសពីមួយ ដូច្នេះថ្នាក់ដែលខ្ពស់ជាងសង្កាត់ (ពោលគឺថ្នាក់ក្រុង) ត្រូវតែមានតួនាទីច្រើន (NCDD 2010a) ។

នៅទីជនបទ ច្បាប់រៀបចំអង្គការចែងថា ថ្នាក់ស្រុកត្រូវតែមានគណនេយ្យភាពចំពោះក្រុមប្រឹក្សាឃុំ/សង្កាត់[17] ។ ការរៀបចំបែបនេះសំដៅឱ្យមានតុល្យភាពរវាងកត្តាពីរ៖ កត្តាទី១ គឺសិទ្ធិរបស់ក្រុមប្រឹក្សាឃុំ/សង្កាត់ ដោយសារពួកគេជាអ្នកទទួលការបោះឆ្នោតដោយផ្ទាល់ពីប្រជាជន និងកត្តាទី២ គឺគុណសម្បត្តិនៃថ្នាក់ស្រុកដែលមានវិមាត្រសេដ្ឋកិច្ច ។ ការរៀបចំនេះនឹងនាំឱ្យមានកិច្ចសហការរវាងស្រុក និងឃុំ/សង្កាត់ ក្នុងនោះថ្នាក់ស្រុកអាចធ្វើការកសាង និងអនុវត្តការងារអភិវឌ្ឍន៍ ទៅតាមលំដាប់អាទិភាពដែលបានពីថ្នាក់ឃុំ/សង្កាត់ ឯថ្នាក់ឃុំ/សង្កាត់នឹងមានសិទ្ធិបញ្ចេញមតិ ក្នុងការកសាងផែនការ និងការបែងចែកធនធានរបស់ស្រុក ។

---

15 មាត្រា ១១១ និង ១១២ នៃច្បាប់រៀបចំអង្គការ

16 មាត្រា ២៤៤ នៃច្បាប់រៀបចំអង្គការ

17 មាត្រា ៩៨ នៃច្បាប់រៀបចំអង្គការ

## ៥. បញ្ហាប្រឈមក្នុងជំហានខាងមុខ

### *៥.១. ការពិនិត្យពីមុខងារ និងការផ្ទេរមុខងារ*

ច្បាប់រៀបចំអង្គការតម្រូវថា ក្រុមប្រឹក្សាថ្នាក់ក្រោមជាតិ នឹងត្រូវមានទាំងមុខងារជាជម្រើស និងមុខងារជាកាតព្វកិច្ច[18] ។ ក្របខ័ណ្ឌផែនការ ៣ឆ្នាំបន្ថែមទៀតថា ស្រុកនឹងទៅជាថ្នាក់រដ្ឋបាលមួយដែលសមស្របសម្រាប់គ្រប់គ្រង និងចាត់ចែងទាំងមុខងារជាជម្រើស និងមុខងារជាកាតព្វកិច្ច (NCDD 2010a) ។ ទាក់ទងនឹងការងារផ្ទេរមុខងារ មានបញ្ហាប្រឈមមួយចំនួនដែលអាចកើតឡើងនាពេលអនាគត ។

ទី១ ការផ្ដោតលើថ្នាក់ស្រុក គឺជាការសមហេតុផលបើយោងតាមហេតុផលវិមាត្រសេដ្ឋកិច្ច ប៉ុន្តែក្នុងជំហានខាងមុខ គេត្រូវបង្កើតឱ្យមានយន្តការជាក់លាក់ ដើម្បីធានាថា សម្លេងរបស់ថ្នាក់ឃុំ/សង្កាត់ពិតជាមានទម្ងន់ ។ កន្លងមកពាក្យថា ពិគ្រោះយោបល់ទៅវិញទៅមក គេបានយកមកប្រើជាញឹកញាប់ ដើម្បីរៀបរាប់ពីរបៀបដែលថ្នាក់ស្រុក ត្រូវមានគណនេយ្យភាពចំពោះថ្នាក់ឃុំ/សង្កាត់ ។ នាពេលអនាគតដ៏ខ្លី គេត្រូវចែងឱ្យច្បាស់ជាងនេះ និងបង្កើតឱ្យមានយន្តការជាក់លាក់ ដើម្បីធានាថាគណនេយ្យភាពនោះពិតជាត្រូវបានអនុវត្ត ។ លើសពីនេះទៀត ការចូលរួម និងសម្លេងរបស់ឃុំ/សង្កាត់ទាក់ទងនឹងថ្នាក់ស្រុក គួរតែមានទាំងក្នុងដំណាក់កាលនៃការកសាងផែនការ និងបែងចែកថវិកា និងក្នុងការត្រួតពិនិត្យនិងតាមដាន ការអនុវត្តផែនការ និងថវិកាដែលអនុម័តនោះផងដែរ ។

ទី២ ការផ្ទេរមុខងារបន្ថែមទៅឱ្យថ្នាក់ក្រោមជាតិ ក្នុងកម្រិតណាមួយនោះមានន័យថា គេត្រូវកាត់យកមុខងារទាំងនោះពីក្រសួង/ស្ថាប័ននៅថ្នាក់ជាតិ ។ មុនពេលច្បាប់រៀបចំអង្គការបានអនុម័តចេញនៅឆ្នាំ២០០៨ ការចូលរួមរបស់ក្រសួងជំនាញនៅថ្នាក់ជាតិក្នុងដំណើរការវិមជ្ឈការ គឺមានកម្រិតតិចតួច ។ ក្នុងពេលរៀបចំកម្មវិធីជាតិនៅឆ្នាំ២០០៨-០៩ តំណាងក្រសួងទាំងនេះ បានចូលរួមក្នុងសិក្ខាសាលាពិគ្រោះយោបល់នានា ហើយបានរៀបចំជាតារាងនៃមុខងារដែលក្រសួងរំពឹងថា នឹងធ្វើវិមជ្ឈការ ឬវិសហមជ្ឈការ ទៅឱ្យថ្នាក់ក្រោមជាតិក្នុងរយៈពេល ៥ ឬ ១០ឆ្នាំទៅមុខ ។ តាមការសង្កេតនៅក្នុងសិក្ខាសាលាទាំងនេះ មានចំណុចគួរកត់សម្គាល់មួយចំនួនដូចតទៅ ។

ទី១ យើងសម្គាល់ឃើញថា វិស័យនីមួយៗមានភាពខុសៗគ្នា នៅពេលនិយាយពីវិមជ្ឈការ និងវិសហមជ្ឈការ ។ ឧទាហរណ៍ វិស័យអប់រំ និងសុខាភិបាល បានផ្ទេរការងារច្រើនទៅឱ្យមន្ទីរ ការិយាល័យ និងអង្គភាពរបស់គេនៅថ្នាក់ខេត្ត ស្រុក និងនៅមូលដ្ឋាន ។ ដូច្នេះនៅពេលរៀបចំជាតារាងមុខងារសម្រាប់ការផ្ទេរ វិស័យទាំងពីរនេះហាក់ទទួលយកនូវគំនិតស្ដីពីការផ្ទេរមុខងារ ទាំងផ្ទេរទៅឱ្យមន្ទីរ ការិយាល័យ និងអង្គភាពក្រោមឱវាទ (ពោលគឺវិសហមជ្ឈការ) និងទៅឱ្យក្រុមប្រឹក្សានៃរដ្ឋបាលថ្នាក់ក្រោមជាតិ (ពោលគឺវិមជ្ឈការ) ។ វិស័យខ្លះទៀតដូចជា វិស័យកសិកម្ម សាធារណការ និងដឹកជញ្ជូន និងធនធានទឹក កន្លងមកមានលក្ខណៈមជ្ឈការច្រើន ដូច្នេះហាក់នៅមានការប្រុងប្រយ័ត្ន និងមិនទាន់ប្រាកដប្រជា ទាក់ទងនឹងការផ្ទេរមុខងារ ហើយច្រើនលើកពីមុខងារសម្រាប់វិសហមជ្ឈការ ជាជាងមុខងារសម្រាប់វិមជ្ឈការ[19] ។

ទី២ វិស័យនីមួយៗក៏ខុសគ្នាផងដែរ ទៅលើបច្ចេកទេសជំនាញក្នុងការផ្ដល់សេវា ។ ឧទាហរណ៍ ការផ្ដល់សេវាសុខាភិបាលមួយចំនួនទាក់ទងនឹងបច្ចេកទេសវេជ្ជសាស្ត្រដែលជាបច្ចេកទេសស្មុគស្មាញ ជាងការផ្ដល់សេវាអប់រំថ្នាក់មត្តេយ្យ និងបឋមសិក្សា ។ កត្តាបច្ចេកទេសទាំងនេះ ត្រូវបានមន្ត្រីវិស័យជំនាញលើកជាហេតុផលដែលនាំឱ្យពួកគេមានការរារែកក្នុងការផ្ទេរមុខងារតាមបែបវិមជ្ឈការទៅឱ្យក្រុមប្រឹក្សា ប៉ុន្តែចង់ធ្វើវិសហមជ្ឈការវិញ ។ មន្ត្រីជំនាញទាំងនេះយល់ថា នៅពេលផ្ទេរមុខងារទៅឱ្យក្រុមប្រឹក្សា ពេលនោះមន្ត្រីរបស់ក្រុមប្រឹក្សា នឹងក្លាយជាអ្នកផ្ដល់សេវាដែលទាក់ទងនឹងមុខងារនោះដោយផ្ទាល់ ។

---

18 ជំពូកទី៥ ផ្នែកទី២ នៃច្បាប់រៀបចំអង្គការ

19 ឧបសម្ព័ន្ធទី១ នៃ NP-SNDD

ឧទាហរណ៍ តាមការយល់របស់ពួកគេ ប្រសិនបើមុខងារក្នុងការផ្គត់ផ្គង់វ៉ាក់សាំងជម្ងឺណាមួយ ត្រូវបានផ្ទេរឱ្យទៅក្រុមប្រឹក្សា ពេលនោះមន្ត្រីរបស់ក្រុមប្រឹក្សាផ្ទាល់ នឹងចុះទៅធ្វើការចាក់វ៉ាក់សាំងដោយខ្លួនឯង[20] ។ ការយល់ឃើញបែបនេះ បាននាំឱ្យមន្ត្រីតាមវិស័យមានការរារែកក្នុងការធ្វើវិមជ្ឈការ ។

តាមពិត គំនិតនេះជាការយល់ច្រឡំមួយ ។ យោងតាមទ្រឹស្តីដែលបានលើកឡើងកន្លងមក ការធ្វើវិមជ្ឈការមុខងារមិនមែនមានន័យថា ក្រុមប្រឹក្សាត្រូវតែជាអ្នកដើរតួដោយផ្ទាល់ក្នុងការផលិត និងផ្តល់សេវាដែលពាក់ព័ន្ធនឹងមុខងារនោះទេ ។ ការយល់ខុសខាងលើ គឺជាឧទាហរណ៍មួយនៃកង្វះខាតការយល់ដឹងពីគ្នាទៅវិញទៅមក រវាងមន្ត្រីជំនាញ និងមន្ត្រីដែលធ្វើការក្នុងក្របខ័ណ្ឌវិមជ្ឈការ ។ ចំណុចនេះបញ្ជាក់ថា នៅក្នុងដំណាក់កាលបន្ទាប់នៃកំណែទម្រង់ ទំនាក់ទំនង និងការយល់ដឹងពីគ្នារវាងភាគីទាំងពីរ គឺជាកត្តាសំខាន់ ។

ទី៣ នៅពេលធ្វើការផ្ទេរមុខងារ គេត្រូវមានគោលការណ៍ជាមូលដ្ឋានមួយចំនួន ទាក់ទងនឹងនិយមន័យនៃពាក្យមុខងារ ធាតុសំខាន់ៗរបស់មុខងារ គោលការណ៍សម្រាប់កំណត់ថា រដ្ឋបាលថ្នាក់ណាគួរទទួលយកមុខងារប្រភេទណា ។ល។ គោលការណ៍ទាំងនេះសំខាន់ណាស់ សម្រាប់កាត់បន្ថយការយល់ច្រឡំនៅពេលពិភាក្សាអំពីការផ្ទេរមុខងារ ។ ប៉ុន្តែសព្វថ្ងៃ គោលការណ៍ទាំងនេះមិនទាន់បានតាក់តែង និងមានការយល់ស្របនៅឡើយទេ ។ ដោយមើលឃើញពីកង្វះខាតបែបនេះ ជំនាញការរបស់ដៃគូអភិវឌ្ឍន៍ខ្លះ បានចាប់ផ្តើមរៀបចំជាឯកសារជំនួយស្មារតីទាក់ទងនឹងគោលការណ៍ទាំងនេះ ។ នៅពេលការងារនេះចប់សព្វគ្រប់ និងទទួលយកដោយរាជរដ្ឋាភិបាល ការផ្សព្វផ្សាយ និងវគ្គបណ្តុះបណ្តាលត្រូវចាប់ផ្តើមនៅតាមស្ថាប័នពាក់ព័ន្ធទាំងឡាយ ដើម្បីឱ្យពួកគាត់បានយល់ពីគោលការណ៍ណែនាំទាំងនេះ ។

សព្វថ្ងៃ គោលគំនិតស្តីពីមុខងារនៅកម្ពុជា ទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ នៅខ្វះភាពច្បាស់លាស់ ។ វិស័យមួយចំនួនដូចជា វិស័យអប់រំ និងសុខាភិបាល ដែលមានបទពិសោធន៍ក្នុងការធ្វើវិសហមជ្ឈការ បានរៀបចំជាសកម្មភាពតាមកម្មវិធី និងអនុកម្មវិធី ។ សកម្មភាពទាំងនេះ ទោះលម្អិតនិងមានភាពជាក់លាក់ តែមិនទាន់ចាត់ទុកថាជាមុខងារនៅឡើយទេ ព្រោះមានលក្ខណៈជាសកម្មភាពដែលត្រូវបានបំបែកទៅជាផ្នែកតូចៗ ក្នុងបំណងធ្វើឱ្យងាយស្រួលដល់ការកសាងថវិកាទៅតាមការងារលម្អិតនីមួយៗនោះ (Pak 2009a; Pak 2009b) ។

វិស័យខ្លះទៀត ដូចជា កសិកម្ម សាធារណការ និងធនធានទឹកជាដើម នៅមិនទាន់មានតារាងការងារបំបែកលម្អិត ដូចក្នុងវិស័យពីរខាងលើទេ ។ តួនាទី និងភារកិច្ចរបស់ក្រសួងក្នុងវិស័យទាំងនេះ នៅបន្តប្រើភាសាទូលំទូលាយដូចជា ការបង្កើត ការសម្របសម្រួល ការគាំទ្រ ការធានាលើការងារ ។ល។ ដែលមានលក្ខណៈទូលំទូលាយ និងខ្វះភាពជាក់លាក់[21] ។ នៅក្នុងវិស័យទាំងនេះ ដើម្បីអាចស្វែងយល់ពីមុខងារជាក់លាក់ដែលពួកគេបានធ្វើ គឺត្រូវចុះទៅសាកសួរ និងអង្កេតដោយផ្ទាល់លើការអនុវត្តជាក់ស្តែងរបស់ពួកគេ ។

ទី៤ ការភ្ជាប់ទំនាក់ទំនងរវាងវិស័យជំនាញ និងកំណែទម្រង់វិមជ្ឈការ គឺជាការងារសំខាន់នៅជំហានបន្ទាប់ ។ បញ្ហាថាតើការភ្ជាប់នេះអាចប្រព្រឹត្តទៅបានកម្រិតណា អាស្រ័យលើប្រសិទ្ធភាពរបស់ គ.ជ.អ.ប និងជាពិសេសរបស់អនុគណៈកម្មាធិការមុខងារ និងធនធាន និងទៅលើភាពសកម្មរបស់ក្រុមការងារបច្ចេកទេសសម្រាប់វិមជ្ឈការនិងវិសហមជ្ឈការ នៅតាមក្រសួងនីមួយៗ ។ នៅតាមក្រសួងខ្លះ ក្រុមការងារនេះបានចាប់ផ្តើមមានសកម្មភាព ប៉ុន្តែខ្លះទៀតហាក់មិនទាន់បានដំណើរការល្អនៅឡើយ ។ ប៉ុន្តែជាទូទៅ ក្រុមការងារទាំងនេះ នៅត្រូវការការគាំទ្រ និងបណ្តុះបណ្តាលសមត្ថភាពច្រើនទៀត ដើម្បីឱ្យពួកគេអាចក្លាយជាយន្តការបង្កឱ្យមានចំណុចប្រសព្វរវាងវិមជ្ឈការ និងការងារបច្ចេកទេសតាមវិស័យ[22] ។

---

20 ការសង្កេតមើលផ្ទាល់ខ្លួនក្នុងអំឡុងពេលនៃការតាក់តែងកម្មវិធីជាតិ (២០០៨/២០០៩)

21 ibid

22 ibid

ទី៥ ការផ្ទេរមុខងារ គឺជាដំណើរការមានរយៈពេលវែង ហើយអាចបន្តទៅហួសពីអាយុកាលរបស់កម្មវិធីរយៈពេល ១០ឆ្នាំ ដែលត្រូវបញ្ចប់នៅឆ្នាំ២០១៩ ទៅទៀត ។ ដំណើរការនេះនឹងកាន់តែមានរយៈពេលវែងទៅទៀតសម្រាប់ប្រទេសកម្ពុជាដែលមានរដ្ឋបាលមជ្ឈការខ្លាំងដូចបច្ចុប្បន្ន ។ សព្វថ្ងៃនេះ មិនត្រឹមតែវិមជ្ឈការប៉ុណ្ណោះទេដែលនៅមានកម្រិត សូម្បីតែវិសហមជ្ឈការតាមវិស័យ ក៏នៅមានកម្រិតដែរ (Pak and Craig 2008) ។ ចំណុចនេះមានន័យថា ពេលធ្វើការផ្ទេរមុខងារ ទាំងការផ្ទេរតាមវិមជ្ឈការ និងការផ្ទេរតាមវិសហមជ្ឈការ គឺត្រូវតែគិតព្រមគ្នា (NCDD 2010a) ។

ប្រអប់ទី ១៖ ជំហានបឋមក្នុងការពិភាក្សាអំពីការផ្ទេរមុខងារក្នុងវិស័យអប់រំ

វិស័យអប់រំ គឺជាវិស័យដែលមានបទពិសោធន៍ច្រើននៅក្នុងការងារវិសហមជ្ឈការ ។ តាំងពីឆ្នាំ២០០០មក វិស័យនេះ មានកម្មវិធីបង្ហូរថវិកាឱ្យទៅដល់សាលារៀន (World Bank 2005) ។ ផែនការជាយុទ្ធសាស្ត្រសម្រាប់វិស័យអប់រំ (ឆ្នាំ២០០៦-១០) ក៏បានចាប់យកវិមជ្ឈការជាធាតុមួយសំខាន់ក្នុងការកសាងស្ថាប័ន និងប្រព័ន្ធគ្រប់គ្រងរបស់ខ្លួនផងដែរ ។

នៅក្នុងសិក្ខាសាលានៃការរៀបចំកម្មវិធីជាតិអំពីការផ្ទេរមុខងារ ក្រសួងអប់រំបានបង្ហាញពីចេតនាធ្វើវិសហមជ្ឈការ និងវិមជ្ឈការនូវមុខងារក្នុងវិស័យរបស់ខ្លួន ។ ក្រុមការងារបច្ចេកទេសសម្រាប់វិមជ្ឈការ និងវិសហមជ្ឈការរបស់ក្រសួង បានដាក់ស្នើមុខងារចំនួន ១១ បន្ទាប់មកថ្នាក់ដឹកនាំក្រសួងបានសម្រេចយកមុខងារចំនួន ៦ សម្រាប់ការផ្ទេរក្នុងរយៈពេលពី ៥ ទៅ ១០ឆ្នាំទៅមុខ ។ មុខងារទាំងនោះរួមមាន (១) ការត្រួតពិនិត្យលើសកម្មភាពមិនមែនបច្ចេកទេសតាំងពីមត្តេយ្យសិក្សារហូតដល់ថ្នាក់មធ្យមសិក្សា (២) ការផ្តល់ការអប់រំកុមារតូច និងមត្តេយ្យសហគមន៍ (៣) ការផ្តល់ការអប់រំក្រៅប្រព័ន្ធ (៤) ការផ្តល់ការអប់រំបឋមសិក្សា (៥) ការធានាឱ្យមានការផ្តល់នូវសម្ភារៈ និងបរិក្ខារនៅតាមសាលារៀន (៦) ការផ្តល់ការអប់រំស្ថិតនៅក្រៅកម្មវិធីសិក្សា ដូចជាតន្ត្រី កីឡា* ។ល ។

ការកំណត់មុខងារខាងលើ គឺជាការសាកល្បង ដើម្បីជម្រុញឱ្យមានការចូលរួមពីក្រសួងជំនាញនៅក្នុងដំណើរការវិមជ្ឈការ ។ ដើម្បីអាចអនុវត្តបាន គេត្រូវធ្វើការសិក្សាល្អិតល្អន់បន្ថែមអំពីហេតុផលដូចជា ហេតុអ្វីបានជាមុខងារមួយគួរផ្ទេរ? ផ្ទេរទៅឱ្យថ្នាក់ណា? និងលើផ្នែកណា? តើគួរផ្ទេរតាមវិមជ្ឈការ ឬវិសហមជ្ឈការ? ហេតុអ្វី? ដើម្បីឆ្លើយតបនឹងសំណួរទាំងនេះ ត្រូវមានការយល់ដឹងទាំងខាងវិមជ្ឈការផង និងវិសហមជ្ឈការផង និងទាំងការងារផ្តល់សេវាអប់រំផង ។

កាន់តែស្មុគស្មាញជាងនេះទៀត គឺការប៉ាន់ស្មាន និងរៀបចំប្រព័ន្ធផ្ទេរធនធាន និងប្រព័ន្ធគ្រប់គ្រងធនធាន ដែលត្រូវភ្ជាប់ជាមួយនឹងមុខងារ ។ សព្វថ្ងៃ វិស័យអប់រំមានកម្មវិធីចំនួន ១២ ដែលជាខ្ទង់ចំណាយចរន្ត និងមានកម្មវិធីសម្រាប់ការអភិវឌ្ឍស្ថាប័នដែលជាខ្ទង់ចំណាយមូលធន (MOEYS 2005b; Pak 2009a) ។ ចេញពីចំណុចនេះ នៅពេលធ្វើការផ្ទេរមុខងារ ដំបូងគេត្រូវកំណត់មុខងារដែលត្រូវផ្ទេរ និងធ្វើការប៉ាន់ស្មានថា តើមុខងារនោះតម្រូវឱ្យមានធនធានប៉ុន្មាន ។ ការប៉ាន់ស្មាននេះ ជួបការលំបាកដោយសារកង្វះខាតព័ត៌មានអំពីការចំណាយថវិកាពីគ្រប់ប្រភព និងការភ្ជាប់ចំណាយទាំងនោះទៅនឹងមុខងារនីមួយៗ ។

របាយការណ៍ថ្មីៗនេះបញ្ជាក់ថា ព័ត៌មានអំពីថវិកាក្នុងវិស័យអប់រំ បានបែកខ្ញែកយ៉ាងហោចជាបីផ្នែក គឺព័ត៌មានទាក់ទងនឹង (១) ចំណាយចរន្តបានមកពីហិរញ្ញប្បទានក្នុងស្រុក (២) ចំណាយមូលធនបានមកពីហិរញ្ញប្បទានក្នុងស្រុក និង (៣) ចំណាយនានាបានមកពីហិរញ្ញប្បទានរបស់ដៃគូអភិវឌ្ឍន៍ និងអង្គការមិនមែនរដ្ឋាភិបាល ។ នាយកដ្ឋានហិរញ្ញវត្ថុរបស់ក្រសួងអប់រំ រក្សាទុកតែព័ត៌មានប្រភេទទី១ប៉ុណ្ណោះ ។ ព័ត៌មានប្រភេទទី២ មានរក្សាទុកជាតួលេខរួមនៅក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងប្រភេទទី៣ អាចទទួលបានពីអង្គភាពគ្រប់គ្រងគម្រោងនីមួយៗ ។ ទោះមានការខិតខំប្រមូលផ្តុំព័ត៌មានទាំងអស់នេះក្តី (ជាពិសេសទាក់ទងនឹងពត៌មាននៃការគាំទ្ររបស់ដៃគូអភិវឌ្ឍន៍ និងអង្គការមិនមែនរដ្ឋាភិបាល) សូម្បីតែមន្ត្រីក្នុងក្រសួងអប់រំ ក៏នៅមានការលំបាកក្នុងការកំណត់ថា តើមុខងារណាមួយកន្លងមកបានប្រើប្រាស់ធនធានអស់ប៉ុន្មាន និងមកពីប្រភពណាខ្លះនោះដែរ (Pak 2009a)។

ទី៦ ទោះការផ្ទេរមុខងារ ត្រូវធ្វើឡើងតាមវិមជ្ឈការ ឬតាមវិសហមជ្ឈការក្តី ក្រុមប្រឹក្សាថ្នាក់ក្រោមជាតិត្រូវធ្វើការពង្រឹងសមត្ថភាពបន្ថែម ។ សម្រាប់មុខងារដែលផ្ទេរតាមវិមជ្ឈការ ក្រុមប្រឹក្សាត្រូវមានសមត្ថភាពគ្រប់គ្រាន់ ក្នុងការធានាឱ្យមានគណនេយ្យភាពទៅលើការបំពេញមុខងារទាំងនោះ ។ ពេលមុខងារត្រូវបានផ្ទេរតាមវិសហមជ្ឈការ ក្រុមប្រឹក្សាត្រូវពង្រឹង

* សិក្ខាសាលានៃការតាក់តែងកម្មវិធីជាតិ ថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០០៨

សមត្ថភាពរបស់ខ្លួន ជាពិសេសទាក់ទងនឹងការកសាងផែនការអភិវឌ្ឍន៍ ការធ្វើសមាហរណកម្មផែនការ និងថវិការបស់មន្ទីរជំនាញ និងការសម្របសម្រួលតាមខ្សែទទឹង និងការត្រួតពិនិត្យតាមដានការអនុវត្តការងារ ។

ក្របខ័ណ្ឌនៃផែនការ ៣ឆ្នាំ បានលើកជាជម្រើសមួយថា ជាដំបូង ការផ្ទេរមុខងារអាចចាប់ផ្តើមជាវិសហមជ្ឈការនៅថ្នាក់ខេត្ត និងជាប្រតិភូកម្មចុះកិច្ចសន្យានៅថ្នាក់ស្រុក ។ នៅដំណាក់កាលនេះ គេគួរចាប់ផ្តើមជាគម្រោងសាកល្បង បន្ទាប់មកអាចពង្រីកទៅទូទាំងប្រទេស ។ សម្រាប់ការចុះកិច្ចសន្យា ថ្នាក់ស្រុកនឹងដើរតួជាស្ថាប័នមានស្វ័យភាពទទួលអនុវត្តកម្មវិធី និងគម្រោងអាទិភាពរបស់ថ្នាក់ជាតិ (NCDD 2010a) ។ ពិតណាស់ នៅពេលអនុវត្តជាក់ស្តែង ការរៀបចំនឹងមានការខុសប្លែកគ្នាពីវិស័យមួយទៅវិស័យមួយ ឯការបែងចែកតួនាទីរវាងថ្នាក់នីមួយៗ ក៏នឹងខុសគ្នាដែរ ។

## ៥.២. ចំណូលផ្ទាល់ និងមូលធនផ្ទេរពីថវិការដ្ឋ

ហិរញ្ញវត្ថុដើរតាមមុខងារ គឺជាគោលការណ៍សំខាន់នៃវិមជ្ឈការហិរញ្ញវត្ថុ ទាំងនៅក្នុងទ្រឹស្តី ទាំងនៅក្នុងការអនុវត្តនៅកម្ពុជា ។ ដូចបានលើកឡើងខាងលើ ប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុបច្ចុប្បន្ន នៅមានលក្ខណៈមជ្ឈការខ្លាំង ។ ទោះយ៉ាងនេះក្តី ច្បាប់រៀបចំអង្គការ និងឯកសារគោលនយោបាយផ្សេងៗទៀតបានចែងច្បាស់ថា ថ្នាក់ក្រោមជាតិត្រូវទទួលបានធនធានហិរញ្ញវត្ថុសម្រាប់គ្រប់គ្រង និងចាត់ចែងការទទួលខុសត្រូវ និងមុខងារដែលផ្ទេរឱ្យ (NCDD 2010a) ។ ក្នុងន័យនេះ ថ្នាក់ក្រោមជាតិ នឹងទទួលបានចំណូលពីប្រភពនៅមូលដ្ឋាន និងពីប្រភពថវិការដ្ឋ ក្នុងរូបភាពជាមូលនិធិផ្ទេរមានភ្ជាប់លក្ខខណ្ឌ និងមូលនិធិផ្ទេរគ្មានភ្ជាប់លក្ខខណ្ឌ[23] ។

ពេលនិយាយពីហិរញ្ញវត្ថុថ្នាក់ក្រោមជាតិ គេត្រូវមានជាប្រព័ន្ធមួយជាក់លាក់ ។ ប្រព័ន្ធនោះមានធាតុបីសំខាន់ ដែលត្រូវបង្កើតឡើងដើម្បីឆ្លើយតបនឹងចំណោទបីដូចតទៅ (១) តើមុខងារណាគួរគ្រប់គ្រង និងចាត់ចែងដោយធនធានហិរញ្ញវត្ថុប្រភេទណា? (២) តើធនធានទាំងនោះត្រូវផ្ទេរតាមរបៀបណា ដើម្បីធានាឱ្យមានភាពទៀងទាត់ និងតម្លាភាព? និង (៣) តើប្រព័ន្ធគ្រប់គ្រងបែបណាអាចធានាឱ្យមានការប្រើប្រាស់ធនធានដែលផ្តល់ឱ្យប្រកបដោយគណនេយ្យភាព? បច្ចុប្បន្ន រាជរដ្ឋាភិបាលមិនទាន់មានគោលនយោបាយដែលឆ្លើយតបនឹងសំណួរទាំងនេះនៅឡើយទេ ។ ប៉ុន្តែមានជាចំណុចគោលសំខាន់ៗមួយចំនួនដែលបានលើកឡើងដោយក្របខ័ណ្ឌផែនការ ៣ឆ្នាំ ដូចមានសង្ខេបក្នុងតារាងខាងក្រោម៖

តារាង ៣៖ ប្រភេទនៃមុខងារ និងធនធានហិរញ្ញវត្ថុសម្រាប់គ្រប់គ្រង និងចាត់ចែងប្រភេទមុខងារនីមួយៗ

| *ប្រភេទមុខងារ និងការទទួលខុសត្រូវ* | *ធនធានហិរញ្ញវត្ថុត្រូវយកមកប្រើ* |
|---|---|
| - មុខងារទូទៅ (ជាជម្រើស)<br>- កិច្ចការរដ្ឋបាល | - ចំណូលផ្ទាល់នៅមូលដ្ឋាន (ទាំងពន្ធ និងមិនមែនពន្ធ)<br>- មូលនិធិផ្ទេរគ្មានភ្ជាប់លក្ខខណ្ឌ |
| - មុខងារជាក់លាក់ ត្រូវបានធ្វើប្រតិភូកម្មឲ្យ | - ហិរញ្ញប្បទានតាមការចុះកិច្ចសន្យា ទទួលបានពីភ្នាក់ងារដែលធ្វើប្រតិភូកម្មឱ្យ |
| - មុខងារជាក់លាក់ ត្រូវបានប្រគល់ឲ្យ | - មូលនិធិផ្ទេរមានភ្ជាប់លក្ខខណ្ឌ |
| - កម្មវិធីអភិវឌ្ឍន៍មូលធនជាប់ទាក់ទងជាមួយនឹងមុខងារ និងការទទួលខុសត្រូវខាងលើ (ឧទាហរណ៍៖ ការវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធ ការការពារធនធានធម្មជាតិ និងការអភិវឌ្ឍសេដ្ឋកិច្ចមូលដ្ឋាន) | - ហិរញ្ញប្បទានតាមគម្រោងអភិវឌ្ឍន៍ |

(ប្រភព៖ NCDD 2010a, p.9)

23 មាត្រា ២៤៦ ២៤៧-៩ នៃច្បាប់រៀបចំអង្គការ

ពេលធ្វើកំណែទម្រង់ រដ្ឋបាលថ្នាក់ក្រោមជាតិនឹងទទួលបានសិទ្ធិអំណាចក្នុងការប្រមូលចំណូលផ្ទាល់ ទាំងពន្ធ និងមិនមែនពន្ធ ។ ពេលនោះ ទី១ គេត្រូវសម្រេចថាតើរដ្ឋបាលថ្នាក់ណា ត្រូវទទួលបានចំណូលពន្ធ និងមិនមែនពន្ធមួយណា ។ ការរៀបចំឱ្យមានចំណូលចែករំលែក (ទាំងពន្ធ និងមិនមែនពន្ធ) ក៏ត្រូវបានលើកជាជម្រើសមួយដែរ ។ ទី២ ដើម្បីលើកកម្ពស់ស្វ័យភាពហិរញ្ញវត្ថុរបស់ថ្នាក់ក្រោមជាតិ និងពង្រឹងគណនេយ្យភាពចំពោះប្រជាជន ថ្នាក់ក្រោមជាតិត្រូវទទួលបានឆន្ទានុសិទ្ធិក្នុងកម្រិតណាមួយ ក្នុងការកំណត់មូលដ្ឋានពន្ធ និងអត្រាពន្ធ ដែលពួកគេអាចប្រមូលនៅក្នុងក្របខ័ណ្ឌមួយដែលកំណត់ដោយច្បាប់របស់រដ្ឋ (NCDD 2010a) ។

ការអនុញ្ញាតឱ្យថ្នាក់ក្រោមជាតិ មានឆន្ទានុសិទ្ធិក្នុងការកំណត់អត្រាពន្ធ ត្រូវបានលើកឡើងនៅក្នុងសិក្ខាសាលាតាក់តែងកម្មវិធីជាតិ ។ សេណារីយ៉ូមួយ គឺអនុញ្ញាតឱ្យថ្នាក់ក្រោមជាតិកំណត់អត្រា នៅក្នុងរង្វង់មួយដែលកំណត់ដោយច្បាប់ ។ សិក្ខាកាមចូលរួមហាក់យល់ស្របថា នេះជាសេណារីយ៉ូល្អមួយ ។ ប៉ុន្តែគេត្រូវគិតពីតថភាពជាក់ស្តែងក្នុងការអនុវត្តសេណារីយ៉ូនេះ ។ មន្ត្រីពន្ធដារជាន់ខ្ពស់ម្នាក់បានលើកថា សេណារីយ៉ូនេះល្អ ប៉ុន្តែប្រហែលជាត្រូវការពេល ៥ ទៅ ១០ឆ្នាំទៀត ទើបអាចដាក់ឱ្យអនុវត្តបាន ដោយសារប្រព័ន្ធរដ្ឋបាលពន្ធដារសព្វថ្ងៃនៅទន់ខ្សោយ ឯប្រជាជនកម្ពុជាមួយភាគធំ នៅមិនទាន់ទម្លាប់នឹងវប្បធម៌នៃការបង់ពន្ធជូនរដ្ឋនៅឡើយ ។ គំនិតលើកឡើងដោយមន្ត្រីពន្ធដារនៅខាងលើ មានភាពសមហេតុផល និងគួរយកមកពិចារណា[24] ។

ភាពទន់ខ្សោយនៅក្នុងប្រព័ន្ធរដ្ឋបាលចំណូលមិនមែនពន្ធ ក៏អាចពន្យឺតការរៀបចំឱ្យមានការប្រមូលចំណូលមិនមែនពន្ធនៅថ្នាក់ក្រោមជាតិដែរ ។ មន្ត្រីនាយកដ្ឋានចំណូលមិនមែនពន្ធនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បានលើកថា សព្វថ្ងៃសិទ្ធិក្នុងការប្រមូលចំណូលមិនមែនពន្ធ មិនមែនស្ថិតក្រោមដែនសមត្ថកិច្ចរបស់នាយកដ្ឋាននេះតែមួយទេ ប៉ុន្តែស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួង និងនាយកដ្ឋានមួយចំនួន ដូចជាក្រសួងកសិកម្ម ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ។ល។ ចំណុចនេះមានន័យថា នៅពេលពិភាក្សាអំពីការផ្ទេរសិទ្ធិប្រមូលចំណូលមិនមែនពន្ធទៅឱ្យថ្នាក់ក្រោមជាតិ ការចូលរួមពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុតែមួយក្រសួងមិនគ្រប់គ្រាន់ឡើយ គឺត្រូវមានការពិភាក្សាជាមួយក្រសួង និងនាយកដ្ឋានផ្សេងៗទៀតដែលមានសិទ្ធិប្រមូលចំណូលនេះដែរ ។ រឿងនេះធ្វើឱ្យការសម្របសម្រួលកាន់តែមានសារៈសំខាន់ថែមទៀត ។

ទោះមានបញ្ហាប្រឈមយ៉ាងនេះក្តី ការរៀបចំឱ្យមានការប្រមូលចំណូលពន្ធ និងមិនមែនពន្ធនៅថ្នាក់ក្រោមជាតិ មិនមែនចាប់ផ្តើមពីកម្រិតទទេស្អាតមួយនោះទេ ។ ដូចបានរៀបរាប់ខាងលើ ចាប់តាំងពីឆ្នាំ១៩៩៨មក ថ្នាក់ខេត្តត្រូវបានប្រគល់សិទ្ធិឱ្យប្រមូលចំណូលជាពន្ធ និងមិនមែនពន្ធមួយចំនួន (Bartholomew and Betley 2004) ។ ការអនុវត្តកន្លងមកនេះអាចយកមកធ្វើជាបទពិសោធន៍ សម្រាប់ការអនុវត្តនាពេលអនាគត ។ ប៉ុន្តែថ្នាក់ស្រុកកន្លងមក មិនត្រូវបានប្រគល់សិទ្ធិប្រមូលចំណូលដូចថ្នាក់ខេត្តឡើយ (Ojendal and Kim 2008) ។

បើទោះជាចំណូលនៅមូលដ្ឋាន មានសារៈសំខាន់នៅក្នុងការងារវិមជ្ឈការហិរញ្ញវត្ថុក្តី យោងតាមស្ថានភាពបច្ចុប្បន្ន គេរំពឹងថា ក្នុងរយៈពេលខ្លី និងមធ្យម ថ្នាក់ក្រោមជាតិនឹងបន្តពឹងផ្អែកលើមូលនិធិផ្ទេរពីថ្នាក់ជាតិ ។ សម្រាប់ថ្នាក់ឃុំ/សង្កាត់ គេអាចដកស្រង់បទពិសោធន៍ជាច្រើនអំពីការអនុវត្តការផ្ទេរមូលនិធិឃុំ/សង្កាត់កន្លងមក ។ នៅថ្នាក់ខេត្ត ការផ្ទេរឧបត្ថម្ភធនកន្លងមកក៏អាចប្រើជាចំណុចប្រៀបធៀបមួយ សម្រាប់រៀបចំឱ្យមានការផ្ទេរមូលនិធិក្នុងពេលអនាគត ។ ចំណុចខ្វះខាតមួយគឺ ប្រព័ន្ធផ្ទេរឧបត្ថម្ភធនឲ្យខេត្តកន្លងមក មិនមានប្រើជារូបមន្តច្បាស់លាស់ សម្រាប់ការបែងចែកថវិកាទៅឱ្យខេត្តនីមួយៗទេ ដែលនាំឱ្យមានអសមភាពតាមតំបន់ (Boex 2009) ។

សម្រាប់ថ្នាក់ស្រុក និងក្រុង នៅមានការងារជាច្រើនត្រូវរៀបចំ ។ ដំបូងគេត្រូវរៀបចំប្រព័ន្ធថវិកាមួយថ្មី ដើម្បីដាក់ឱ្យថ្នាក់ស្រុក និងក្រុងប្រើប្រាស់ ។ ត្រង់នេះ ក្របខ័ណ្ឌនៃផែនការអនុវត្ត ៣ឆ្នាំ បានលើកឡើងជាជម្រើសហិរញ្ញប្បទាន បីសំខាន់ៗ សម្រាប់ការគ្រប់គ្រង និងចាត់ចែងមុខងារទូទៅ (ពោលគឺមុខងារជាជម្រើស) នៅថ្នាក់ស្រុក និងក្រុង ។ ជម្រើស

---

24 កិច្ចសម្ភាសជាមួយមន្ត្រីពន្ធដារ នៅថ្ងៃទី២១ ខែមករា ឆ្នាំ២០០៩

ទី១ គេនឹងបង្កើតឱ្យមានជាមូលនិធិស្រុក/ក្រុង (ដែលមានលក្ខណៈស្រដៀងនឹងមូលនិធិឃុំ/សង្កាត់) ហើយកំណត់ចំនួនមូលនិធិឲ្យស្មើនឹង 0,៥% ឬ ១,0% នៃចំណូលក្នុងស្រុករបស់ជាតិ ហើយប្រើរូបមន្តប្រកបដោយតម្លាភាពមួយ ដើម្បីបែងចែកមូលនិធិនោះទៅឱ្យស្រុក និងក្រុង ។ ជម្រើសទី២ គេនឹងបង្កើនចំនួនមូលនិធិឃុំ/សង្កាត់ពី ២,៨% ទៅ ៣,៥% ធៀបនឹងចំណូលក្នុងស្រុករបស់ជាតិ សម្រាប់រយៈពេលពីឆ្នាំ២០១១-២០១៣ ។ ក្នុងរយៈពេលនេះ ឃុំ/សង្កាត់នឹងទទួលបានមូលនិធិក្នុងចំនួនមួយថេរ ឯចំនួនដែលនៅសល់ (សមតុល្យ) នឹងត្រូវផ្ទេរឱ្យទៅថ្នាក់ស្រុក និងក្រុង ។ ជាជម្រើសទី៣ គេនឹងបែងចែកថវិកាជាតិមួយផ្នែកសម្រាប់ថ្នាក់ស្រុក និងក្រុង ហើយចាត់ចែងថវិកានេះក្នុងលក្ខណៈស្រដៀងគ្នានឹងមូលនិធិដែលផ្ទេរឱ្យសាលាខេត្តនាពេលបច្ចុប្បន្ន (NCDD 2010a) ។

នៅពេលផែនការ ៣ឆ្នាំលម្អិតបានអនុម័តហើយនៅខែវិច្ឆិកា ឆ្នាំ២០១០ រាជរដ្ឋាភិបាលបានសម្រេចយកជម្រើសទី១ ពោលគឺការបង្កើតឱ្យមានមូលនិធិស្រុក និងក្រុង ។ សេចក្តីសម្រេចនេះ បានបើកផ្លូវឱ្យថ្នាក់ស្រុកមានសិទ្ធិទទួលបានថវិកាផ្ទាល់របស់ខ្លួន ដែលពីមុនមក ពួកគេមិនដែលបានទទួល ។ គួរបញ្ជាក់ថា ថវិកាផ្ទាល់ខ្លួននៅទីនេះ មានន័យថា ថ្នាក់ស្រុក/ក្រុងនឹងមានឆន្ទានុសិទ្ធិ ក្នុងការបែងចែកថវិកានោះ ដើម្បីឆ្លើយតបនឹងតម្រូវការនៅមូលដ្ឋានរបស់ខ្លួន អនុលោមតាមច្បាប់គ្រប់គ្រងហិរញ្ញវត្ថុសាធារណៈទាំងឡាយ ។ ដូច្នេះ ថ្នាក់ស្រុក និងក្រុងនឹងមានស្វ័យភាពហិរញ្ញវត្ថុមួយនៅក្នុងក្របខ័ណ្ឌច្បាប់ ។

ចំណោទស្តីពីស្វ័យភាពហិរញ្ញវត្ថុ ទាក់ទងដោយផ្ទាល់ជាមួយនឹងការរៀបចំប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុនៅថ្នាក់ក្រោមជាតិ ។ ក្នុងដំណាក់កាលដំបូងនេះ យើងសង្កេតឃើញថា នៅមានភាពប្រទាំងប្រទើសគ្នាខ្លះរវាងច្បាប់រៀបចំអង្គការ (ដែលណែនាំពីប្រព័ន្ធរដ្ឋបាលបែបវិមជ្ឈការ) និងច្បាប់គ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (ដែលនៅប្រកាន់យកគោលការណ៍មជ្ឈការទាក់ទងនឹងការងារហិរញ្ញវត្ថុ) ។ ច្បាប់គ្រប់គ្រងហិរញ្ញវត្ថុឆ្នាំ២០០៨ ចែងថា រដ្ឋបាលថ្នាក់ជាតិ គឺជាអ្នកអនុម័តលើថវិការបស់ថ្នាក់ក្រោមជាតិ ។ ការចែងនេះនឹងផ្តល់អំណាចដល់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុនូវអំណាចក្នុងការចរចា និងអនុម័តថវិការបស់ថ្នាក់ក្រោមជាតិ មុនពេលឈានដល់ការអនុម័តចុងក្រោយដោយរដ្ឋសភាជាតិ[25] ។

ពេលអនុវត្តថវិកា តាមច្បាប់គ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ តួនាទីរបស់រតនាគារជាតិ និងសាខារតនាគារនៅតាមខេត្តនឹងមានតួនាទីសំខាន់ ។ តួនាទីនោះមាន ការជួយចាត់ចែងការដកប្រាក់ចំណាយ ការរក្សាទុកបញ្ជីគណនេយ្យ និងការធ្វើរបាយការណ៍ជាប់ពាក់ព័ន្ធ ។ នៅក្នុងសិក្ខាសាលាតាក់តែងកម្មវិធីជាតិ មន្ត្រីរតនាគារជាតិបានលើកឡើងថា ខាងរតនាគារកំពុងរៀបចំការងារមួយចំនួន ដើម្បីគាំទ្រដល់ដំណើរការវិមជ្ឈការ រួមមាន ការរៀបចំឱ្យមានប្លង់គណនេយ្យថ្មី សម្រាប់ថ្នាក់ស្រុក និងក្រុង ការបង្កើតឱ្យមានយន្តការសម្រាប់ការផ្ទេរថវិកាទៅឱ្យថ្នាក់នេះ និងការងាររៀបចំការិយាល័យ និងបុគ្គលិកចាំបាច់មួយចំនួន[26] ។

ក្នុងរូបភាពមួយ តួនាទីសកម្មភាពរបស់រតនាគារអាចធ្វើឱ្យគេយល់ថា ជាការជម្រុញការងារបែបមជ្ឈការនៅថ្នាក់ក្រោមជាតិ ។ ប៉ុន្តែតួនាទីនេះសំខាន់ណាស់ សម្រាប់ការគាំពារ និងឃ្លាំមើលការចំណាយធនធានសាធារណៈ ។ ដូច្នេះ នៅពេលនិយាយពីការរៀបចំប្រព័ន្ធថវិកាថ្នាក់ក្រោមជាតិ សំណួរមិនមែននៅត្រង់ថា តើថ្នាក់ជាតិត្រូវធ្វើ ឬថ្នាក់ក្រោមជាតិត្រូវធ្វើនោះទេ ។ សំខាន់ត្រូវស្វែងរកតុល្យភាពរវាងកត្តាពីរគឺទី១ ស្វ័យភាពហិរញ្ញវត្ថុរបស់ថ្នាក់ក្រោមជាតិ និងទី២ ការធានាគណនេយ្យភាពក្នុងការប្រើប្រាស់ធនធានដែលបានប្រគល់ទៅឱ្យថ្នាក់ក្រោមជាតិឱ្យបាន ដោយអនុលោមទៅតាមច្បាប់ និងវិធានពាក់ព័ន្ធរបស់ជាតិ ។ គេរំពឹងថា ចំណុចលម្អិតបន្ថែមលើបញ្ហានេះ នឹងមានចែងនៅក្នុងច្បាប់របបហិរញ្ញវត្ថុ និងការគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ដែលនឹងត្រូវអនុម័តនាពេលឆាប់ៗនេះ[27] ។

---

25 ច្បាប់ហិរញ្ញវត្ថុ ឆ្នាំ២០០៨ ជំពូកទី៣ និងទី៤

26 កិច្ចសម្ភាសន៍ជាមួយមន្ត្រីរតនាគារ

27 សុន្ទរកថារបស់ឯកឧត្តម គាត ឈន់ នៅក្នុងសិក្ខាសាលាជាតិ ឆ្នាំ២០១០ ស្តីពីការរៀបចំផែនការសកម្មភាព និងថវិការបស់គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គ.ជ.អ.ប) ភ្នំពេញ ថ្ងៃទី៦-៧ តុលា ២០០៩ ។

## ប្រអប់ទី ២៖ ការភ្ជាប់ទំនាក់ទំនងរវាងកំណែទម្រង់វិមជ្ឈការ និងការផ្តល់សេវាតាមវិស័យ៖ ករណីវិស័យកសិកម្ម និងធនធានទឹក

ទាក់ទងនឹងការបែងចែកថវិការវាងថ្នាក់ក្រសួង និងថ្នាក់មន្ទីរ វិស័យកសិកម្ម និងធនធានទឹក នៅមានលក្ខណៈមជ្ឈការខ្លាំង បើធៀបនឹងវិស័យអប់រំ (RGC 2008a) ។ ដូចមានចែងនៅយុទ្ធសាស្ត្រសម្រាប់វិស័យកសិកម្ម និងធនធានទឹក (២០០៦-១០) វិស័យទាំងពីរនេះត្រូវសង្កត់ធ្ងន់ជាពិសេសលើ (១) ការលើកកម្ពស់វិស័យកសិកម្ម និង (២) ការស្តារ និងកសាងហេដ្ឋារចនាសម្ព័ន្ធ ។ គោលនយោបាយនេះមាន ៨ផ្នែក ដែលនៅទីនេះសូមលើកយកតែ ២ចំណុចមកធ្វើជាឧទាហរណ៍៖

- ផ្នែកទី ៧៖ បង្កើនផលិតភាពនៅក្នុងវិស័យកសិកម្ម
- ផ្នែកទី ៥៖ លើកកម្ពស់សិទ្ធិអំណាចរបស់ប្រជាជន និងសហគមន៍

ថ្មីៗនេះ ការត្រួតពិនិត្យឡើងវិញលើចំណាយសាធារណៈ (ហៅកាត់ជាភាសាអង់គ្លេសថា PER) សម្រាប់វិស័យកសិកម្ម និងធនធានទឹក បានផ្តល់ជារបកគំហើញគួរឱ្យចាប់អារម្មណ៍មួយចំនួន ។ ទី១ គេរកឃើញថា នៅក្នុងវិស័យទាំងពីរ ការធ្វើវិភាគលើមុខងារមានការលំបាក ដោយសារចំណាត់ថ្នាក់ថវិកាបច្ចុប្បន្នមិនធ្វើតាមមុខងារទេ តែធ្វើតាមអង្គភាពរដ្ឋបាល (ពោលគឺបែងចែងតាមក្រសួង និងនាយកដ្ឋាន) និងតាមចំណាត់ថ្នាក់សេដ្ឋកិច្ច (ពោលគឺបែងចែងរវាងចំណាយចរន្ត និងចំណាយមូលធន) ។ ដោយសារមានការលំបាកបែបនេះ PER បានសម្រេចប្រើប្រាស់ថវិកាចរន្ត តាមនាយកដ្ឋាន ជាមូលដ្ឋានសម្រាប់ការវិភាគចំណាយតាមមុខងារ (World Bank forthcoming) ។

របកគំហើញក្នុងវិស័យកសិកម្ម បង្ហាញថា សេវាផ្សព្វផ្សាយកសិកម្មសំខាន់ជាខ្លាំងសម្រាប់ការបង្កើនផលិតភាព (ផ្នែកទី៧ ខាងលើ) ប៉ុន្តែសេវានេះទទួលបានត្រឹមតែ ២,៨% (ប្រហែល ១២១២លានរៀល) នៃចំណាយចរន្តសរុបរបស់ក្រសួងប៉ុណ្ណោះនៅឆ្នាំ២០០៨ ។ ប៉ុន្តែក្នុងពេលជាមួយគ្នា សេវាផ្សព្វផ្សាយកសិកម្មទទួលបានជំនួយជាច្រើនពីដៃគូអភិវឌ្ឍន៍ ពោលគឺប្រហែល ៩៥% នៃចំណាយសរុបលើសេវានេះ ក្នុងឆ្នាំ២០០៨ (ប្រហែល ២៤.៣៨៩លានរៀល) (World Bank forthcoming) ។

ទាក់ទិននឹងការផ្ទេរមុខងារ ក្នុងវិស័យកសិកម្មវិញ នៅក្នុងសិក្ខាសាលានៃការតាក់តែងកម្មវិធីជាតិ ក្រសួងកសិកម្មបានលើកជាមុខងារចំនួន ១០ សម្រាប់ការពិចារណានឹងផ្ទេរក្នុងរយៈពេល ៥ ទៅ ១០ឆ្នាំខាងមុខ ក្នុងនោះក៏មានមុខងារក្នុងការផ្តល់សេវាផ្សព្វផ្សាយកសិកម្មផងដែរ ។ យោងតាមរបកគំហើញរបស់ PER ខាងលើ យើងអាចរំពឹងថា ប្រសិនបើមានការផ្ទេរមុខងារនេះមែន អាចមានការប៉ះពាល់ខ្លាំងទៅលើការផ្តល់ហិរញ្ញប្បទានពីដៃគូអភិវឌ្ឍន៍ដែលមានទំហំច្រើនលើសលុប បើធៀបនឹងហិរញ្ញប្បទានពីថវិកាជាតិ ។

ខាងលើនេះជាឧទាហរណ៍ជាក់ស្តែងមួយបង្ហាញថាការធ្វើវិមជ្ឈការអាចប៉ះពាល់ដោយផ្ទាល់ទៅលើរបៀបរបបនៃការផ្តល់ជំនួយពីដៃគូអភិវឌ្ឍន៍។ ដោយសារហេតុផលនេះ មានម្ចាស់ជំនួយខ្លះបានចាប់ផ្តើមពិនិត្យមើលថា តើគម្រោងរបស់ខ្លួនគួរកែប្រែយ៉ាងណា ដើម្បីឱ្យសមស្របនឹងគោលនយោបាយវិមជ្ឈការរបស់រដ្ឋាភិបាល ។ ឧទាហរណ៍ ធនាគារអភិវឌ្ឍន៍អាស៊ី បានពិនិត្យលើគម្រោងអភិវឌ្ឍន៍ជនបទជុំវិញទន្លេសាបរបស់ខ្លួន ដែលមានទំហំ ៥៥ លានដុល្លារ ហើយបានរកឃើញថា សព្វថ្ងៃគម្រោងនេះប្រើប្រាស់ធនធានយ៉ាងច្រើន សម្រាប់ចំណាយរដ្ឋបាលនៅក្នុងអង្គភាពអនុវត្តគម្រោង ។ គេក៏បានលើកជាជម្រើសមួយដែរថា នាពេលអនាគត ការអនុវត្តផ្ទាល់នៅក្នុងគម្រោង អាចនឹងធ្វើនៅថ្នាក់ស្រុកដែលជាថ្នាក់នឹងត្រូវទទួលបានមុខងារច្រើន (Niazi and Lamont forthcoming) ។

វិស័យធនធានទឹក មានចំណុចខុសពីវិស័យកសិកម្មនៅត្រង់ថា វិស័យនេះចំណាយច្រើនលើការផ្តល់ហេដ្ឋារចនាសម្ព័ន្ធ ជាជាងការផ្តល់សេវា ។ ហេតុដូច្នេះ វិស័យធនធានទឹកមានខ្ទង់ចំណាយមូលធនច្រើនជាងវិស័យកសិកម្ម ។ PER បានជ្រើសយកនាយកដ្ឋានវិស្វកម្មមកធ្វើការត្រួតពិនិត្យ ។ នាយកដ្ឋាននេះ មានតួនាទីកសាង ជួសជុល និងថែរក្សាសំណង់ធារាសាស្ត្រ ។ គេរកឃើញថា ចំណាយសម្រាប់ការជួសជុល និងថែទាំ មានទំហំតូចជាខ្លាំង បើធៀបនឹងចំណាយសរុបរបស់នាយកដ្ឋានទាំងមូល ពោលគឺប្រមាណតែ ១០% នៅចន្លោះឆ្នាំ២០០៦ - ២០០៨ និងប្រមាណ ១៤% នៅឆ្នាំ២០០៩ បើគិតជាចំនួន គឺប្រមាណ ១លានដុល្លារ ។ របកគំហើញនេះ បញ្ជាក់ពីភាពខ្វះខាតការគាំទ្រពីរដ្ឋាភិបាលទៅលើការធានានិរន្តរភាពនៃសំណង់ធារាសាស្ត្រជាច្រើននៅក្នុងប្រទេស (World Bank forthcoming) ។

ទាក់ទិននឹងការផ្ទេរមុខងារក្នុងវិស័យធនធានទឹកវិញ នៅក្នុងសិក្ខាសាលានៃការតាក់តែងកម្មវិធីជាតិ ក្រសួងបានលើកយកតែមុខងារពីរគត់សម្រាប់ពិចារណាពីការផ្ទេរក្នុងរយៈពេល ៥ - ១០ឆ្នាំខាងមុខ៖ (១) ការជួសជុល និងថែទាំសំណង់ធារាសាស្ត្រខ្នាតតូច និង (២) ការសម្របសម្រួល និងគាំទ្រដល់ការបង្កើតក្រុមកសិករប្រើប្រាស់ទឹក ។ តាមរបកគំហើញរបស់ PER ខាងលើ យើងអាចសន្និដ្ឋានបានថា បើទោះជាមុខងារទាំងពីរត្រូវបានផ្ទេរមែន ក៏មិននាំឱ្យមានការផ្លាស់ប្តូរច្រើនដែរ លុះត្រាណាមានការបង្កើនថវិកាសម្រាប់ចំណាយលើការថែទាំ និងជួសជុល ។

ចំនុចមួយទៀត គឺគោលនយោបាយទាំងក្នុងវិស័យកសិកម្ម និងធនធានទឹក បានលើកកម្ពស់ដល់តួនាទី និងការចូលរួមរបស់សហគមន៍មូលដ្ឋាន ។ សហគមន៍ទាំងនេះ រួមមាន ក្រុមកសិករប្រើប្រាស់ទឹក និងក្រុមជួយខ្លួនឯងដែលជួយគ្នាលើការងារដាំដុះ និងចិញ្ចឹមសត្វ (ផ្នែកទី ៥ ខាងលើ) ។ ការសិក្សាកន្លងមករកឃើញថា នៅតាមជនបទ ក្រុមសហគមន៍ទាំងនេះ បានដើរតួនាទីយ៉ាងសំខាន់នៅក្នុងការអភិវឌ្ឍមូលដ្ឋាន ប៉ុន្តែពួកគេហាក់នៅមិនទាន់ធ្វើការសហការឱ្យបានទៀងទាត់ជាមួយនឹងអាជ្ញាធររបស់រដ្ឋនៅឡើយ ។ ការសិក្សាកន្លងមកក៏បានឱ្យដឹងដែរថា ដើម្បីធ្វើឱ្យក្រុមទាំងនេះអាចមានលទ្ធភាព និងមាននិរន្តរភាពជាងមុន រាជរដ្ឋាភិបាលត្រូវផ្តល់ការគាំទ្រ និងត្រូវមានការចែងច្បាស់លាស់ពីសិទ្ធិអំណាច និងទំនាក់ទំនងផ្លូវការរវាងរដ្ឋបាលថ្នាក់ក្រោមជាតិ និងក្រុមសហគមន៍ទាំងនេះ (Ngin 2010; So, Ratner et al. 2010) ។

## ៥.៣. តួនាទីរបស់ដៃគូអភិវឌ្ឍន៍ និងការអនុវត្តគម្រោងអភិវឌ្ឍន៍

ដើម្បីសម្របតាមក្របខ័ណ្ឌនៃកំណែទម្រង់វិមជ្ឈការរបស់រាជរដ្ឋាភិបាល ដៃគូអភិវឌ្ឍន៍ បានចាប់ផ្តើមធ្វើការសម្រួលរបៀបរបបក្នុងការផ្តល់ជំនួយហិរញ្ញវត្ថុ និងជំនួយបច្ចេកទេសរបស់ខ្លួន ។ ឧទាហរណ៍ ថ្មីៗនេះភ្នាក់ងារដៃគូអភិវឌ្ឍន៍ចំនួន ១៥ បានចាប់ផ្តើមធ្វើផែនការរួមគ្នាមួយ សំដៅគាំទ្រដល់ការងារវិមជ្ឈការរបស់រាជរដ្ឋាភិបាល ។ ដៃគូអភិវឌ្ឍន៍ទាំងនេះ បានផ្តុំគ្នាជា ៤ក្រុម ។ ក្រុមនីមួយៗផ្តោតលើទិដ្ឋភាពផ្សេងគ្នានៃកំណែទម្រង់ (Niazi and Lamont forthcoming)៖

១. ក្រុមសហគមន៍អឺរ៉ុប ផ្តោតលើទិដ្ឋភាពនៃការលើកកម្ពស់លទ្ធិប្រជាធិបតេយ្យ គណនេយ្យភាព សម្លេង និងការចូលរួមរបស់ប្រជាជន ។
២. ក្រុម UNDP ផ្តោតលើគោលនយោបាយទូទៅ និងធ្វើការយ៉ាងជិតស្និទ្ធជាមួយ គ.ជ.អ.ប ។
៣. ក្រុមធនាគារពិភពលោក ធនាគារអភិវឌ្ឍន៍អាស៊ី UNCDF, GTZ, Unicef ផ្តោតលើការងារវិមជ្ឈការហិរញ្ញវត្ថុ ។
៤. ដៃគូអភិវឌ្ឍន៍ផ្សេងទៀត ដូចជា JICA, Danida និង AusAid បានធ្វើការក្នុងរូបភាពជាគម្រោងដាច់ដោយឡែក និងផ្តល់ជាជំនួយទៅលើទិដ្ឋភាពជាក់លាក់ខ្លះ នៅក្នុងគោលនយោបាយវិមជ្ឈការទូទៅ ។

ទាក់ទងនឹងវិមជ្ឈការហិរញ្ញវត្ថុ ធនាគារពិភពលោក ធនាគារអភិវឌ្ឍន៍អាស៊ី និង UNCDF បានដើរតួនាទីគាំទ្រយ៉ាងសំខាន់ ហើយបានយល់ស្របគ្នាថា ពួកគេនឹងធ្វើការឲ្យបានជិតស្និទ្ធជាមួយគ្នា បើទោះជាផែនការសកម្មភាពលម្អិតរបស់ពួកគេ នៅមិនទាន់បានបន្សុីគ្នានៅឡើយក៏ដោយ ។ គួរកត់សំគាល់ថា ធនាគារពិភពលោក និងធនាគារអភិវឌ្ឍន៍អាស៊ី មានតួនាទីយ៉ាងសំខាន់ ព្រោះស្ថាប័នទាំងពីរនេះ ក៏បានជួយគាំទ្រយ៉ាងច្រើនដល់កម្មវិធីកំណែទម្រង់ប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដូច្នេះអាចដើរតួដោយផ្ទាល់ក្នុងការសម្របសម្រួលកំណែទម្រង់ទាំងពីរ ។ UNCDF បានគាំទ្រដល់ការតាក់តែងសេចក្តីព្រាងច្បាប់របបហិរញ្ញវត្ថុ និងការគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ក្នុងពេលដែល GTZ និង Unicef បានចាប់ផ្តើមរៀបចំជាឯកសារជំនួយស្មារតីមួយចំនួនសម្រាប់ការពិភាក្សាអំពីការផ្ទេរមុខងារ ។

បញ្ហាប្រឈមមួយ គឺការកែប្រែជាបណ្តើរៗពីការធ្វើការតាមគម្រោងដាច់ដោយឡែក មកជាការគាំទ្រសមាសធាតុជាក់លាក់របស់កំណែទម្រង់ ។ នៅពេលធ្វើវិមជ្ឈការហិរញ្ញវត្ថុ ការអនុវត្តគម្រោងរបស់ដៃគូអភិវឌ្ឍន៍នឹងមានការផ្លាស់ប្តូរ ។ ឧទាហរណ៍ ធនាគារអភិវឌ្ឍន៍អាស៊ីបានវិភាគលើគម្រោងទាំងឡាយរបស់ខ្លួនសម្រាប់រយៈពេល ២០០៩-២០១២ ហើយបានធ្វើចំណាត់ថ្នាក់គម្រោងទៅតាមកម្រិតមុខងាររបស់វា៖ (១) កម្រិតថ្នាក់ជាតិ (២) កម្រិតថ្នាក់ក្រោមជាតិ និង (៣) កម្រិតថ្នាក់តំបន់ និង (៤) កម្រិតថ្នាក់ជាតិលាយជាមួយនឹងថ្នាក់ក្រោមជាតិ (Niazi and Lamont forthcoming) ។

ដើម្បីធ្វើចំណាត់ថ្នាក់នេះ ធនាគារអភិវឌ្ឍន៍អាស៊ីបានប្រើគោលការណ៍មួយចំនួន ដូចជា គោលការណ៍បង្អិតអ្នកផ្តល់សេវាទៅជិតនឹងអ្នកប្រើប្រាស់ គោលការណ៍វិមាត្រសេដ្ឋកិច្ច គោលការណ៍សមភាព ។ល។ គេបានរកឃើញថា ២៣% នៃមុខងារដែលស្ថិតក្នុងគម្រោងទាំងនោះ អាចចាត់ក្រោម "កម្រិតថ្នាក់ជាតិ" និងប្រមាណ ៧៧% ទៀតអាចចាត់ចូលក្នុង "កម្រិតថ្នាក់ជាតិលាយជាមួយនឹងថ្នាក់ក្រោមជាតិ" ។ ឈរលើបេកគំហើញនេះ ធនាគារអភិវឌ្ឍន៍អាស៊ី នឹងត្រូវធ្វើការសម្រេចចិត្តថាតើគម្រោង និងសកម្មភាពណាដែលខ្លួននៅបន្តធ្វើការជាមួយដៃគូជាស្ថាប័នថ្នាក់ជាតិ និងគម្រោង និងសកម្មភាពណា ដែលត្រូវប្តូរទៅធ្វើការជាមួយថ្នាក់ក្រោមជាតិ (ជាពិសេសថ្នាក់ស្រុក) ។

ការផ្លាស់ប្តូរពីការងារក្នុងរូបភាពជាគម្រោង មកជាការធ្វើការតាមកម្មវិធី គឺជាកត្តាសំខាន់ ។ ជាទូទៅ បើធ្វើការតាមគម្រោង ភាគច្រើនវាមានរយៈពេលកំណត់ និងខ្វះនិរន្តរភាព ព្រោះពេលគម្រោងចប់ អ្វីៗច្រើនចប់តាមគម្រោងដែរ ។ លក្ខណៈនេះ ខុសពីមុខងារ ដែលសំដៅធានាឱ្យមាននិរន្តរភាពនៅក្នុងការផ្តល់សេវាប្រកបដោយគណនេយ្យភាព ។ ការផ្លាស់ប្តូរពីការងារតាមគម្រោង មកជាការគាំទ្រដល់មុខងារជាក់លាក់ នឹងត្រូវការពេលយូរ ប៉ុន្តែចាំបាច់ត្រូវតែធ្វើ ។

ដោយសារប្រព័ន្ធគ្រប់គ្រងរបស់រដ្ឋាភិបាលនៅទន់ខ្សោយ ឯកំណែទម្រង់ហិរញ្ញវត្ថុសាធារណៈនៅបន្តធ្វើ យើងរំពឹងថា ដៃគូអភិវឌ្ឍន៍នឹងត្រូវបន្តអនុវត្តប្រើអង្គភាពគ្រប់គ្រងគម្រោង និងបន្តបង្វែរ និងគ្រប់គ្រងជំនួយរបស់គេ តាមប្រព័ន្ធមួយផ្សេង

ក្រៅពីប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុរបស់រដ្ឋ ។ ហេតុនេះហើយ នៅក្នុងក្របខ័ណ្ឌនៃផែនការ ៣ឆ្នាំរបស់ គ.ជ.អ.ប គេនៅតែរំពឹងថា ហិរញ្ញប្បទានតាមគម្រោងអភិវឌ្ឍន៍ នឹងត្រូវយកមកប្រើសម្រាប់កម្មវិធីអភិវឌ្ឍន៍មូលធន ដែលទាក់ទងនឹងមុខងារត្រូវផ្ទេរទៅឱ្យថ្នាក់ក្រោមជាតិ (សូមមើលតារាង ៣ ខាងដើម) ។

## ៦. សេចក្តីសន្និដ្ឋាន

ជាសេចក្តីសន្និដ្ឋាន អត្ថបទនេះសូមគូសបញ្ជាក់ចំណុចសំខាន់ៗមួយចំនួនទាក់ទងនឹងវិមជ្ឈការហិរញ្ញវត្ថុនៅកម្ពុជា៖

ទី១ ដើម្បីសម្រេចបាននូវការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ វិមជ្ឈការហិរញ្ញវត្ថុនៅជំហានខាងមុខ ត្រូវផ្តោតទាំងលើការកសាងស្ថាប័ន (ពោលគឺកសាងរចនាសម្ព័ន្ធ និងនីតិវិធីពាក់ព័ន្ធ) និងទាំងលើការលើកកម្ពស់ការផ្តល់សេវាសាធារណៈ ។ ចំណុចនេះមានន័យថា ការងារកំណែទម្រង់នៅជំហានបន្ទាប់ត្រូវសំដៅ (១) បង្កើត និងពង្រឹងធាតុសំខាន់នៃវិមជ្ឈការហិរញ្ញវត្ថុ ដូចបានលើកឡើងខាងលើ និង (២) ភ្ជាប់ និងសម្របសម្រួលរវាងកំណែទម្រង់វិមជ្ឈការ និងការងារផ្តល់សេវាតាមវិស័យ ។ ចំណុចទីពីរនេះសំខាន់ណាស់ ហើយមិនទាន់មានការយកចិត្តទុកដាក់គ្រប់គ្រាន់នៅឡើយក្នុងរយៈកាលកន្លងមក ។

ទី២ ជំហានបន្ទាប់នៃកំណែទម្រង់ ត្រូវតែមានលក្ខណៈគ្រប់ជ្រុងជ្រោយ និងមានការសម្របសម្រួលខ្ពស់ទាំងនៅកម្រិតគោលនយោបាយ កម្រិតនៃការអនុវត្ត និងកម្រិតនៃកម្មវិធីកំណែទម្រង់ ។

ទី៣ ភាពគ្រប់ជ្រុងជ្រោយ មិនមែនមានន័យថា រដ្ឋាភិបាលត្រូវចាត់ចែងគ្រប់ទិដ្ឋភាពនៃកំណែទម្រង់ក្នុងពេលតែមួយនោះទេ ។ ការធ្វើបែបនេះ អាចនាំឱ្យហួសលទ្ធភាពដែលមានបច្ចុប្បន្ន និងផ្ទុយពីគោលការណ៍ រៀនបណ្តើរ ធ្វើបណ្តើររបស់រាជរដ្ឋាភិបាល ។ ផ្ទុយទៅវិញ ភាពគ្រប់ជ្រុងជ្រោយ មានន័យថា ត្រូវមានជាចក្ខុវិស័យច្បាស់លាស់សម្រាប់រយៈពេលវែង និងមធ្យម និងការរំពឹងទុកឱ្យបានត្រឹមត្រូវពីបញ្ហាប្រឈមដែលអាចកើតមាន និងរកដំណោះស្រាយសម្រាប់បញ្ហាទាំងនោះជាជំហានៗប្រកបដោយយុទ្ធសាស្ត្រ ។

ទី៤ ការភ្ជាប់រវាងកំណែទម្រង់វិមជ្ឈការហិរញ្ញវត្ថុ និងការងារផ្តល់សេវាតាមវិស័យ គឺជាបញ្ហាប្រឈមធំមួយ ។ ទី១ ដោយសារក្រសួងតាមវិស័យនីមួយៗ ភាគច្រើនមិនទាន់បានគិតគូរឲ្យដិតដល់អំពីការងារវិមជ្ឈការទេ ដែលនាំឱ្យមានកង្វះខាតការសម្របសម្រួល ទាំងក្នុងកម្រិតគោលនយោបាយ និងកម្រិតនៃការអនុវត្ត ។ ទី២ ដោយសារកង្វះការសម្របសម្រួលរវាងគម្រោងអភិវឌ្ឍន៍ដែលគាំទ្រដល់ការងារវិមជ្ឈការ និងគម្រោងដែលដំណើរតាមវិស័យ ។ ដើម្បីដោះស្រាយបញ្ហានេះ ក្រសួងមហាផ្ទៃ និងក្រសួងជំនាញ តាមរយៈ គ.ជ.អ.ប ត្រូវសហការណ៍ជាមួយគ្នាឱ្យបានច្រើន ជៀសវាងការភ័ន្តច្រឡំថា កំណែទម្រង់វិមជ្ឈការ គឺជាដែនសមត្ថកិច្ចរបស់ក្រសួងមហាផ្ទៃតែមួយ តែជាកម្មវិធីកំណែទម្រង់របស់រដ្ឋទាំងមូល ។ ដៃគូអភិវឌ្ឍន៍ក៏ត្រូវចូលរួមសហការផងដែរ ។

ទី៥ អត្ថបទនេះមានទាំងសុទិដ្ឋិនិយមផង និងទុទិដ្ឋិនិយមផង ចំពោះអនាគតនៃកំណែទម្រង់វិមជ្ឈការហិរញ្ញវត្ថុនៅកម្ពុជា ។ ម្យ៉ាង យើងមើលឃើញថា បទពិសោធន៍នៃការអនុវត្តកំណែទម្រង់កន្លងមក បានផ្តល់ជាការសង្ឃឹមយ៉ាងរឹងមាំថា រាជរដ្ឋាភិបាលនឹងបន្តការធ្វើបណ្តើរ រៀនបណ្តើររបស់ខ្លួន ដើម្បីជម្នះលើបញ្ហាប្រឈមទាំងឡាយដែលអាចកើតមានឡើង ។ ម្យ៉ាងទៀត បើយើងក្រឡេកមើលខ្លឹមសារលម្អិតនៃកំណែទម្រង់ដែលបានធ្វើ យើងឃើញថា កំណែទម្រង់នៅថ្នាក់ឃុំ/សង្កាត់កន្លងមកមានពាក់ព័ន្ធតិចតួចណាស់នឹងការងារជាមូលដ្ឋានមួយចំនួនដែលត្រូវអនុវត្តនៅដំណាក់កាលបន្ទាប់ ដូចជា ការពិនិត្យមុខងារ ការផ្ទេរមុខងារ និងការផ្ទេរធនធានជាដើម ។ នៅពេលចាប់ផ្តើមធ្វើការងារទាំងនេះ កំណែទម្រង់វិមជ្ឈការនឹងជៀសមិនផុតពីការជំទាស់ពីសំណាក់ស្ថាប័នថ្នាក់ជាតិមួយចំនួន ដែលមិនមានចេតនាព្រលែងសិទ្ធិអំណាច និងធនធានរបស់ខ្លួនឱ្យទៅថ្នាក់ក្រោមជាតិ ។ បញ្ហាប្រឈមទាំងនេះ គឺជាការសាកល្បងមួយទៅលើឆន្ទៈនយោបាយរបស់រាជរដ្ឋាភិបាលនៅក្នុងការងារវិមជ្ឈការ និងការលើកកម្ពស់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅមូលដ្ឋាន ។

# ឯកសារយោង


Bahl, R. (1999), *Implementation rules for fiscal decentralization* (Athens: Georgia State University)

Bahl, R. (2000), *Intergovernmental transfers in developing and transition countries: Principles and practice* (Washington, DC: World Bank)

Bahl, R. (2009), "Promise and reality of fiscal decentralization", in S. Ichimura & R. Bahl (eds.) *Decentralization policies in Asian development* (Singapore: World Scientific Publishing Company)

Bahl, R. & P. Smoke (eds.) (2003), *Restructuring local government finance in developing countries: Lessons from South Africa* (Cheltenham: Edward Elgar Publishing)

Bartholomew, A. & M. Betley (2004), *Deconcentration: Provincial Budget Operations* (Phnom Penh: Seila Task Force)

Blunt, P. & M. Turner (2005), "Decentralization, democracy and development in post-conflict society: commune councils in Cambodia", *Public Administration and Development,* 25, pp. 75–87

Blunt, P. & M. Turner (2007), "Decentralization, deconcentration and poverty reduction in the Asia Pacific", in G.S. Cheema & D.A. Rondinelli (eds.), *Decentralizing governance: Emerging concepts and practices* (Washington, DC: Brookings Institution Press)

Boex, J. (2009), "Moving forward with the development of a national fiscal decentralization policy framework in Cambodia", final Draft (Cambodia: MEF)

Chandler, D. (2008), *A history of Cambodia* (Boulder: Westview Press)

Cambodian People's Party (2008), "Forty-two policy points for the implementation of the CPP policy platforms for the development of communes/*sangkat* 2007–12" (Phnom Penh: CPP)

Dom, C. (2008), *Commune/sangkat budget execution study* (Phnom Penh: NCDD)

Eaton, K., K. Kaiser, & P. Smoke (2010), *The political economy of decentralization reforms: Implications for aid effectiveness* (Washington, DC: World Bank)

Economic Institute of Cambodia (2006), *Local public services: Performance and unofficial fees* (Phnom Penh: EIC)

Ferrazzi, G. (2001), *Assignment of functions for Cambodian communes: A preliminary framework* (Phnom Penh: GTZ and RGC)

Flam, S. (2008), *Functional review in Cambodia: A proposed process for discussion* (Phnom Penh: GTZ)

GTZ (2009), "Functional assignment in multi-level government: A technical paper", Volume I: Conceptual foundation of functional assignment (Phnom Penh: GTZ)

IMF (2004), *Rebuilding fiscal institutions in post-conflict countries* (Washington, DC: IMF)

Keat, C. (2009), *Speech at the 2010 National Workshop of the Annual Work Plan and Budget of the NCDD (6-7 October, 2009)* (Phnom Penh: NCDD)

Malena, C. & K. Chhim (2009), *Linking citizens and the state: An assessment of civil society's contribution to good governance in Cambodia* (Washington, DC: World Bank)

Manor, J. (1999), *The political economy of democratic decentralization* (Washington, DC: World Bank)

Meerkerk, D., S. Hean & S. Lanjouw (2008), *Survey of citizen and councilor perceptions of commune councils* (Phnom Penh: PACT and USAID)

Ministry of Agriculture, Forestry and Fishery (MAFF) and Ministry of Water Resource & Meteorology (MOWRAM) (2007), *Strategy for agriculture and water (2006-10)* (Phnom Penh: TWG on Agriculture and Water).

Ministry of Education, Youth and Sport (2005a), *Education Strategic Plan (ESP) 2006–2010* (Phnom Penh: RGC)

Ministry of Education, Youth and Sport (2005b), *Education Sector Support Program (ESSP) 2006–2010* (Phnom Penh: RGC)

Ministry of Health (2008), *Health Sector Strategic Plan 2 (HSP2)* (Phnom Penh: MoH)

National Committee for Democratic Development (2008), *Prakas No. 68, dated 8 September 2008, on the new structure of the PRDC/ExCom* (Phnom Penh: NCDD)

National Committee for Democratic Development (2010a), *Outline of the first 3 years (2011–2013) implementation plan of NP-SNDD* (Phnom Penh: NCDD)

National Committee for Democratic Development (2010b), *An analysis of the Commune Development Planning Data Base* (Phnom Penh: NCDD)

National Committee for Democratic Development (2010c), *Three-Year Implementation Plan of the National Program on Sub-national Democratic Development (2011–2013)* (Phnom Penh: NCDD)

Ngin, C. (2010), *Farmers' Associations in Cambodia: Internal functions and external relations* (Phnom Penh: Regional Centre for Social Science and Sustainable Development)

Niazi, T. & J. Lamont (forthcoming), *De-concentration and decentralization reforms in Cambodia: Recommendations for an Institutional Framework* (Phnom Penh: ADB)

Öjendal, J. & S. Kim (2008), *A background study on the district office's role and potential facing the decentralization and deconcentration reforms* (Göteborg & Phnom Penh: SIDA)

Oosterom, M. (2009), *Fragility at the local level: Challenges to building local state-citizen relations in fragile settings,* working paper prepared for workshop on Local Governance in Fragile Settings: Strengthening Local Governments, Civic Action or Both, the Hague)

Pak, K. (2009a), *Mapping budget information in education* (Phnom Penh: NGO Forum on Cambodia)

Pak, K. (2009b), *Mapping budget information in health* (Phnom Penh: NGO Forum on Cambodia)

Pak, K. (2010), "Assessment of actual and potential commune and *sangkat* council functions", unpublished field report (Phnom Penh: National League of the Communes/*Sangkats* and GTZ Cambodia)

Pak, K. (forthcoming), "A dominant party in a weak state: How the ruling party in Cambodia manages to become and stay dominant in power", PhD dissertation (Australian National University)

Pak, K. & D. Craig (2008), *Accountability and public expenditure management in decentralised Cambodia,* Working Paper 38, (Phnom Penh: CDRI)

Project to Support Democratic Development through Decentralization and Deconcentration (2009), *2009 Annual Workplan and Budget* (Phnom Penh: PSDD)

Romeo, L. (2003), "The role of external assistance in supporting decentralization reform", *Public Administration and Development,* 23, pp: 89–96

Rondinelli, D. A. (2007), "Parallel and partnership approaches in decentralized governance: Experiences in weak states", in G.S. Cheema & D.A. Rondinelli (eds.), *Decentralizing governance: Emerging concepts and practices* (Washington, DC: Brookings Institution Press)

Royal Government of Cambodia (1993), *Law on public financial system* (Phnom Penh: RGC)

Royal Government of Cambodia (1994), *Sub-decree on provincial administration* (Phnom Penh: RGC)

Royal Government of Cambodia (1998), "Royal decree on provincial/municipal budget and durable assets regime" (Phnom Penh: RGC)

Royal Government of Cambodia (2001), *Law on Management and Administration of Communes/Sangkat* (Phnom Penh: RGC)

Royal Government of Cambodia (2002), *Budget Law for 2002* (Phnom Penh: RGC)

Royal Government of Cambodia (2005), *Strategic Framework for Decentralization and Deconcentration Reforms* (Phnom Penh: RGC)

Royal Government of Cambodia (2007), *Budget Law for 2008* (Phnom Penh: RGC)

Royal Government of Cambodia (2008a), *Budget Law for 2009* (Phnom Penh: RGC)

Royal Government of Cambodia (2008b), *The Cambodia aid effectiveness report: 2008* (Phnom Penh: RGC)

Royal Government of Cambodia (2008c), *Mid-term review 2008 on National Strategic Development Plan* (NSDP) (Phnom Penh: RGC)

Royal Government of Cambodia (2008d), *Public Financial Management Reform Programme Stage 2: Building on improved budget credibility toward achieving better financial accountability* (Phnom Penh: RGC and the World Bank.)

Royal Government of Cambodia (2008e), "Royal Decree on the Establishment of the National Committee for Democratic Development" (Phnom Penh: RGC)

Royal Government of Cambodia (2008f), *Law on public financial system* (Phnom Penh: RGC)

Royal Government of Cambodia (2008g), *Law on Administrative Management of the Capital, Provinces, Municipalities, Districts and Khans* (Phnom Penh: RGC)

Royal Government of Cambodia (2009), *Public Investment Programme: 3 Year Rolling 2010–2012* (Phnom Penh: Ministry of Planning)

Royal Government of Cambodia (2010a), *National Program for Sub-National Democratic Development (NP-SNDD) 2010–2019* (Phnom Penh: RGC)

Royal Government of Cambodia (2010b), *Aid effectiveness report* (Phnom Penh: RGC)

Royal Government of Cambodia (2010c), *National Program for Sub-National Democratic Development (NP-SNDD) 2010–2019* (Phnom Penh: RGC)

Royal Government of Cambodia (2010d), "Sub-decree (no. 93) on resources transfer from national budget to Commune-*Sangkat* Fund" (Phnom Penh: RGC)

Rudengren, J. & J. Öjendal (2002), *Learning by doing: an analysis of the Seila experience in Cambodia* (Stockholm: SIDA)

Rusten, C., S. Kim, N. Eng & K, Pak (2004), *The challenges of decentralization design in Cambodia* (Phnom Penh: CDRI)

Smoke, P. (2001), *Fiscal decentralization in developing countries: A review of current concepts and practice* (New York: United Nations Research Institute for Social Development)

Smoke, P. (2007), "Fiscal decentralization and intergovernmental relations: Navigating a viable path to reform", in G.S. Cheema & D.A. Rondinelli (eds.), *Decentralizing governance: Emerging concepts and practices* (Washington D.C: Brookings Institution Press)

Smoke, P., and M.S. Winters (2011), *Donor program harmonization, aid effectiveness and decentralized governance: Local Governance & Decentralization* (Bonn, Germany: Development Partners Working Group on Local Governance and Decentralisation)

So, S., & B. Ratner, (2010), *Conflict and collective action in Tonle Sap fisheries: Adapting institutions to support community livelihoods* (Phnom Penh: CDRI)

SEILA Task Force (2008), *Seila program,* Volume I: Design, implementation and management (Phnom Penh: STF)

Taliercio, R. (2008), *Unlocking capacity and debunking political will: Cambodia's public financial management reforms, 2002–2007* (Bangkok: Asia Pacific Governance Institute)

United Nations Capital Development Fund  (2005), *Delivering goods and local government* (New York: UNCDF)

United Nations Capital Development Fund (2010), *Local development outlook: Cambodia* (Phnom Penh: UNCDF)

VBNK & Results-based management group (RBMG) (2010), *Phase two evaluation of the Paris Declaration: Technical volume: Cambodia country study report* (Phnom Penh: VBNK)

World Bank (1998), *The Assignment of Revenues and Expenditures in Intergovernmental Fiscal Relations* (Washington, DC: World Bank)

World Bank (2005), *PETS in education* (Washington, DC: World Bank)

World Bank (2010), *Project appraisal document (PAD) for livelihood enhancement and association of the poor project* (Phnom Penh: World Bank)

World Bank (forthcoming), *PER in agriculture, irrigation and rural development* (Phnom Penh: World Bank)

World Bank & Asian Development Bank (2003), *Enhancing service delivery through improved resource allocation and institutional reform—integrated fiduciary assessment and public expenditure review (IFAPER)* (Phnom Penh: World Bank)

# បញ្ជីឯកសារពិភាក្សារបស់វិទ្យាស្ថាន CDRI

១៨. Martin Godfrey, សូ-សុវណ្ណារិទ្ធ ទេព-សាវ៉ាវី ប៉ុន-ដូរីណា Claude-Katz, Sarthi-Acharya, ស៊ីសុវត្ថិ-ឌួង-ចាន់តូ និងហ៊ីង ថូរ៉ាក់ស៊ី (តុលា ២០០១) *ការសិក្សាអំពីទីផ្សារពលកម្មនៅកម្ពុជា៖ ការកាត់បន្ថយភាពក្រីក្រ ការលូតលាស់ និងការកែតម្រូវចំពោះវិបត្តិ* (ឯកសារពិភាក្សា លេខ១៨) ជាភាសាខ្មែរ តម្លៃ ៨.០០០រៀល ។

១៩. ច័ន្ទ-សុផល ទេព-សាវ៉ាវី និង Sarthi Acharya, (ធ្នូ ២០០១) *ការកាន់កាប់ដីនៅកម្ពុជា៖ ការវិភាគលើទិន្នន័យចុងក្រោយ* (ឯកសារពិភាក្សាលេខ ១៩) ជាភាសាខ្មែរ តម្លៃ៨.០០០រៀល ។

២០. សូ-សុវណ្ណារិទ្ធ រៀល-សុភាព អ៊ុច-ឧទេយ្យ ស៊ី-រត្ន័មុនី, Brett Ballard និង Sarthi Acharya (មីនា ២០០២) *ការវាយតម្លៃសង្គមពាក់ព័ន្ធនឹងដីធ្លីនៅកម្ពុជា* (ឯកសារពិភាក្សាលេខ ២០) ជាភាសាខ្មែរ តម្លៃ ៨.០០០រៀល ។

២១. Bhargavi Ramamurthy ស៊ុក-បូរ័ក្ស, Per Ronnås និង សុក-ហាច (មីនា ២០០២) ប្រទេសកម្ពុជា ឆ្នាំ១៩៩៩-២០០០៖ *ការផ្តោតលើបញ្ហាដីធ្លី កំលាំងពលកម្ម និងការចិញ្ចឹមជីវិត នៅជនបទ* (ឯកសារពិភាក្សា លេខ ២១) តម្លៃ ៨.០០០រៀល ។

២២. ច័ន្ទ-សុផល និង Sarthi Acharya (កក្កដា ២០០២) *ការលក់ដូរដីធ្លីនៅកម្ពុជា៖ ការវិភាគទិន្នន័យនៃការផ្ទេរ និងការលក់ដូរដីធ្លី* (ឯកសារពិភាក្សាលេខ ២២) ជាភាសាខ្មែរ តម្លៃ ៨.០០០រៀល ។

២៣. Bruce McKenney និង ព្រុំ-តុលា (កញ្ញា ២០០២) *ធនធានធម្មជាតិ និងជីវភាពនៅតាម ជនបទក្នុងប្រទេសកម្ពុជា៖ ការវាយតម្លៃជាមូលដ្ឋាន* (ឯកសារពិភាក្សាលេខ ២៣) ជាភាសា ខ្មែរ តម្លៃ ១០.០០០រៀល ជាអង់គ្លេស តម្លៃ ១០.០០ដុល្លារ ។

២៤. ច័ន្ទ-សុផល គីម-សេតារា និង Sarthi Acharya (ធ្នូ ២០០២) *ដីធ្លី ជីវភាពជនបទ និងសន្តិសុខស្បៀងនៅកម្ពុជា៖ ទស្សនៈបានពីអង្កេតតាមមូលដ្ឋាន* (ឯកសារពិភាក្សាលេខ ២៤) ជាភាសាខ្មែរ តម្លៃ ៦.០០០រៀល ជាអង់គ្លេស តម្លៃ ៧.០០ដុល្លារ ។

២៥. ច័ន្ទ-សុផល និង Sarthi Acharya (ធ្នូ ២០០២) *បញ្ហាប្រឈមចំពោះការចិញ្ចឹមជីវិតនៅ ជនបទ៖ ការសិក្សាលើភូមិចំនួន ៩ នៅកម្ពុជា* (ឯកសារពិភាក្សា លេខ២៥) ជាភាសាខ្មែរ តម្លៃ ៨.០០០រៀល ជាភាសាអង់គ្លេស តម្លៃ ១០.០០ដុល្លារ ។

២៦. Sarthi Acharya គីម-សេតារា ចាប-សុថារិទ្ធ និង មាច-យ៉ាឌី (កញ្ញា ២០០៣) *ការងារក្រៅកសិដ្ឋាន និងការងារមិនមែនកសិកម្ម៖ ទស្សនៈស្តីពីការបង្កើតការងារនៅកម្ពុជា* (ឯកសារពិភាក្សាលេខ ២៦) ជាភាសាខ្មែរ តម្លៃ ៧.០០០រៀល ជាភាសាអង់គ្លេស តម្លៃ ៥,០០ដុល្លារ ។

២៧. យឹម-ជា និង Bruce McKenney (ធ្នូ ២០០៣) *ការនាំចេញត្រីពីបឹងទន្លេសាបទៅប្រទេសថៃ៖ ការវិភាគលើការរាំងស្ទះពាណិជ្ជកម្ម អភិបាលកិច្ច និងបរិយាកាសសម្រាប់ការលូតលាស់* (ឯកសារពិភាក្សាលេខ២៧) ជាភាសាខ្មែរ តម្លៃ ៧.០០០រៀល ជាភាសាអង់គ្លេស ១០,០០ដុល្លារ ។

២៨. ព្រុំ-តុលា និង Bruce McKenney (ធ្នូ ២០០៣) *ការធ្វើពាណិជ្ជកម្មផលព្រៃឈើនៅកម្ពុជា៖ ការប្រឈម ការគំរាមកំហែង និងឱកាសសម្រាប់ពាណិជ្ជកម្មជ័រទឹក* (ឯកសារពិភាក្សាលេខ២៨) ជាភាសាខ្មែរ ៧.០០០រៀល ជាភាសាអង់គ្លេស តម្លៃ ១០,០០ដុល្លារ ។

២៩. យឹម-ជា និង Bruce McKenney (វិច្ឆិកា ២០០៣) *ពាណិជ្ជកម្មត្រីក្នុងស្រុក៖ ករណីសិក្សានៃម៉ាឃីទីងត្រីពីបឹងទន្លេសាបទៅក្រុងភ្នំពេញ* (ឯកសារពិភាក្សាលេខ២៩) ជាភាសាខ្មែរ ៥.០០០រៀល ជាភាសាអង់គ្លេស ៥,០០ដុល្លារ ។

៣០. Caroline Hughes និង គីម-សេតារា (មិថុនា ២០០៤) *ការវិវត្តន៍នៃដំណើរការប្រជាធិបតេយ្យ និងការគ្រប់គ្រងទំនាស់នៅកម្ពុជា៖ ការសិក្សាប្រៀបធៀបការបោះឆ្នោតបីលើកនៅកម្ពុជា* (ឯកសារពិភាក្សាលេខ ៣០) ជាភាសាខ្មែរ តម្លៃ ១០.០០០រៀល ជាភាសាអង់គ្លេស តម្លៃ ១៣,៥០ដុល្លារ ។

៣១. Robert Oberndorf (កក្កដា ២០០៤) *សុខដុមនីយកម្មច្បាប់ទាក់ទងនឹងដំណើរការវិមជ្ឈការនៅកម្ពុជា* (ឯកសារពិភាក្សាលេខ ៣១) ជាភាសាខ្មែរ តម្លៃ ៥.០០០រៀល ជាភាសាអង់គ្លេស តម្លៃ ៦,៥០ដុល្លារ ។

៣២. K. A. S. Murshid និង ទួត-សុខផល្លី (ឧសភា ២០០៥) *សេដ្ឋកិច្ចឆ្លងកាត់ព្រំដែនរបស់ ប្រទេសកម្ពុជា៖ ការសិក្សាជំហានដំបូង* (ឯកសារពិភាក្សាលេខ៣២) ជាភាសាខ្មែរ ៨.០០០រៀល ជាភាសាអង់គ្លេស ៥,០០ដុល្លារ ។

៣៣. Hansen, Kasper K. និង គុប-នេត (ធ្នូ ២០០៦) *Natural Forest Benefits and Economic Analysis of Natural Forest Conversion in Cambodia* (Working Paper No. 33) ជាភាសាអង់គ្លេស តម្លៃ ៨.០០ដុល្លារ ។

៣៤. ប៉ក់-គីមជឿន ហ៊ីង-វុទ្ធី អេង-នេត្រា អាន-សុវត្ថា គឹម-សេតារា, Jenney Knowles និង David Craig (មីនា ២០០៧) *Accountability and Neo-patrimonialism in Cambodia: A Critical Literature Review* (ឯកសារពិភាក្សាលេខ៣៤) ជាភាសាអង់គ្លេស ៦,០០ដុល្លារ ។

៣៥. គឹម-សេតារា និង Joakim Öjendal (ឧសភា ២០០៧) *Where Decentralisation Meets Democracy: Civil Society, Local Government, and Accountability in Cambodia* (ឯកសារពិភាក្សាលេខ៣៥) ជាភាសាអង់គ្លេស តម្លៃ ៤,០០ដុល្លារ ។

៣៦. លឹម-សុវណ្ណារា (វិច្ឆិកា ២០០៧) *Youth Migration and Urbanistion in Cambodia* (ឯកសារពិភាក្សាលេខ ៣៦) ជាភាសាខ្មែរ ៦.០០០រៀល ជាភាសាអង់គ្លេស ៣,៥០ដុល្លារ ។

៣៧. Chem Phalla *et al.* (May 2008), *Framing Research on Water Resources Management and Governance in Cambodia: A Literature Review* ជាភាសាអង់គ្លេស តម្លៃ ៥,០០ដុល្លារ ។

៣៨. Pak Kimchoeun and David Craig, *Accountability and Public Expenditure Management in Decentralised Cambodia* (Working Paper No. 38) ជាភាសាអង់គ្លេស តម្លៃ ៥,០០ដុល្លារ ។

៣៩. Horng Vuthy and David Craig, *Accountability and Planning in Decentralised Cambodia* (Working Paper No. 39) ជាភាសាអង់គ្លេស តម្លៃ ៥,០០ដុល្លារ ។

៤០. Eng Netra and David Craig (forthcoming), *Accountability and Human Resource Management in Decentralised Cambodia* (Working Paper No. 40) ជាភាសាអង់គ្លេស តម្លៃ ៥,០០ដុល្លារ ។

៤១. ហ៊ីង វុត្ថា និង Hossein Jalilian (មេសា ២០០៩) *ផលប៉ះពាល់នៃកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីអាស៊ាន-ចិន ចំពោះបរិស្ថាននៅតាមបណ្តាប្រទេសក្នុងមហាអនុតំបន់មេគង្គ (ឯកសារពិភាក្សាលេខ ៤១)* ជាភាសាខ្មែរ តម្លៃ ៨.០០០រៀល ជាភាសាអង់គ្លេស តម្លៃ៣,០០ដុល្លារ ។

៤២. Thon Vimealea, Ou Sivhuoch, Eng Netra and Ly Tem (October 2009), *Leadership in Local Politics of Cambodia: A Study of Leaders in Three Communes of Three Provinces.*

៤៣. ហ៊ីង វុត្ថា និង បណ្ឌិត ធន់ វឌ្ឍនា (ធ្នូ ២០០៩) *ពាណិជ្ជកម្មកសិកម្មក្នុងមហាអនុតំបន់មេគង្គៈ ករណីដំឡូងឈើ និងកៅស៊ូ នៅកម្ពុជា* (ឯកសារពិភាក្សាលេខ ៤៣) ជាភាសាខ្មែរ តម្លៃ ៦.០០០រៀល ជាភាសាអង់គ្លេស ៣,០០ដុល្លារ ។

៤៤. ច័ន្ទ សុផល (ធ្នូ ២០០៩) *ផលប្រយោជន៍ និងចំណាយនៃទេសន្តរប្រវេសន៍កំលាំងពលកម្មក្នុងមហាអនុតំបន់មេគង្គៈ ករណីសិក្សានៅប្រទេសកម្ពុជា* ជាភាសាខ្មែរតម្លៃ ៨,០០០រៀល ជាភាសាអង់គ្លេស តម្លៃ ៣.០០ដុល្លារ ។

៤៥. CDRI Publication (December 2009), *Costs and Benefits of Cross-country Labour Migration in the GMS: Synthesis of the Case Studies in Thailand, Cambodia, Laos and Vietnam* ជាភាសាអង់គ្លេស តម្លៃ ១,៥០ដុល្លារ ។

៤៦. CDRI Publication (December 2009), *Agricultural Trade in the Greater Mekong Sub-region: Synthesis of the Case Studies on Cassava and Rubber Production and Trade in GMS Countries* ជាភាសាអង់គ្លេស តម្លៃ ១,៥០ដុល្លារ ។

៤៧. Chea Chou (August 2010), *The Local Governance of Common Pool Resources: The Case of Irrigation Water in Cambodia* ជាភាសាអង់គ្លេស តម្លៃ ២,៥០ដុល្លារ ។

៤៨. CDRI Publication (August 2010), *Empirical Evidence of Irrigation Management in the Tonle Sap Basin: Issues and Challenges* ជាភាសាអង់គ្លេស តម្លៃ ២,៥០ដុល្លារ ។

៤៩. ចែម ផល្លា និង សុមេធ ប៉ារ៉ាឌី (ឧសភា ២០១១), *ការប្រើប្រាស់ចំណេះដឹងជលសាស្ត្រនៃអាងស្ទឹង និងការចូលរួមរបស់សហគមន៍ដើម្បីលើកកម្ពស់ការធ្វើសេចក្តីសម្រេចចិត្តប្រកបដោយការចូលរួមស្តីពីការបែងចែកទឹកសម្រាប់ស្រោចស្រព* ជាភាសាអង់គ្លេស តម្លៃ ២,៥០ដុល្លារ ជាភាសាខ្មែរ តម្លៃ ៨.០០០រៀល ។

**វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា**

☞ អគារលេខ 56 ផ្លូវ 315 ខ័ណ្ឌទួលគោក

✉ ប្រអប់សំបុត្រលេខ 622 ភ្នំពេញ កម្ពុជា

☏ (855-23) 881-384/881-701/881-916/883-603/012 867-278

🖶 (855-23) 880-734

អ៊ីមែល៖ cdri@cdri.org.kh

គេហទំព័រ៖ http://www.cdri.org.kh

តម្លៃ ៨.000 រ

9 789995 052423